ស្ថិតនៅលើព្រំដែន

សិក្សាអំពីទស្សនៈ និងបទពិសោធន៍របស់កុមារដែល
ធ្វើការ/រស់នៅតាមផ្លូវ នៅតាមព្រំដែនខ្មែរ-ថៃ

DAMNOKTOEK (Goutte d'Eau)

up! to end violence

ស្ថិតនៅលើព្រំដែន

សិក្សាអំពីទស្សនៈ និងបទពិសោធន៍របស់កុមារដែលធ្វើការ/រស់នៅតាមផ្លូវ នៅតាមព្រំដែនខ្មែរ-ថៃ

ឧសភា ២០១៧

អ្នករៀបរៀងរបាយការណ៍ និងទទួលបន្ទុកចម្បងផ្នែកស៊ើបអង្កេត

Jarrett Davis

Jarrett Davis, MA
អ្នកប្រឹក្សាផ្នែកកិច្ចការស្រាវជ្រាវ
ភ្នំពេញ ប្រទេសកម្ពុជា
j.davis@up-international.org

Dr. Long Sanrithy
នាយករង
ប៉ោយប៉ែត ប្រទេសកម្ពុជា
deputy@damnoktoek.org

Judith Fiss
សហស្ថាបនិក/អ្នកប្រឹក្សាក្នុងតំបន់អាស៊ី
ហ្ស៊ីរីណែរ ប្រទេសស្វីស
j.fiss@up-international.org

Nathalie Nguyen
បុគ្គលិកសម្របសម្រួលគម្រោង
ប៉ោយប៉ែត ប្រទេសកម្ពុជា
project@damnoktoek.org

Dr. Glenn Miles, PhD
អ្នកប្រឹក្សាផ្នែកកិច្ចការស្រាវជ្រាវជាន់ខ្ពស់
ស្វាន់សៀរ ប្រទេសវេលស៍
drglennmiles@gmail.com

សេចក្ដីថ្លែងអំណរគុណ

បុគ្គលិកសង្គមកិច្ច/អ្នកសម្ភាស

Touy Ban
បុគ្គលិកសម្របសម្រួលមណ្ឌលសំចត អង្គការតំណក់ទឹក

Sineth Phay
បុគ្គលិកសង្គមកិច្ច អង្គការតំណក់ទឹក

Srey Touch
បុគ្គលិកសង្គមកិច្ច អង្គការតំណក់ទឹក

Veth Kim
បុគ្គលិកសម្របសម្រួលមណ្ឌលទទួលកុមារ

អង្គការតំណក់ទឹក

អ្នកប្រឹក្សាផ្នែកការពារកុមារ និងសង្គមកិច្ចៈ

Juliana Snapp, MS

អ្នកប្រែសម្រួលគម្រោងស្រាវជ្រាវ និងរបាយការណ៍ជាភាសាខ្មែរ

Sophorn Phuong
The Vantage Translation

រចនាគម្របសៀវភៅ

Paul Austria

សេចក្តីថ្លែងអំណរគុណពិសេស

ជាដំបូង យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់កុមារា និងកុមារី ដែលធ្វើការនៅតាមដងផ្លូវទីក្រុងប៉ោយប៉ែត។ យើងខ្ញុំពិតជាអរគុណដល់ពួកគេដែលបានចែកចាយនូវបទពិសោធន៍ និងចំណេះដឹងអំពីសហគមន៍របស់ពួកគេ សំដៅចូលរួមចំណែកជួយឲ្យយើងខ្ញុំយល់បន្ថែមទៀតអំពីជីវិត និងការងាររបស់ពួកគេ។ យើងខ្ញុំសូមឧទ្ទិសគម្រោងការងារស្រាវជ្រាវនេះដល់កុមារា និងកុមារីទាំងនេះ។

ជាទីពីរ ការស្រាវជ្រាវនេះពិតជាមិនអាចសម្រេចជារូបរាងបានទេ ប្រសិនបើគ្មានជំនួយថវិកាដ៏សប្បុរសពីមូលនិធិ **CEDAR Fund** ដែលជាអង្គការគ្រីស្តបរិស័ទឯករាជ្យមួយធ្វើការងារសង្គ្រោះ និងកិច្ច ការអភិវឌ្ឍ ប្រចាំក្នុងទីក្រុងហុងកុង និងអង្គការ **Ping-Pong-a-Thon (PPAT**) ដែលជាព្រឹត្តិការណ៍លេងកូនបាល់លើតុ ២៤ម៉ោង ដែលប្រារព្ធធ្វើនៅទីតាំងជាច្រើន នៅទូទាំងប្រទេសអូស្ត្រាលី ដើម្បីស្វែងរកជំនួយសម្រាប់គម្រោងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ និងអំពើកេងប្រវ័ញ្ចមនុស្ស នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍។

យើងខ្ញុំដែលធ្វើការនៅអង្គការ **UP!** ពិតជាសូមថ្លែងអំណរគុណយ៉ាងខ្លាំង ដល់អង្គការទាំងពីរនេះ!

មាតិការ

សេចក្តីផ្តើម.. 3

សង្ខេបរបាយការណ៍ 4

ការពិនិត្យមើលបណ្ណសារស្រាវជ្រាវ 5

ការកំណត់និយមន័យអំពីការពាក់ព័ន្ធនៅតាមផ្លូវ.. 5

កុមារដែលពាក់ព័ន្ធនៅតាមផ្លូវជាសកល.. 6

កុមារដែលពាក់ព័ន្ធនៅតាមផ្លូវក្នុងតំបន់អាស៊ីអាគ្នេយ៍.. 7

តំបន់ប៉ោយប៉ែត និងបរិបទសេដ្ឋកិច្ចសង្គម.. 8

ការប្រើប្រាស់សារធាតុញៀន...9

យេនឌ័រ និងភាពងាយរងគ្រោះ..9

ក្រុមបងធំ និងអត្តសញ្ញាណក្នុងសង្គម...10

វិធីសាស្រ្តស្រាវជ្រាវ...11

គំរូសំណាកស្រាវជ្រាវ..12

លក្ខខណ្ឌជ្រើសរើស...13

ការពិចារណាអំពីក្រុមសីលធម៌..13

ឧបករណ៍ស្រាវជ្រាវ...13

ការវិភាគទិន្នន័យ..14

លទ្ធផល...14

ព័ត៌មានប្រជាសាស្រ្ត...15

ការពាក់ព័ន្ធនៅតាមផ្លូវ..17

ការធ្វើចំណាកស្រុក...27

អំពើហិង្សាលើរាងកាយ..19

អំពើហិង្សាលើផ្លូវភេទ..22

អំពើហិង្សាលើផ្លូវអារម្មណ៍..26

សុខភាព...33

ការប្រើប្រាស់សារធាតុញៀន...55

ការពិភាក្សា..37

ការធ្វើចំណាកស្រុក...37

ការប្រើប្រាស់សារធាតុញៀន..42

អំពើហិង្សា...45

ការអប់រំអំពីផ្លូវភេទ...48

អនុសាសន៍...49

Bibliography..53

សេចក្តីផ្តើម

អស់រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ទីក្រុងប៉ោយប៉ែតបានក្លាយជាតំបន់មួយក្នុងប្រទេសកម្ពុជា ដែលមានកំណើនចំនួនមនុស្សរស់នៅ និងធ្វើការនៅតាមផ្លូវ គួរឲ្យកត់សម្គាល់។ កំណើននេះអាចកើតឡើងដោយសារតំបន់សេដ្ឋកិច្ច ពិសេស និងតំបន់ពាណិជ្ជកម្មសេរី ដែលស្ថិតនៅលើព្រំដែនប្រទេសកម្ពុជា និងប្រទេសថៃ។ នៅក្នុងតំបន់បែបនេះ រដ្ឋាភិបាលអនុញ្ញាតឲ្យមានច្បាប់ពាណិជ្ជកម្ម និងអាជីវកម្មពិសេស ដើម្បីជំរុញឲ្យមានអាជីវកម្ម និងការបង្កើតការងាររវាងប្រទេស និងប្រទេស (FIDA, 2008)។ ដូច្នេះវាបង្កើតឲ្យ មានបរិយាកាសសេដ្ឋកិច្ចដែលអំណោយផល សម្រាប់ការវិនិយោគទុន និងអាជីវកម្មសេរីឆ្លងដែនខ្នាតធំ។ នៅក្នុងទីក្រុងប៉ោយប៉ែត តំបន់នេះបានមានប្រជាប្រិយភាព សម្រាប់កាស៊ីណូ ភ្ញៀវទេសចរ និងអាជីវកម្មឆ្លងដែន និងបម្រើការជាច្រកចេញចូលព្រំដែនខ្មែរ-ថៃ។

ការសន្យាអំពីការងារ និងឱកាសសេដ្ឋកិច្ចផ្សេងទៀតនៅក្នុងតំបន់នេះ និងឆ្លងព្រំដែនទៅក្នុងប្រទេសថៃ បានធ្វើឲ្យប៉ោយប៉ែតជាទិសដៅមួយគួរឲ្យទាក់ទាញសម្រាប់កុមារ និងគ្រួសាររបស់ពួកគេ ឲ្យចេញពីតំបន់ដែលមានបញ្ហាលំបាកផ្នែកសេដ្ឋកិច្ចនៅជុំវិញប្រទេសកម្ពុជា ជាពិសេស ទាក់ទងនឹងខេត្តនានាដែលជាប់ព្រំប្រទល់ជាមួ យប្រទេសថៃ (បន្ទាយមានជ័យ បាត់ដំបង និងឧត្តរមានជ័យ) ដែលរបាយការណ៍បង្ហា ញថា មានកម្រិតនៃភាពក្រីក្រខ្ពស់បំផុតនៅក្នុងប្រទេស (USAID, 2011)។ ជាលទ្ធផល តំបន់នេះត្រូវបានមានឈ្មោះល្បីថាជាតំបន់ដែលមានចំណាកស្រុកគ្មាន សុវត្ថិភាព មានអំពើជួញដូរមនុស្ស និងទម្រង់ផ្សេងៗនៃអំពើកេងប្រវ័ញ្ចកុមារ ដែលផ្តល់គ្រោះថ្នាក់យ៉ាងខ្លាំងទៅដល់សុវត្ថិភាព ការលូតលាស់ និងសុខមាលភាពរបស់កុមារដែលរស់នៅ/ធ្វើការនៅតាមផ្លូវ ក្នុងតំបន់ព្រំដែន។

ទោះបីជាមានព័ត៌មានទាំងនេះក្តី ក៏នៅតែខ្វះព័ត៌មានបឋមអំពីតម្រូវការ និងភាពងាយរងគ្រោះរបស់ក្រុមកុមារទាំងនេះ ទាក់ទងនឹងការធ្វើចំណាកស្រុក និងអំពើហិង្សា។ ការស្រាវជ្រាវទៅលើបញ្ហានេះបានផ្តោតជាទូទៅ ទៅលើការសិក្សាអត្រាប្រេវ៉ាឡង់របស់គ្រួសារ ដែលជាញឹកញាប់ ការពិតគឺថា មានចំនួនកុមារងាយរងគ្រោះជាច្រើនដែលមិនបានរស់នៅជាមួយគ្រួសារ ហើយមិនបានចូលរៀនជាប់លាប់នោះទេ ហើយត្រូវអវត្តមានពីការស្រាវជ្រាវអំពីអត្រាប្រេវ៉ាឡង់ខ្នាតធំនេះ។ ដើម្បីឆ្លើយតបចំពោះបញ្ហានេះ យើងបានធ្វើការជាមួយបុគ្គលិកសង្គមកិច្ចដែលនៅមូលដ្ឋាន និងអ្នកឯកទេសផ្នែកការពារកុមារ ដើម្បីប្រមូលទិន្នន័យចម្បងពីកុមារដែលរស់នៅ និងធ្វើការតាមផ្លូវ តាមរយៈការសន្ទនាមួ យទល់នឹងមួយ។

ដូច្នេះ គម្រោងនេ ះមានទំហំតូចជាង។ គោលបំណងនៃគម្រោងនេះ គឺចង់អភិរក្សសំឡេងរបស់កុមារនីមួយៗ ដែលទទួលស្គាល់ថា ខ្លួនឯងពិតជា "ស្ថិតនៅលើព្រំដែន" តាមន័យចំ និងន័យប្រៀបធៀប។ ព្រំដែន អាចសំដៅទៅលើព្រំដែនភូមិសាស្ត្រជាក់ស្តែងរវាងប្រទេស និងប្រទេស ឬអាចសំដៅទៅលើនិមិត្តសញ្ញាព្រំដែន ដែលមានន័យថា កុមារទាំងនេះមិនត្រូវបានសហគមន៍ និងសង្គមទូទៅ យកចិត្តដាក់ខ្លាំងនោះទេ។ នៅពេលយើងរួមបញ្ចូលសម្តីរបស់ កុមារ

ទាំងនេះ យើងសង្ឃឹមថានឹងអាចផ្តល់នូវការវិភាគអំពីគំនិតយល់ឃើញ និងបទពិសោធន៍របស់ពួកគេនៅលើផ្លូវ តាមបែបគុណភាព ឲ្យកាន់តែស៊ីជម្រៅថែមទៀត។

យើងជឿថា លទ្ធផលដែលរកឃើញទាំងនេះមានប្រយោជន៍ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ទេ។ យើងត្រូវធ្វើកិច្ចការបន្តទៀត ដើម្បីស្វែងយល់អំពីតម្រូវការ និងភាពងាយរងគ្រោះរបស់ក្រុមកុមារទាំងនេះ ដែលជាញឹកញាប់ត្រូវបានលាក់កំបាំង ជាពិសេសនៅក្នុងតំបន់សហគមន៍អាស៊ានដែលកំពុងមានការអភិវឌ្ឍយ៉ាងខ្លាំង។ យើងមានបំណងចិត្តថា ព័ត៌មានបឋមខ្លីនេះនឹងជួយឲ្យមានការបង្កើតនូវគម្រោង និងគំនិតផ្តួចផ្តើមថ្មីៗ និងធ្វើជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចការស្រាវជ្រាវថ្មីៗ និងមានការលំបាក ទៅលើក្រុមមនុស្សដែលងាយរងគ្រោះ និង/ឬ ត្រូវបានមើលរំលងនៅក្នុងតំបន់សហគមន៍អាស៊ាន។

សង្ខេបរបាយការណ៍

តំបន់សេដ្ឋកិច្ចពិសេស និងពាណិជ្ជកម្មសេរី ដែលស្ថិតនៅលើព្រំដែនរវាងក្រុងប៉ោយប៉ែត ប្រទេសកម្ពុជា និងស្រុកអារញ្ញ ប្រទេសថៃ គឺជាតំបន់មួយដែលមានការកើនឡើងនៃចំនួនកុមាររស់នៅ និងធ្វើការនៅតាមផ្លូវ។ តំបន់នេះមានប្រជាប្រិយភាព ដោយសារមានកាស៊ីណូ ភ្ញៀវទេសចរ និងអាជីវកម្មរវាងប្រទេស និងប្រទេស និងធ្វើជាច្រកឆ្លងកាត់រវាងប្រទេសថៃ និងប្រទេសកម្ពុជា។ តំបន់នេះល្បីឈ្មោះដោយសារចំណាកស្រុកអសុវត្ថិភាព អំពើជួញដូរមនុស្ស និងទម្រង់ផ្សេងៗនៃអំពើកេងប្រវ័ញ្ច ដែលទាក់ទាញកុមារ និងគ្រួសារជាច្រើនមកពីតំបន់ ដែលមានបញ្ហាផ្នែកសេដ្ឋកិច្ច ជាហេតុធ្វើឲ្យពួកគេប្រឈមគ្រោះថ្នាក់ចំពោះសុវត្ថិភាព ការលូតលាស់រាងកាយ និងសុខមាលភាពរបស់ពួកគេ។ ទោះបីជាមានព័ត៌មានទាំងនេះក្តី ប៉ុន្តែនៅតែខ្វះព័ត៌មានបឋមអំពីតម្រូវការ និងភាពងាយរងគ្រោះរបស់ក្រុមកុមារទាំងនេះ។ ដើម្បីឆ្លើយតបចំពោះបញ្ហានេះ ការសិក្សានេះបានទាញយកទិន្នន័យចម្បងពីកុមារ ៨០% ដែលធ្វើការ និងរស់នៅតាមផ្លូវ តាមបណ្តោយព្រំដែនខ្មែរ-ថៃ រវាងតំបន់ប៉ោយប៉ែត និងស្រុកអារញ្ញ និងផ្តល់នូវការវិភាគបឋមអំ ពីតម្រូវការ ភាពងាយរងគ្រោះ និងភាពធាប់ជាសះស្បើយ។

ការសិក្សានេះប្រើវិធីសាស្ត្រគំរូសំណាកដែលមានគោលបំណង និងឯកសារយោងបន្តគ្នា ដើម្បីសិក្សាអំពីជីវិត និងបទពិសោធន៍របស់ក្មេងប្រុសចំនួន ៥៥នាក់ និងក្មេងស្រីចំនួន ២៥នាក់ ដែលកំពុងរស់នៅ និង/ឬ ធ្វើការនៅក្នុងតំបន់ព្រំដែនខ្មែរ-ថៃ។ បុគ្គលិកសង្គមកិច្ចនៅតំបន់នោះប្រើការសម្ភាសពាក់កណ្តាលរចនាសម្ព័ន្ធ ជាមួយកុមារ និងសួរសំណួរទៅលើប្រធានបទជាច្រើនអំពីជីវិត ការងារ បទពិសោធន៍ និងគំនិតយល់ឃើញរបស់កុមារនៅតាមផ្លូវ ដោយផ្តោតពិសេសទៅលើចំណាកស្រុកទៅប្រទេសថៃ ការប្រើសារធាតុញៀន និងបទពិសោធន៍អំពីទម្រង់ផ្សេងៗនៃអំពើហិង្សា។ ការសិក្សានេះផ្តោតពិសេសទៅលើមធ្យោបាយ និងភាពញឹកញាប់នៃការធ្វើការចំណាកស្រុក និងការងារឆ្លងដែនក្នុងចំណោមកុមារ និងឪពុកម្តាយរបស់ពួ កគេ ហើយការសិក្សានេះរកឃើញថា កុមារដែលចូលរួមសម្ភាសភាគច្រើនដែលឆ្លងដែនទៅប្រទេសថៃ គឺស្វែងរកឱកាសការងារធ្វើ។

កុមារដែលឆ្លងដែនទៅរកការងារធ្វើនៅក្នុងប្រទេសថៃ ត្រូវបានរកឃើញថា មានបញ្ហាប្រឈមកាន់តែខ្លាំងទៅនឹងទម្រង់ផ្សេងៗនៃអំពើហិង្សា រួមទាំង ការដែលត្រូវគេចាប់ខ្លួន និងការឃុំខ្លួន។ កុមារដែលធ្វើការនៅព្រំដែនទាំងសង ខាង លើកឡើងអំពីអត្រានៃអំពើហិង្សាខ្ពស់ផ្នែករាងកាយ ផ្លូវភេទ និងផ្លូវអារម្មណ៍ ដែលជាញឹកញាប់ទទួលរងនូវការរំលោភបំពានពីមនុស្សជាច្រើន រួមមាន ប៉ូលីស មិត្តភ័ក្ដ មនុស្សធំ មនុស្សដែលមិនដែលស្គាល់ និងក្រុមបងធំ។ អំពើហិង្សាផ្នែកផ្លូវភេទនៅតាមផ្លូវ ក៏ត្រូវបានលើកឡើងដោយកុមារជាង ១/៤ ហើយស្ទើរតែកើតឡើងទៅលើក្មេងប្រុស ៤ដងច្រើនជាងក្មេងស្រី។ ទោះបីជាយ៉ាងណាក៏ដោយ ទាំងក្មេងប្រុស និងក្មេងស្រី ហាក់បីដូចជាមិនយល់ថា អំពើហិង្សាផ្លូវភេទអាចជាគ្រោះថ្នាក់សម្រាប់ក្មេងប្រុសនោះទេ។ ការប្រើប្រាស់គ្រឿងញៀនក៏ត្រូវបានរកឃើញថាជាបញ្ហាដ៏ធំមួយក្នុងចំណោមក្មេងប្រុសដែលពាក់ព័ន្ធនៅតាមផ្លូវ ក្នុងក្រុងប៉ោយប៉ែតផងដែរ ហើយត្រូវបានរកឃើញថា មានការទាក់ទងសំខាន់ទៅនឹងផលប៉ះពាល់ជាអវិជ្ជមានទៅលើខុសភាព អំពើហិង្សាលើរាងកាយ ផ្លូវភេទ និងការអប់រំ។ ការប្រើប្រាស់គ្រឿងញៀនក៏ទាក់ទងនឹងការការទទួលរងនូវអំពើហិង្សាលើរាងកាយផងដែរ។

របាយការណ៍នេះគូសបង្ហាញអំពីតម្រូវការឲ្យមានការពិភាក្សា ដោយមានការយល់ដឹងទៅលើភាពងាយរងគ្រោះរបស់កុមារ និងយុវជនដែលនៅតាមផ្លូវ។ របាយការណ៍នេះមានគោលបំណងផ្ដល់នូវធនធានព័ត៌មានសម្រាប់ស្ថាប័នដែលផ្ដល់សេវាជំនួយសង្គម អ្នកបង្កើតគោលនយោបាយ អ្នកតស៊ូមតិអំពីកិច្ចការពារកុមារ និងអ្នកស្រាវជ្រាវកិច្ចការសង្គម ដែលធ្វើការជាមួយក្រុមកុមារទាំងនេះ នៅក្នុងមហាតំបន់ទាំងមូល។

ការពិនិត្យមើលបំណ្ណសារស្រាវជ្រាវ

ការកំណត់និយមន័យអំពីការពាក់ព័ន្ធនៅតាមផ្លូវ

យោងតាមអង្គការយូនីសេហ្វ កុមារនៅតាមផ្លូវគឺជាកុមារម្នាក់ដែលយក "ដងផ្លូវធ្វើជាលំនៅដ្ឋាន និង/ឬធ្វើជាប្រភពនៃការរកប្រាក់ចំណូល" (Williams, 1993)។ និយមន័យនេះក្ដោបអត្ថន័យនៃពាក្យ "ផ្លូវ" ក្នុងន័យទូលំទូលាយ ដែលមានន័យដូចជា ទីលំនៅដែលគ្មានមនុស្សរស់នៅ ដីដែលគេទុកចោល ជាដើម បន្ថែមពីលើអត្ថន័យនៃពាក្យ "ផ្លូវ" តាមន័យត្រង់ (1993)។ ជាទូទៅ កុមារនៅតាមផ្លូវត្រូវបានយល់ក្នុងន័យពីរដែលត្រួតគ្នា៖ កុមារធ្វើការនៅតាមផ្លូវ និងកុមាររស់នៅនៅលើផ្លូវ។ កុមារដែលនៅតាមផ្លូវគឺជាកុមារដែលធ្វើការនៅលើផ្លូវ ប៉ុន្តែជាទូ ទៅ ត្រឡប់ទៅផ្ទះវិញនៅពេលយប់ ដើម្បីគេង (Woan, et al., 2013)។ កុមារដែលរស់នៅលើផ្លូវ ជាទូទៅ កម្រ និងស្ទើរតែ មិនដែលត្រ ឡប់ទៅផ្ទះវិញទេ។ ជាទូទៅមានការទទួលស្គាល់ថា កុមារនៅតាមផ្លូវភាគច្រើននៅ ក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម ធ្វើការនៅតាមផ្លូវ មិនមែនរស់នៅតាមផ្លូវទេ (2013)។

ពាក្យ "កុមារនៅ តាមផ្លូវ" ហាក់បីដូចជាមានការពិបាកផ្ដល់និយមន័យ ព្រោះពាក្យនេះមានន័យទូលំទូ លាយ និង សំដៅទៅលើភាពចម្រុះនៃក្រុមមនុស្ស ដែលជាញឹកញាប់ ពួកគេមកពីស្ថានភាពខុសៗគ្នា។ តាមការក្រឡេកមើល ទៅលើការព្យាយាមកំណត់ និងចាត់ថ្នាក់ក្រុមកុមារទាំងនេះ គួរមានការទទួលស្គាល់ថា តថភាពសង្គមដែលស្ថិតនៅពី ក្រោយក្រុម

កុមារទាំងនេះ មានភាពផ្សេងៗពី គ្នា ដូច្នេះការផ្តល់និយមន័យទូទៅទៅលើបទពិសោធន៍របស់ក្រុមទាំង នេះ អាច បង្ហាញថាមានការរើសអើង (OHCHR, 2011) និងអាចបង្វែរការយកចិត្តទុ កដាក់ទៅលើកុមារដែលងាយ រងគ្រោះដទៃទៀត (Panter-Brick, 2002)។ និយមន័យថ្មីៗដែលត្រូវបានប្រើប្រាស់កាន់តែ ច្រើន មានដូចជាពាក្យ "សកម្មនៅតាមផ្លូវ" "ទាក់ទងនៅតាមដងផ្លូវ" ឬ "ពាក់ព័ន្ធនៅតាមផ្លូវ" និងសំដៅទៅ លើនិយមន័យទូលំទូលាយមួយសម្រាប់ "កុមារដែលយកចិញ្ចើមផ្លូវជាចំណុចទំនាក់ទំនង និងផ្លូវមានតួនាទីសំខាន់នៅក្នុងជីវិតរបស់ពួកគេ" (Thomas de Benitez, 2007: 9)។ សម្រាប់ គោលបំណងនៃការសិក្សានេះ អ្នកនិពន្ធបានជ្រើសរើសប្រើពាក្យ "ពាក់ព័ន្ធនៅ តាមផ្លូវ" ដើម្បីពិពណ៌នាអំពីកុមារដែលចូលរួមក្នុងការសិក្សានេះ។

កុមារដែលពាក់ព័ន្ធនៅតាមផ្លូវជាសកល

ទោះបីជាមិនមានព័ត៌មានច្បាស់អំពីចំនួនកុមារដែលពាក់ព័ន្ធនៅតាមផ្លូវក៏ដោយ ក៏ប៉ុន្តែចំនួនប៉ាន់ស្មានបច្ចុប្បន្នបង្ហាញថា កុមារទាំងនេះមានចំនួនរាប់លាននាក់ គឺជាចំនួនមួយដែលត្រូវបានជឿថានឹងមានការកើនឡើង ទៅតាមកំណើនប្រជាជន និងការកើនឡើងនៃចំណាកស្រុក និងនគរូបនីយកម្ម (UNICEF, 2012)។ ចំនួនប៉ាន់ស្មានទាំងនេះកំពុង ត្រូវបានពិភាក្សាដេញដោលយ៉ាងខ្លាំង ក៏ប៉ុន្តែចំនួនកុមារទាំងនេះតែងតែធ្វើដំណើររហូត ហើយជាញឹកញាប់ មិនមានបញ្ជីអត្រានុកុលដ្ឋានទេ និងស្ថិតនៅក្រៅរចនាសម្ព័ន្ធសង្គមជាផ្លូវការ ដែលធ្វើឲ្យការប្រមូលទិន្នន័យមានការលំបាក។

ភាពក្រីក្រត្រូវបានលើកឡើងជាកត្តាជំរុញមួយដែលធ្វើឲ្យកុមាររស់នៅ/ធ្វើការនៅតាមផ្លូវ។ ទោះបីជាយ៉ាងណាក៏ដោយ មូលហេតុពិតប្រាកដមានភាពស្មុគស្មាញខ្លាំងជាង និងមាននូវកត្តា "រុញច្រាន" និងកត្តា "ទាក់ទាញ"។ ចំពោះកត្តារុញច្រាន មានការបែកបាក់គ្រួសារដោយអំពើហិង្សាក្នុងគ្រួសារ ដែលជំរុញឲ្យកុមារ និងយុវជនរស់នៅ/ធ្វើការតាមផ្លូវ (Reale, 2008; Patricia, et al., 2011)។ នៅក្នុងករណីជាច្រើន ការចាកចេញពីបរិយាកាសគ្រួសារដែលមានអំពើហិង្សា ឬមិននឹងធឹង អាចជាទម្រង់មួយនៃសមត្ថភាពនៃការរៀនរស់នៅខ្លួនឯង និងមានភាពឯករាជ្យ (Veeran, 2004)។ "កត្តាទាក់ទាញ" ក៏អាចដើរតួនៅក្នុងកុមារ "ដែលជ្រើសរើស" រស់នៅ/ធ្វើការតាមផ្លូវ។ កត្តាទាំងនេះអាចរួមបញ្ចូលការស្វែងរកការផ្សងព្រេង ភាពរំភើបរីករាយ និងសេរីភាព និងការគេចចេញពីច្បាប់ទម្លាប់តឹងរឹង ឬការរំពឹងចង់បានពីគ្រួសារ (Butler, 2009)។

គុណសម្បត្តិធំមួយរបស់កុមារដែលពាក់ព័ន្ធនៅតាមផ្លូវ គឺជាសមត្ថភាពរបស់ពួកគេក្នុងការធ្វើការ និងរកប្រាក់ចំណូល។ កុមារនៅតាមដងផ្លូវភាគច្រើនធ្វើការងារសាមញ្ញជាច្រើន ដូចជា សុំទាន ជូតកញ្ចក់ឡាន រើសអេតចាយ ដើរលក់អីវ៉ាន់ ។ល។ ពេលខ្លះ កុមារនៅតាមផ្លូវអាចធ្វើការងារពីរបីផ្សេងគ្នាក្នុងមួយថ្ងៃ តាមតម្រូវការប្តូរវេនពីព្រឹក ទល់យប់ (Thomas de Benítez, 2011)។ ការងារប្រភេទនេះជាទូទៅមិនមានភាពជាប់លាប់ទេ ដោយសារប្រាក់ ចំណូលប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ដែលធ្វើឲ្យការរៀបផែនការអនាគតរបស់ពួកគេ មានការលំបាក។ យុវជនដែលនៅតាមផ្លូវជាច្រើនជាញឹកញាប់ប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ ដូចជា អំពើកេងប្រវ័ញ្ច និងត្រូវគេជួញដូរ ដែលបញ្ហាទាំងនេះត្រូវបានជំរុញដោយសារការខ្វះទំនាក់ទំនងជិតស្និទ្ធជាមួយគ្រួសារ និង/ឬ ដោយសារភាពនៅវ័យក្មេង។

កុមារដែលពាក់ព័ន្ធនៅតាមផ្លូវក្នុងតំបន់អាស៊ីអាគ្នេយ៍

កុមារនៅតាមផ្លូវភាគច្រើននៅលើពិភពលោក មាននៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងកណ្តាល ដូចជា កុមារដែលមកពីតំបន់អាស៊ីអាគ្នេយ៍។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចការស្រាវជ្រាវភាគច្រើនដែលធ្វើទៅលើកុមារ និងយុវជននៅតាមផ្លូវ ត្រូវបានធ្វើឡើងនៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ ដូចជា សហរដ្ឋអាមេរិច ប្រទេសអង់គ្លេស និងទីក្រុងនានានៅក្នុងទ្វីបអឺរ៉ុប (Woan, et al., 2013)។

កត្តាវប្បធម៌មួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ អាចបណ្តាលឲ្យកុមាររស់នៅ/ធ្វើការនៅតាមផ្លូវ ចំពោះកុមារនៅក្នុងគ្រួសារមួយចំនួន។ នៅក្នុងវប្បធម៌អាស៊ីអាគ្នេយ៍ភាគច្រើន កុមារធំៗមានកាតព្វកិច្ចក្នុងសង្គមដែលចូលរួមចំណែករកប្រាក់ចំណូលជួយគ្រួសាររបស់ពួកគេ។ ក្នុងចំណោមគ្រួសារដែលរស់នៅក្នុងភាពក្រីក្រ កុមារដែលធ្វើការ/រស់នៅតាមផ្លូវអាចនឹងមានច្រើន ហើយត្រូវបានសង្គមរំពឹងបែបនេះផងដែរ។ នៅក្នុងករណីខ្លះ សារសំខាន់នៃទំនួលខុសត្រូវរបស់គ្រួសារ និងការបំពេញកាតព្វកិច្ចមើលថែឪពុកម្តាយ និងបងប្អូន ក៏បណ្តាលឲ្យកុមារធ្វើការសម្រេចចិត្តដោយខ្លួនឯងក្នុងការធ្វើចំណាកស្រុកដើម្បីស្វែងរកឱកាសការងារផងដែរ (Beazley, 2015)។ នៅក្នុងប្រទេសកម្ពុជា វាពិតជាពិបាកក្នុងការពិភាក្សាឲ្យបានគ្រប់គ្រាន់អំពីកុមារដែលនៅតាមផ្លូវ ប្រសិនបើមិនរួមបញ្ចូលអំពីបញ្ហាចំណាកស្រុករបស់កុមារផងដែរនោះទេ។ ជាទូទៅ កុមារតាមផ្លូវ រស់នៅ/ធ្វើការនៅក្នុងតំបន់ទីក្រុង ព្រោះពួកគេធ្វើដំណើរពីតាមបណ្តាខេត្ត ដោយសង្ឃឹមថានឹងស្វែងរកឱកាសធ្វើការ និងរកប្រាក់ចំណូលបានប្រសើរ (street children network/SNAPSHOT, 2012)។ ជាពិសេស ខេត្តប្រទេសកម្ពុជាដែលជាប់ព្រំប្រទល់ជាមួយប្រទេសថៃ (ខេត្តបន្ទាយមានជ័យ បាត់ដំបង និងឧត្តរមានជ័យ) ត្រូវបានលើកឡើងថា មានកម្រិតនៃភាពក្រីក្រខ្ពស់បំផុតនៅក្នុងប្រទេស។ ដោយសារខេត្តទាំងនេះនៅជាប់ព្រំដែន ដូច្នេះវាមានផលប៉ះពាល់ដោយផ្ទាល់ទៅលើអត្រាចំណាកស្រុកខ្ពស់ សម្រាប់តំបន់ នេះ ក៏ដូចជាមានអត្រាបោះបង់ចោលការសិក្សាផងដែរ ដែលត្រូវបានរកឃើញថា មានកម្រិតខ្ពស់បំផុតនៅក្នុងប្រទេស (USAID, 2011)។ នៅក្នុងភូមិមួយចំនួននៅក្នុងតំបន់នេះ គ្រួសារចំនួន ៧៨% មានសមាជិកយ៉ាងហោចណាស់ម្នាក់ ដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃ (ADIC, 2003)។

តំបន់ប៉ោយប៉ែត និងបរិបទសេដ្ឋកិច្ចសង្គម

ប៉ោយប៉ែតមានទីតាំងស្ថិតនៅប៉ែកពាយព្យនៃប្រទេសកម្ពុជា និងដើរតួជាច្រកឆ្លងដែនដីគោកដ៏សំខាន់ពីប្រទេស កម្ពុជាទៅប្រទេសថៃ។ ការសិក្សាប្រជាសាស្ត្រថ្មីមួយ ដែលប្រើវិធីសាស្ត្រស្រាវជ្រាវ "ចាប់-ព្រលែង-ចាប់" (capture-recapture research) ដែលប៉ាន់ស្មានថា មានកុមារចំនួន ៦៣៦នាក់ចន្លោះអាយុ ១៣ឆ្នាំ និង ១៧ឆ្នាំ ដែល គេងនៅតាមផ្លូវក្នុងទីក្រុងប៉ោយប៉ែត (Stark, et al., 2017) ដែលកុមារជាច្រើនរស់នៅ/ធ្វើការនៅតាមផ្លូវ ប៉ុន្តែត្រឡប់ទៅផ្ទះ

វិញជាប្រចាំ ឬមិនជាប្រចាំ។ ដោយសារទីក្រុងប៉ោយប៉ែតមានភាពងាយស្រួលឆ្លងដែនទៅប្រទេសថៃ ដូច្នេះទីក្រុងនេះក្លាយជាទិសដៅដ៏សំខាន់មួយសម្រាប់គ្រួសារជនជាតិកម្ពុជា និងកូនរបស់ពួកគេ ដែលមានបញ្ហាសេដ្ឋកិច្ច ដោយផ្តល់សេចក្តីសង្ឃឹមក្នុងការរកប្រាក់ចំណូលពីអាជីវកម្មឆ្លងដែនដែលកំពុងតែលូតលាស់ រួមជាមួយសណ្ឋាគារ និងកាស៊ីណូនៅក្នុងតំបន់ព្រំដែនខ្មែរ-ថៃ ផងដែរ (Damnok-Toek, 2013)។ ទោះបីជាមានការយល់ឃើញបែបនេះក៏ដោយ ក៏ប៉ុន្តែឱកាសនៃការទទួលបានការងារធ្វើសម្រាប់ពលករដែលគ្មានជំនាញ មានតិចតួចណាស់ ដែលជាហេតុធ្វើឲ្យជនចំណាកស្រុកជាច្រើនស្ថិតនៅក្នុងស្ថានភាពសេដ្ឋកិច្ចមិននឹងធឹង (2013)។ នៅក្នុងតំបន់ចន្លោះព្រំដែនប្រទេសកម្ពុជា និងប្រទេសថៃ គឺជាតំបន់សេដ្ឋកិច្ចសេរីពិសេស (Special Economic Free Trade Zone - FTZ) ដែលជាតំបន់មួយដែលរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃអនុញ្ញាតឲ្យមានច្បាប់ពាណិជ្ជកម្មពិសេស ដើម្បីជំរុញអាជីវកម្ម និងពាណិជ្ជកម្ម។ តំបន់សេដ្ឋកិច្ចទាំងនេះបានកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីលើក កម្ពស់កំណើនសេដ្ឋកិច្ច បង្កើនការប្រកួតប្រជែងឧស្សាហកម្ម និងដើម្បីទាក់ទាញវិនិយោគបរទេស (FIAS, 2008)។ FTZ ដែលស្ថិតនៅចន្លោះប្រទេសកម្ពុជា និងប្រទេសថៃបានក្លាយជាកន្លែងប្រជាប្រិយភាពមួយ សម្រាប់កាស៊ីណូ ភ្ញៀវទេសចរណ៍ និងពាណិជ្ជកម្ម រវាងប្រទេសទាំងពីរ និងបានទាក់ទាញកុមារ និងគ្រួសារជាច្រើនដែលមកពីតំបន់ ដែលមានបញ្ហា ផ្នែកសេដ្ឋកិច្ច ធ្វើចំណាកស្រុកស្វែងរកភាពប្រសើរឡើងផ្នែកសេដ្ឋកិច្ច។ ទោះបីជាមានសេចក្តី សង្ឃឹមផ្នែកសេដ្ឋកិច្ច ដោយសារតំបន់ទាំងនេះក៏ដោយក៏ FTZ នៅតែត្រូវបានរិះគន់ដោយសារផលប៉ះពាល់អវិជ្ជមាន ផ្នែកសង្គម និងសេដ្ឋកិច្ច ដោយសារទម្រង់ផ្សេងៗនៃអំពើកេងប្រវ័ញ្ចពលកម្ម និងលក្ខខណ្ឌការងារមិ នល្អ (2008) រួមទាំងការចូលរួមចំណែកដែលគួរឲ្យកត់សម្គាល់ទៅលើកំណើនអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលេ ើកុមារដែលរស់នៅ និងធ្វើការនៅក្នុងតំបន់ទាំងនេះ (ECPAT, 2016)។

ដោយសារតែសហគមន៍អង្គការធ្វើការផ្នែកអភិវឌ្ឍន៍ ចាប់ផ្តើមយល់ដឹងកាន់តែច្រើនអំពីភាពងាយរងគ្រោះរបស់កុមារទៅនឹងអំពើហិង្សា និងអំពើកេងប្រវ័ញ្ចនៅក្នុងតំបន់មេគង្គ ដូច្នេះទើបមាននូវការស្រាវជ្រាវជាច្រើន ដែល សិក្សាទៅលើបទពិសោធន៍ទទួលរងអំពើហិង្សារបស់កុមារ នៅតាមផ្ទះ និងសាលារៀន ដូចជា ការស្រាវជ្រាវរបស់អង្គការយូនីសេហ្វអំពីអំពើហិង្សាទៅលើកុមារក្នុងប្រទេសកម្ពុជា (VAC) (2013; 2004)។ នៅក្នុងការស្រាវជ្រាវថ្មីបំផុតអំពីអំពើហិង្សាទៅលើកុមារ ភេទប្រុស និងភេទស្រីជាងពាក់កណ្តាលដែលមានអាយុចន្លោះ ១៨ និង ២៤ឆ្នាំ បានលើកឡើងថា ពួកគេជួបអំពើហិង្សាផ្នែករាងកាយ ហើយភេទស្រីចំនួន ៤% និងភេទប្រុស ៥% លើកឡើងអំពីការទទួលរងអំពើហិង្សាផ្លូវភេទមុនពេលពួកគេមានអាយុ ១៨ឆ្នាំ (UNICEF, 2013)។ ទោះបីជាការសិក្សាបែបនេះអាចជាព័ត៌មានដែលមានប្រយោជន៍ក៏ដោយ ប៉ុន្តែភាគច្រើនការសិក្សាទាំងនេះច្រើនតែធ្វើការស្ទង់មតិ ឬសម្ភាសជាមួយសិស្សសាលាតែប៉ុណ្ណោះ ដូច្នេះអាចនឹងរំលងកុមារដែលនៅក្រៅសាលារៀន កុមារដែលមិនបានចុះឈ្មោះ ឬកុមារដែលមិនរស់នៅតាមផ្ទះ។ ថ្មីៗនេះ មានការសិក្សាទៅលើបទពិសោធន៍របស់ក្រុមកុមារទាំងនេះ នៅក្នុងប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសភីលីពីន ដែលបានរកឃើញថា អត្រានៃអំពើហិង្សាលើរាងកាយ ផ្លូវភេទ និងផ្លូវអារម្មណ៍ មានកម្រិតខ្ពស់ជាងការរកឃើញនៅក្នុងការស្រាវជ្រាវលើប្រជាសាស្ត្រខ្នាតធំ។ ការស្រាវជ្រាវមួយដែលធ្វើការសិក្សាទៅលើកុមារតាមផ្លូវក្នុងក្រុងកំពង់សោម

(2014) បានរកឃើញថា ក្មេងប្រុសនៅតាមផ្លូវចំនួន ៣៨% មានបទពិសោធន៍នៃអំពើហិង្សាផ្លូវភេទ នៅតាមផ្លូវ (Davis & Miles, 2014) ស្ទើរតែមានចំនួន ៣៣% ខ្ពស់ជាងការរកឃើញនៅក្នុងការស្រាវជ្រាវប្រជាសាស្ត្រ។

អំពើកេងប្រវ័ញ្ចពលកម្ម

ទីក្រុងអារញ្ញរបស់ប្រទេសថៃ (ជាប់នឹងទីក្រុងប៉ោយប៉ែត) ដែលធ្វើជាច្រកចេញចូលរបស់មនុស្សវ័យជំទង់ជនជាតិខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើ (Capaldi, 2014)។ ជាញឹកញាប់ ក្រុមមនុស្សទាំងនេះ តែងតែធ្វើការនៅក្នុងឧស្សាហកម្មនេសាទ និងផ្នែកកសិកម្មរបស់ប្រទេសថៃ ឬឧស្សាហកម្មសំណង់ដែលកំពុងលូតលាស់យ៉ាងខ្លាំង ដើម្បីជួយផ្គត់ផ្គង់ដល់សមាជិកគ្រួសាររបស់ពួកគេ ដែលកំពុងរស់នៅក្នុងតាមបណ្តាខេត្តប្រទេសកម្ពុជានៅឡើយ (2014)។ នៅក្នុងការស្រាវជ្រាវមួយដែលសិក្សាទៅលើកុមារ ៧៦នាក់ដែលធ្វើចំណាកស្រុកទៅប្រទេសថៃ (ជនជាតិខ្មែរ និងជនជាតិភូមា) បានរកឃើញថា កុមារជនជាតិខ្មែរទាំងអស់ដែលធ្វើចំណាកស្រុក បានធ្វើដំណើរចូលទៅក្នុងប្រទេសថៃ ដោយគ្មានឯកសារធ្វើការងារស្របច្បាប់ (2014)។ បញ្ហាមួយចំនួនដែ លប្រជាជនចំណាកស្រុកបានរាយការណ៍គឺ លក្ខខណ្ឌការងារពិបាក មិនបានទទួលប្រា ក់ឈ្នួលពេញ ទទួលអំពើហិង្សាលើរាងកាយ និងធ្វើការលើសកម្លាំង (York, 2013)។ បន្ថែមពីលើនេះទេ ៀត ការខ្វះឯកសារស្របច្បាប់ត្រឹមត្រូវអាចនឹងធ្វើឲ្យពលករចំណាកស្រុកទាំងនេះកាន់តែរងគ្រោះថែមទៀត ព្រោះក្រុមទាំងនេះ មិនសូវចង់ស្វែងរកជំនួយ នៅក្នុងករណីដែលពួកគេត្រូវបានគេធ្វើបាបនោះទេ (Walsh, 2011)។ នៅក្នុងការវិភាគមួយដែលទាក់ទងនឹងទិន្នន័យគំរូសំណាកបន្តគ្នាជាប្រព័ន្ធមួយអំពីជនរងគ្រោះដោយអំពើជួញដូរ នៅក្នុងមហាអនុតំបន់មេគង្គ ដែលបានប្រមូលមកទល់បច្ចុប្បន្ននេះ បានរកឃើញថា ១៤.២% នៃគំរូសំណាកនេះមានអាយុក្រោម ១៨ និង ៦.១% ស្ថិតនៅក្រោមអាយុ ១៤ឆ្នាំ (Pocock, et al., 2016)។ ក្មេងប្រុសៗនៅក្នុងគំរូសំណាកនេះត្រូវបានរកឃើញថាមានភាព ងាយរងគ្រោះដោយអំពើកេងប្រវ័ញ្ចពលកម្ម ដែលមានសមាសភាពភេទប្រុស ២/៣ នៃពលករត្រូវបានជួញដូរ និងត្រូវបានបង្ខំ។ ពលករទាំងនេះភាគច្រើនជួបនូវអំពើរំលោភបំពាន និងការងារដែលមានគ្រោះថ្នាក់ខ្លាំង (2016)។

អំពើកេងប្រវ័ញ្ចផ្លូវភេទ

ការផ្តល់សេវាផ្លូវភេទដើម្បីដោះដូរជាមួយលុយ ឬសំណងផ្សេងទៀត អាចក្លាយជាមធ្យោបាយចាំបាច់ដើម្បីរស់រានមានជីវិត ចំពោះកុមារដែលនៅតាមផ្លូវជាច្រើន (Marshall, et al., 2009)។ ទោះបីជាមិនមានការស្រាវជ្រាវឲ្យបានគ្រប់គ្រាន់ក៏ដោយ ក៏ប៉ុន្តែយើងមើលឃើញថា តំបន់អាស៊ីគឺជាតំបន់មួយដែលមានអត្រានៃអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារខ្ពស់បំផុត នៅលើពិភពលោក (UNICEF, 2001; Ward, 2004)។ វាគឺជាបញ្ហាមួយដែលទាក់ទងភាគច្រើនទៅនឹងការធ្វើដំណើរ និងទេសចរណ៍។ ទំនាក់ទំនងនៃអំពើកេ ងប្រវ័ញ្ចផ្លូវភេទជាមួយនឹងការធ្វើដំណើរ និងទេសចរណ៍កើតមានឡើងជាពិសេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ព្រោះវាគឺជាតំបន់មួយដែលល្បីសុះសាយអំពីបញ្ហានេះនៅជុំវិញពិភពលោកជាលើកដំបូង (ECPAT, 2016)។ ទោះបីជាប្រទេសកម្ពុជា និងប្រទេសថៃត្រូវបានយល់ថាជាទិសដៅសំខាន់របស់ជនល្មើសក៏ដោយ ក៏ប៉ុន្តែជាញឹកញាប់ ជនល្មើសក្នុងស្រុកត្រូវបានមើលរំលង និងមិនមានចំណាត់ការពីថ្នាក់ជាតិ

និងអន្តរជាតិប្រឆាំងនឹងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារនោះទេ (ECPAT, 2016)។ ការសិក្សាបឋមថ្មីៗទៅលើកុមារនៅតាមផ្លូវក្នុងក្រុងកំពង់សោម (ខេត្តព្រះសីហនុ) ប្រទេសកម្ពុជា រកឃើញថា ក្មេងប្រុស ១៨% និងក្មេង ស្រី ១៤% លើកឡើងថា ពួកគេបានផ្តល់សេវាផ្លូវភេទ ដើម្បីដោះដូរជាមួយលុយ ម្ហូបអាហារ ឬតាមទម្រង់នៃការដោះដូរផ្សេងទៀត (Davis & Miles, 2014; 2017)។ នៅក្នុងការសិក្សាស្រដៀងគ្នាដែរនៅក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន បានរកឃើញថា ក្មេងប្រុសជាង ១/៤ បានលាតត្រដាងអំពីអំពើកេងប្រវ័ញ្ចផ្លូវភេទដូចគ្នា (Davis & Miles, 2015)។

នៅក្នុងប្រទេសកម្ពុជា អំពើកេងប្រវ័ញ្ចធ្វើអាជីវកម្មផ្លូវភេទលើកុមារត្រូវបានស្វែងយល់ថា កើតឡើងតាមទម្រង់មួយ នៃទម្រង់ទាំងពីរ។ ទម្រង់ទីមួយគឺអំពើកេងប្រវ័ញ្ចផ្លូវនៅក្នុងគ្រឹះស្ថាន ដែលជាញឹកញាប់កើតឡើងនៅក្នុងផ្ទះបន សួនស្រាបៀរ ក្លិបខារ៉ាអូខេ និងហាងម៉ាស្សា (APLE, 2006)។ ចំនួននៃក្មេងស្រីដែលរងគ្រោះមានការធ្លាក់ចុះយ៉ាង ខ្លាំងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ លើកលែងតែនៅក្នុងហាងខារ៉ាអូខេដែល ៩% គឺជាស្រ្តីក្រោមអាយុ ១៨ឆ្នាំ (IJM, 2013)។ទីពីរ អំពើកេងប្រវ័ញ្ចផ្លូវភេទនៅតាមផ្លូវ ឬអំពើកេងប្រវ័ញ្ចផ្លូវភេទឱកាសនិយម ជាញឹកញាប់ ត្រូវបានប្រព្រឹត្តឡើងដោយជនល្មើសផ្លូវភេទ ឬអន្តរការី ដែលទៅរកកុមារនៅតាមផ្លូវដោយផ្ទាល់ ឬនៅតំបន់សាធារណៈផេ្សងទៀតក្នុងគោលបំណងចាប់ផ្តើមទំនាក់ទំនងជាមួយកុមារ ដែលឈានទៅដល់ការរំលោភបំពានផ្លូវភេទ (2006)។ ប្រភេទនៃអំពើកេងប្រវ័ញ្ចផ្លូវទីពីរនេះ ជាញឹកញាប់មានការលំបាកក្នុងការតាមដាន ដោយសារកុមារ និងទីតាំងនៃការរំលោភបំពានដែលកើតឡើង តែងតែប្រែប្រួល។

ការប្រើប្រាស់សារធាតុញៀន

ការប្រើប្រាស់គ្រឿងញៀន និងការប្រើគ្រឿងស្រវឹងបង្កើននូវហានិភ័យដែលកុមារជួបនៅតាមផ្លូវ ដោយសារពួកគេងាយប្រឡូកក្នុងសកម្មភាពដែលគ្រោះថ្នាក់ (NIDA, 2003)។ កត្តាគ្រោះថ្នាក់ទាំងនេះត្រូវកើនឡើងថែមទៀតដោយសារកង្វះព័ត៌មានអំពីការរួមភេទដោយសុវត្ថិភាព និងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងពេលប្រើសារធាតុញៀន បង្កើននូវការប្រឈមឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (2013)។ នៅក្នុងការត្រួតពិនិត្យជាប្រព័ន្ធទៅលើឯកសារស្រាវជ្រាវចំនួន ១០៨ឯកសារ អំពីកុមារនៅតាមផ្លូវនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងកណ្តាល រកឃើញថា ការប្រើប្រាស់សារធាតុញៀនគឺជាបញ្ហាដែលកើតឡើងច្រើនបំផុត ដែលត្រូវបានលើកមកពិភាក្សា ហើយមានអត្រានៃការប្រើប្រាស់ចាប់ពី ៣៥% ទៅដល់ ១០០% (Moan, et al., 2013b)។ កត្តារួមទាក់ទងនឹងការប្រើប្រាស់ សារធាតុ ញៀននៅក្នុងចំណោមកុមារដែលនៅតាមផ្លូវគឺ ជាភេទប្រុស មានអាយុច្រើន មិនសូវមានទំនាក់ទំនងជាមួយគ្រួសារ មានការធ្លាក់ទឹកចិត្ត និងមានបទពិសោធន៍ធ្លាប់ទទួលរងគ្រោះការរំលោភបំពាន (2013b)។

ការស្រាវជ្រាវក៏បង្ហាញផងដែរអំពីទំនាក់ទំនងដ៏គួរឲ្យកត់សម្គាល់នៃការប្រើប្រាស់គ្រឿងញៀន និងការរំលោភបំពានផ្លូវភេទ។ ការរំលោភបំពានផ្លូវភេទកាលពីកុមារភាពមានផលប៉ះពាល់ខ្លាំង និងអាចបង្កឲ្យមានជំងឺបាក់ស្បាត បង្កើនភាពថប់បារម្ភ ការធ្លាក់ទឹកចិត្ត ការមានដៃគូផ្លូវ ភេទច្រើន ឬការកើនឡើងនៃអំពើអត្ត ឃាត (Paolucci, Genuis & Violato, 2001)។ នៅក្នុងបរិបទនេះ ជនដែលរួចផុតពីអំពើជួញដូរមនុស្ស បានត្រឡប់ទៅរកការប្រើប្រាស់គ្រឿង

ញៀនវិញ ជារបៀបក្នុងការដោះស្រាយភាពតានតឹង ឬជាទម្រង់មួយនៃ "ការគេចវេសផ្លូវអារម្មណ៍" ដើម្បីរម្ងាប់អារម្មណ៍ឈឺចាប់របស់ពួកគេ (Polusny and Follette, 1995 cited in Lalor & McElvaney, 2010, p.13)។ ទំនាក់ទំនងនេះត្រូវបានរកឃើញនៅក្នុងការស្រាវជ្រាវលើកមុន ជាមួយកុមារនៅតាមផ្លូវ ក្នុងទីក្រុងឈៀងម៉ៃ (Davis, Fiss, & Miles, 2016)។ នៅក្នុងការសិក្សា នេះ មានយុវជនរស់នៅតាមផ្លូវមួយចំនួនធំ ត្រូវបានរកឃើញថា ត្រឡប់ទៅ ប្រើគ្រឿងញៀនវិញ នៅពេលប្រៀបធៀបជាមួយយុវជនដែលមិនរស់នៅតាមផ្លូវ។ ស្ថានភាពលំបាកនៃ ការរស់នៅតាមផ្លូវ ការប្រឈមញឹកញាប់ និងជាប្រចាំទៅនឹងស្ថានភាពស្ត្រេស សម្ពាធនៅក្នុងការងារធ្ងន់ៗ កង្វះជំនួយផ្លូវអារម្មណ៍ និងកង្វះនៃអារម្មណ៍នៃភាពកក់ក្ដៅ រួមជាមួយជីវិតរស់នៅតាមផ្លូវ និងក្រុមកុមារដែលប្រើគ្រឿងញៀន ទាំងអស់នេះគឺជាកត្តាជំរុញឲ្យមានអត្រានៃការប្រើប្រាស់គ្រឿងញៀនខ្ពស់ នៅពេលរស់នៅតាមផ្លូវ (2016)។

យេនឌ័រ និងភាពងាយរងគ្រោះ

ក្មេងប្រុសត្រូវបានរកឃើញថាមានចំនួនច្រើនជាក្មេងស្រី នៅក្នុងចំណោមកុមារនៅតាមផ្លូវ ជាពិសេសនៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍ ដែលមានកុមារធ្វើការនៅតាមផ្លូវជាង ៧០% ជាភេទប្រុស (WHO, 2000)។ ការសិក្សាអត្រា ប្រេវ៉ាឡង់ថ្មីៗអំពីបទពិសោធន៍នៃអំពើហិង្សាពីកុមារភាព នៅក្នុងប្រទេសកម្ពុជា និងហ្វីលីពីន (រួមមាន ទម្រង់ អំពើហិង្សាផ្នែកផ្លូវភេទ ផ្លូវអារម្ម ណ៍ និងអំពើហិង្សាផ្នែករាងកាយ) បានបង្ហាញថា ក្មេងប្រុសងាយរងគ្រោះដោយអំពើហិង្សាតាមទម្រង់មួយចំនួន ច្រើនជាងក្មេងស្រី (VAC-Cambodia, 2013; VAC-Philippines, 2016)។ បន្ថែមពីលើនេះទៀត ការសិក្សាតាមបែបគុណភាពនៅក្នុងតំបន់ដែលបានរកឃើញថា ក្មេងប្រុសដែលនៅតាមផ្លូវស្ទើរតែងាយទទួលរងគ្រោះដោយអំពើហិង្សាផ្លូវភេទ ច្រើនជាងក្មេងស្រីដែលនៅតាមផ្លូវដូចគ្នា (Davis et al, 2016; Davis, Fiss, & Miles, 2016)។ បន្ថែមពីលើនេះទៀត ក្មេងប្រុសត្រូវបានស្គាល់ថាអាចបង្ហាញទំនុកចិត្តខ្ពស់លើខ្លួនឯង មានអាក្បកិរិយាប្រថុយប្រថាន និងបុគ្គលិកលក្ខណៈបែបរស់រាយ នៅក្នុងប្រទេសជាច្រើន ដែលជាហេតុធ្វើឲ្យពួកគេងាយប្រ ឈមនឹងការធ្វើចំណាកស្រុកអសុវត្ថិភាព និងប្រឈមនឹងអំពើហិង្សា (Capaldi, 2014)។

ការពិនិត្យមើលអំពើហិង្សាផ្លូវភេទ ការរំលោភបំពានផ្លូវភេទលើក្មេងប្រុស ជាញឹកញាប់ត្រូវបានមើលរំលងនៅក្នុងគ្រួសារ និងសហគមន៍នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយសារតែវប្បធម៌ប្រ ពៃណី ដែលហាក់បីដូចជាបង្ហាញថា ក្មេងប្រុសមិនប្រឈមនឹងការរំលោភបំពាន ឬអំពើកេងប្រវ័ញ្ចទេ (Frederick, 2010)។ ក្មេងប្រុសតែងតែត្រូវបានគេសន្មតថា អាចការពារខ្លួនឯងបាន ហើយការរំលោភបំពានផ្លូវភេទទៅលើក្មេងប្រុស ជាញឹ កញាប់ត្រូវបានមើលរំលង ឬត្រូវបានបដិសេធ។ ការស្រាវជ្រាវទៅលើអំពើហិង្សាផ្លូវភេទទៅលើក្មេងប្រុសនៅក្នុងបរិបទអន្តរកាល ឆ្លុះបញ្ចាំងនូវតថភាពស្រដៀងគ្នា ដែលនៅពេលជនរងគ្រោះភេទប្រុសរាយការណ៍អំពីអំពើហិង្សាផ្លូវភេទ ការរាយការណ៍នេ ះមិនត្រូវបានយកចិត្តទុកដាក់ទេ ហើយជាញឹកញាប់ តែងតែកំណត់និយមន័យអំពើហិង្សាផ្លូវភេទថាជាទម្រង់អំពើហិង្សាលើរាងកាយទៅវិញ ទោះបីជាការរំលោភបំពានស្រដៀងគ្នានេះប្រព្រឹត្តទៅលើស្ត្រី ត្រូវចាត់ទុកថាជាការរំលោភបំពានផ្លូវភេទក៏ដោយ (ICJT, 2015)។ ការសន្មតអំពីភាពមាំមួនរបស់ភេទប្រុស អាចនឹងបញ្ជាក់អំពីទស្សនៈថា បុរសមាន "ភាពខ្លាំង" ពីធម្មជាតិ ដូច្នេះមានភាពរឹងមាំផ្នែកផ្លូវចិត្ត អាចការពារខ្លួនឯងបាន និងអាចជាសះ ស្បើយពីការប៉ះទង្គិចលឿនជាងក្មេងស្រី

វ៉ាយជីទង់ (2010:7)។ ជាលទ្ធផល គ្រួសារ និងសហគមន៍ ជាញឹកញាប់ មិនសូវប្រុងប្រយ័ត្នជាមួយក្មេងប្រុសនោះទេ (2010) ហើយករណី នៃអំពើរំលោភបំពានទៅលើក្មេងប្រុស ក៏មិនត្រូវបានរាយការណ៍ផងដែរ (ECPAT, 2010; Holmes, et al., 1997)។

បន្ថែមពីលើនេះទៀត ការសិក្សាមួយក្នុងឆ្នាំ ២០០៣ ដែលវិភាគទៅលើអត្រាដ៏ខ្ពស់នៃអំពើអត្តឃាត និងការស្លាប់មុនអាយុ ក្នុងចំណោមមនុស្សប្រុស បានរកមើលឃើញថា ទស្សនៈពីដើមអំពីភាពជាបុរសគឺជាកត្តាគ្រោះថ្នាក់មួយ (Möller-Leimkühler, 2003)។ តថភាពភាពនេះត្រូវបានបញ្ជាក់នៅក្នុងរបាយការណ៍មួយក្នុងឆ្នាំ ២០០៧ របស់អង្គការសុខភាពពិភពលោកដែលរកឃើញថា មនុស្សប្រុសដែលកំពុងមានអសន្តិសុខផ្នែកអាហារបរិភោគ មានកម្រិតស្ត្រេសនៃការងារខ្ពស់ មានភាពអត់ការងារធ្វើ ឬមានការរួមភេទជាមួយបុរសដទៃទៀត ងាយទទួលរងនូវការធ្លាក់ទឹកចិត្តខ្លាំង ប្រសិនបើប្រៀបធៀបជាមួយនឹងភេទស្រី ដែលរបាយការណ៍នេះចង្អុលបង្ហាញជាក់ច្បាស់អំពីកត្តាគ្រោះថ្នាក់ដែលប៉ះពាល់ដល់សុខភាពរបស់បុរស (WHO, 2007)។

ក្រុមបងធំ និងអត្តសញ្ញាណក្នុងសង្គម

កុមារនៅតាមផ្លូវក៏អាចជាគោលដៅងាយស្រួលសម្រាប់ក្រុមបងធំ និងក្រុមដែលមានអំពើហិង្សា។ ទោះបីជាមានគ្រួសារក៏ពិតមែន ក៏ប៉ុន្តែជាញឹកញាប់ ទំនាក់ទំនងតែងតែមានការប្រែប្រួល និងចលំត ការព្យាយាមបង្កើតរចនាសម្ព័ន្ធ គ្រួសារសារជាថ្មី និងការបង្កើតចំណងសង្គមរឹងមាំជាមួយមិត្តភ័ក្តនៅតាមផ្លូវ ដែលជំនួសឲ្យគ្រួសារ គឺជារឿងដែលកើតឡើងជាញឹកញាប់។ ការបង្កើតគ្រួសារជំនួសនេះអាចធ្វើឡើង តាមរយៈការចូលរួមជាមួយក្រុមបងធំ ការរស់នៅក្នុងក្រុម ឬការបង្កើតមិត្តភាព តាមរយៈបណ្តាញជាមួយកុមារនៅតាមផ្លូវដទៃទៀត។ ការមានទំនាក់ទំនងជាមួយក្រុម ជួយឲ្យយុវជននៅតាមផ្លូវមិនគ្រាន់តែទទួលបានការទទួលស្គាល់ និងបំពេញតម្រូវការនៅក្នុងទំនាក់ទំនងប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយឲ្យពួកគេស្វែងរកសន្តិសុខ ការការពារលើរូបកាយ និងជំនួយផ្លូវអារម្មណ៍ផងដែរ (UMP, 2000)។

ឧទាហរណ៍៖ កុមារនៅតាមផ្លូវក្នុងទីក្រុងយ៉ូកយ៉ាតា ប្រទេសឥណ្ឌូនេស៊ី (Yogyarta, Indonesia) បានបង្កើតវប្បធម៌មួយ ដែលមានរចនាសម្ព័ន្ធ បទដ្ឋាន និងគុណតម្លៃជាផ្លូវការ ដែលហៅថា "ទីកយ៉ាន់" “Tikyan”។ វប្បធម៌របស់ក្រុមនេះរួមមានក្រមសីលធម៌នៅក្នុងជីវិត ដូចជា ឋានុក្រមនៅក្នុងកន្លែងធ្វើ ការឆ្លាក់រូបនៅលើរាងកាយ និងការប្រើប្រាស់គ្រឿងញៀន ព្រមទាំង សម្លៀកបំពាក់ ឥរិយាបថ និងភាសារួមតែមួយ។ ការបង្កើតអត្តសញ្ញាណថ្មីនៅពេលរស់នៅ / ធ្វើការតាមផ្លូវ ជួយឲ្យកុមារងើបផុតពីភាពរើសអើងថាជា "ក្មេងតាមផ្លូវ" និងផ្តល់នូវអត្ថន័យវិជ្ជមានចំពោះបទពិសោធន៍ឈឺចាប់ដែលពួកគេជួបប្រទះ ដោយសារការដែលពួកគេស្ថិតនៅក្នុងក្រុមមួយ ដែលទទួលយកពួកគេ។ យុទ្ធសាស្ត្រដើម្បីរស់រានមានជីវិតនេះ ក៏អាចជួយផ្តល់សិទ្ធិអំណាចដល់យុវជនផងដែរ។ ដូច្នេះ កុមារនៅដងផ្លូវក្នុងទីក្រុងយ៉ូកយ៉ាតា អាចបង្ហាញការប្រឆាំងទៅលើការគ្រប់គ្រងរបស់រដ្ឋ និងការចាត់ថ្នាក់អវិជ្ជមាន ដោយធ្វើការបកស្រាយសារជាថ្មីតាមអត្ថន័យដែលវិជ្ជមាន តាមរយៈអត្តសញ្ញាណដែលបានឲ្យតម្លៃថ្មី (Beazley, 2003)។

វិធីសាស្ត្រស្រាវជ្រាវ

គំរូសំណាកស្រាវជ្រាវ

ការសិក្សានេះប្រើនូវវិធីសាស្ត្រគំរូសំណាកដែលមានគោលបំណង និងការណែនាំបន្ត ដើម្បីធ្វើការសម្ភាសបែបពាក់កណ្ដាលរចនាសម្ព័ន្ធជាមួយកុមារជនជាតិខ្មែរនៅតាមដងផ្លូវ និងនៅជុំវិញព្រំដែនខ្មែរ-ថៃ ក្នុងទីក្រុងប៉ោយប៉ែត ប្រទេសកម្ពុជា។ ការសម្ភាសធ្វើឡើងជាមួយក្មេងប្រុសចំនួន ៥៥នាក់ និងក្មេងស្រីចំនួន ២៥នាក់ ដែលរស់នៅ និង/ឬ ធ្វើការនៅតាមផ្លូវ នៅក្នុងតំ បន់សំខាន់ៗចំនួន ៥៖ ផ្សារឡូងគ្លឿ (ប្រទេសថៃ) ក្បាលស្ពាន ភូមិប៉ោយប៉ែត ផ្សារអាគីក (ស្រុកប៉ាឡៃលំយ ១) និងភូមិផ្សារកណ្ដាល។ ការសម្ភាសត្រូវបានធ្វើឡើងដោយបុគ្គលិកជំនាញផ្នែកសង្គមកិច្ចមកពី អង្គការតំណក់ទឹក[1] (Damnok Toek - DT) ដែលជាអង្គការកម្ពុជា និងជាសមាជិកបណ្ដាញសុវត្ថិភាពកុមារ[2] (ChildSafe) ដែលបានធ្វើការជាមួយកុមាររងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ នៅក្នុងទីក្រុងប៉ោយប៉ែត ចាប់តាំងពីឆ្នាំ ២០០៣។

មុនពេលប្រមូលទិន្នន័យ យើងបានចុះធ្វើការច្រើនជាមួយបុគ្គលិកជំនាញក្នុងអង្គការតំណក់ទឹក ដើម្បីស្វែងយល់ពេញលេញអំពីបរិបទ និងបទពិសោធន៍របស់ក្រុមកុមារដែលនៅតាមផ្លូវ និងការងារដែលបានធ្វើជាមួយក្រុមទាំងនេះ។ បន្ថែមពីលើនេះទៀត ការកំណត់ទីតាំងត្រូវបានធ្វើឡើងជាមួយក្រុមប្រមូលទិន្នន័យ និងបុគ្គលិកជំនាញមកពីអង្គការ តំណក់ទឹក ដើម្បីកំណត់អំពីផ្នែកសំខាន់ៗ ដែលអាចរកឃើញកុមារនៅតាមផ្លូវ ក៏ដូចជាព័ត៌មានប្រជាសាស្ត្របឋមអំពី ពួកគេ។ ផ្អែកលើការកំណត់ផែនទីនេះ ទំហំគំរូតាងសម្រាប់ទីតាំង និងយេនឌ័រត្រូវបានបង្កើតឡើង។ ផលធៀបភេទ ប្រុស និងភេទស្រីនៅក្នុងការសិក្សានេះគឺ៖ ក្មេងប្រុសចំនួន ៥៥នាក់ ក្មេងស្រីចំនួន ២៥នាក់។ ចំនួននេះឆ្លុះបញ្ចាំងអំពីការរកឃើញនៅក្នុងការកំណត់ផែនទីនៅក្នុងការសិក្សានេះ ហើយក៏ត្រូវបានឆ្លុះបញ្ចាំងស្រដៀងគ្នានៅក្នុងស្រាវជ្រាវថ្នាក់ជាតិថ្មីៗនេះអំពីយុវជនដែលរស់នៅតាមផ្លូវ នៅក្នុងប្រទេសកម្ពុជា។ ការសិក្សារកឃើញថា ក្មេងប្រុសមានចំនួន ៦៤.៣២% នៃយុវជនដែលរស់នៅតាមផ្លូវ ដែលមានអាយុចន្លោះពី ១៣ ទៅ ១៧ឆ្នាំ (Stark, et al., 2017)។

លក្ខខណ្ឌជ្រើសរើស

ការសិក្សានេះទាមទារនូវលក្ខខណ្ឌសំខាន់ៗចំនួន ៦ សម្រាប់ការបញ្ចូលទៅក្នុងគំរូតាងនៃការសិក្សា។ ដើម្បីរួមបញ្ចូលក្នុងការសិក្សា គ្រប់កុមារទាំងអស់ត្រូវបំពេញលក្ខខណ្ឌខាងក្រោម៖

1. ក្មេងប្រុស ឬក្មេងស្រីដែលធ្វើការ ឬរស់នៅតាមផ្លូវ

[1] សម្រាប់ព័ត៌មានបន្ថែមអំពីអង្គការតំណក់ទឹក និងការងាររបស់ពួកគេនៅក្នុងប្រទេសកម្ពុជា សូមចូលគេហទំព័រខាងក្រោម៖ http://www.damnoktoek.org/html/

[2] បណ្ដាញសុវត្ថិភាពកុមារគឺជាបណ្ដាញការពារកុមារជាសកល។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ៖ http://thinkchildsafe.org/

2. មានអាយុចន្លោះ ១០ និង ១៨ឆ្នាំ
3. មិនរស់នៅក្នុងមណ្ឌល (អង្គការ ឬរដ្ឋាភិបាល) ហើយក៏មិនទទួលអត្ថប្រយោជន៍ពីករណីដែលបានបិទ និងពីស្ថាប័នផ្តល់សេវាសង្គមណាមួយ
4. យល់ព្រមចូលរួមដោយស្ម័គ្រចិត្ត
5. មិនស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ឬគ្រឿងស្រវឹង នៅពេលកំពុងសម្ភាស
6. គ្មានការប្រថុយប្រថានគ្រោះថ្នាក់ដោយការចូលរួមក្នុងការសម្ភាស

ការពិចារណាអំពីក្រមសីលធម៌

អ្នកសម្ភាសទាំងអស់គឺជាបុគ្គលិកដែលមានជំនាញសង្គមកិច្ចមកពីសហគមន៍មូលដ្ឋាន និងបានឆ្លងកាត់ការបណ្តុះ បណ្តាលអំពីការការពារកុមារ ដែលផ្អែកលើការស្រាវជ្រាវ ជាមួយចិត្តវិទូផ្នែកការប៉ះទង្គិចផ្លូវចិត្តកុមារដែលមានអាជ្ញា បណ្ណ ផ្អែកលើគោលការណ៍ណែនាំក្រមសីលធម៌សម្រាប់កិច្ចការស្រាវជ្រាវលើអំពើជួញដូរមនុស្ស (2008) មុននឹង ចាប់ផ្តើមប្រមូលទិន្នន័យ។ នៅក្នុងការបណ្តុះបណ្តាលនេះ យើងប្រើលំហាត់សម្តែងតួ និងសាកល្បងកម្រងសំ ណួរ ដើម្បីជួយឲ្យអ្នកសម្ភាសស្គាល់ឧបករណ៍ស្រាវជ្រាវ និងដើម្បីជួយពួកគេយល់អំពីចិត្ត និងអារម្មណ៍របស់កុមារដែល ត្រូវបានសួរសំណួរ និងដើម្បីរៀបចំពួកគេសម្រាប់ស្ថានភាព ដែលពួកគេនឹងត្រូវបញ្ជូនករណី។

ក្នុងអំឡុងពេលប្រមូលទិន្នន័យ ការសម្ភាសនីមួយៗត្រូវបានធ្វើឡើងនៅក្នុងការសន្ទនាបែបឯកជនពាក់កណ្តាល រវាងកុមារ និងបុគ្គលិកសង្គ មកិច្ច ដែលកុមារនីមួយៗយល់ព្រមជាពាក្យសម្តី និងលាយលក្ខណ៍អក្សរ។ ការសម្ភាសត្រូវបានធ្វើឡើងនៅក្នុងទីតាំងដែលមានសុវត្ថិភាព និងត្រូវបានរៀបចំជាមុន ដែលត្រូវកំណត់តាមរយៈការចុះបំពេញការងារ មុនពេលប្រមូលទិន្នន័យ។ កុមារទាំងអស់ត្រូវបានប្រាប់ជាមុនអំពីគោលបំណងនៃការសិក្សា និងលក្ខណៈនៃសំណួរ និង ការបញ្ជាក់អំពីការរក្សាការសម្ងាត់។ កុមារត្រូវប្រាប់ថា ឈ្មោះរបស់ពួកគេនឹងមិនត្រូវបានកត់ត្រានៅលើបែបបទស្រាវ ជ្រាវទេ ហើយពួកគេអាចបញ្ឈប់ការសម្ភាសនៅពេលណាក៏បាន ប្រសិនបើពួកគេមានអារម្មណ៍មិនស្រួល ឬអាចរំលងសំណួរណាមួយក៏បាន។ ជាចុងក្រោយ សម្រាប់កុមារដែលត្រូវការសេវាសង្គ ម ការការពារផ្នែកច្បាប់ ឬសេវាថែទាំសុខភាព អាចនឹងមានការបញ្ជូនដោយផ្ទាល់ ឬផ្តល់ជូននូវព័ត៌មាននៃការបញ្ជូនបន្ត។

ឧបករណ៍ស្រាវជ្រាវ

កម្រងសំណួរដែលត្រូវបានប្រើសម្រាប់ការសិក្សានេះគឺជាការបញ្ចូលសំណួរពហុចម្លើយ និងសំណួរបើក ដែលនិយាយអំពីប្រធានបទជាច្រើននៅក្នុងជីវិត ការងារ និងបទពិសោធន៍របស់កុមារនៅតាមផ្លូវ ដោយផ្តោតពិសេសទៅលើចំណាកស្រុកទៅប្រទេសថៃ ការប្រើប្រាស់គ្រឿងញៀន និងបទពិសោធន៍នៃអំពើហិង្សា។ ការផ្តោតចម្បងសម្រាប់ការសិក្សាបឋមនេះត្រូវបានសម្រេចថាជាកិច្ចព្រមព្រៀង រវាងថ្នាក់ដឹកនាំនៃអង្គការតំណក់ទឹក និងអង្គការអាប់អ៊ិនធើណា សិនណាល់ (up! International)។

មុននឹងបង្កើតឧបករណ៍ស្រាវជ្រាវនេះ បុគ្គលិកសង្គមកិច្ចមកពីអង្គការតំណក់ ទឹក ជាមួយនឹងអ្នកស៊ើបអង្កេតចម្បង បានធ្វើការពិភាក្សាក្រុមគោលដៅជាមួយកុមារនៅតាមផ្លូវក្នុងក្រុងប៉ោយប៉ែត។ កុមារទាំងនេះត្រូវបានសួរសំណួរអំពីពេលវេលា មធ្យោបាយ និងមូលហេតុដែលពួកគេឆ្លងដែនទៅប្រទេសថៃ រួមទាំងគំ និតយល់ឃើញរបស់ពួកគេអំពីជីវិត និងការងារ នៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃ ។ បន្ថែមពីលើចំណាកស្រុក កុមារទាំងនេះបានពិភាក្សាអំពីប្រភេ ទនៃអំពើហិង្សាដែលពួកគេមើលឃើញកំពុងកើតមានឡើងនៅតាមផ្លូវ ទីតាំងដែលកើតឡើង និងមូលហេតុដែលបណ្តាលឲ្យមានអំពើហិង្សា រួមជាមួយការពិភាក្សាដទៃទៀត។

ការសន្ទនាដំបូងនេះជួយឲ្យក្រុមស្រាវជ្រាវស្វែងយល់កាន់តែច្បាស់ថែមទៀត អំពីការយល់ដឹងរបស់កុមារ និងសកម្មភាពធ្វើចំណាកស្រុក អំពើហិង្សា និងការប្រើគ្រឿងញៀននៅក្នុងសហគមន៍របស់ពួកគេ។ ផ្អែកលើការពិភាក្សា ក្រុមគោលដៅទាំងនេះ ក្រុមស្រាវជ្រាវបង្កើតនូវផ្នែកជាក់លាក់នៃឧបករណ៍ស្រាវជ្រាវ ដែលផ្តោតទៅលើចំណាកស្រុក ការពាក់ព័ន្ធនៅលើផ្លូវ និងការប្រើគ្រឿងញៀន ដែលស្របនឹងបរិបទក្នុងក្រុងប៉ោយប៉ែត។ តាមរយៈការធ្វើការជាមួយបុគ្គលិកសង្គមកិច្ចមកពីអង្គការតំណក់ទឹក ផ្នែកផ្សេងៗនៃឧបករណ៍ស្រាវជ្រាវត្រូវបានកែ សម្រួលឲ្យស្របនឹងបរិបទក្នុងតំបន់ ស្របតាមឧបករណ៍ស្រាវជ្រាវពីលើកមុន ដែលត្រូវបានប្រើដើម្បីប្រមូលព័ត៌មានបឋមគ្រប់ជ្រុងជ្រោយអំពីកុមារដែលរស់នៅ និងធ្វើការតាមដងផ្លូវ (សូមមើលឯកសារស្រាវជ្រាវ៖ Miles & Davis, 2014; Miles & Davis, 2015; Miles & Davis, 2016)។

ឧបករណ៍ព្រាងដំបូងត្រូវបានបកប្រែជាភាសាខ្មែរ ដោយអ្នកបកប្រែពីខាងក្រៅ បន្ទាប់មក ត្រូវបានកែសម្រួលដោយប្រុងប្រយ័ត្នពីសំណាក់ក្រុមបុគ្គលិកសង្គមកិច្ចអង្គការដំណក់ទឹក។ ដំណើការនេះពិតជាសំខាន់ ព្រោះយើងពិតជាឲ្យតម្លៃទៅដល់ចំណេះដឹងរបស់បុគ្គលិក និងបទពិសោធន៍របស់កុមារនៅតាមផ្លូវ ការដែលពួកគេស្គាល់អំពីភាសាដែល ប្រើនៅតាមផ្លូវ និងការចូលរួមបញ្ចេញគំនិតអំពីផ្នែកជាក់លាក់នៃជីវិតរបស់យុវជនទាំងនេះ។ ដំណើរការនៃការចូលរួមបង្កើតឲ្យមានម្ចាស់ការទៅការរៀបចំកម្រងសំណួរ និងម្ចាស់ការទៅលើគម្រោងស្រាវជ្រាវ របស់ក្រុមការងារ និងបង្កើនទំនុកចិត្តលើខ្លួនឯង មុនពេលធ្វើការសម្ភាស។ ការត្រួតពិនិត្យឧបករណ៍ស្រាវជ្រាវជាច្រើនលើកច្រើនសា ជាមួយក្រុមអ្នកសម្ភាសពិតជាសំខាន់ ដើម្បីធានាឲ្យមានភាពច្បាស់ លាស់ សាកល្បងទៅលើសំណួរ រៀបចំលំដាប់លំដោយសំណួរ ព្រមទាំងពិចារណាទៅលើកម្រិតនៃអារម្មណ៍ផាសុកភាពរបស់អ្នកសម្ភាស ដោយគិតទៅដល់វប្បធម៌ និងភាសា ដែលអ្នកសម្របសម្រួលកិច្ចការស្រាវជ្រាវមិនមែនជាជនជាតិខ្មែរ មិនមានការយល់ដឹង។

ការវិភាគទិន្នន័យ

វិធីសាស្ត្រស្រាវជ្រាវចម្រុះ បែបបរិមាណ និងគុណភាព ត្រូវបានប្រើក្នុងពេលបកស្រាយទិន្នន័យ។ ទិន្នន័យត្រូវបានបញ្ចូលទៅក្នុងកម្មវិធី IBM SPSS ដែលត្រូវបានប្រើសម្រាប់ការវិភាគស្ថិតិ។ ចម្លើយបែបគុណភាពត្រូវបានវាយបញ្ចូលយ៉ាងសុក្រិត។ ទាក់ទងនឹងសំណួរបើក យើងប្រើវិធីសាស្ត្របែបគុណភាព ដើម្បីវិភាគទិ ន្នន័យ ហើយអ្នកស្រាវជ្រាវចម្បងបានបែកចែកចម្លើយតាមផ្នែកនីមួយៗជាប្រព័ន្ធ និងកំណត់អំពីក្រុម និងទិដ្ឋភាពរួម។ សំណួរក៏ត្រូវបានបែងចែកជាក់លាក់ដើម្បីបញ្ចូលក្នុងរបាយការណ៍នេះផងដែរ ដើម្បីស្វែងយល់បន្ថែមទៀតអំពីបទពិសោធន៍នៃអំពើហិង្សាដែល

កុមារជួបប្រទះ។ ទិន្នន័យនេះត្រូវបានធ្វើបទបង្ហាញ ដោយផ្តោតសំខាន់ទៅលើព័ត៌មានទៅលើយេនឌ័រដាក់លាក់ ដែលជាការផ្តោតសំខាន់នៅក្នុងរបាយការណ៍នេះ បង្ហាញអំពីចំណុចខុសគ្នា និងចំណុចរួម ទាក់ទងទៅនឹងអំពើហិង្សានៅតាមផ្លូវ។

លទ្ធផល

ព័ត៌មានប្រជាសាស្ត្រ

អាយុ

អាយុរបស់កុមារចូលរួមមានចន្លោះ ១០ឆ្នាំ។ កុមារដែលក្មេងជាងគេមានអាយុ ៨ឆ្នាំ ហើយច្រើនជាងគេអាយុ ១៨ឆ្នាំ ដូច្នេះ អាយុជាមធ្យមគឺ ១២.៨ឆ្នាំ។ ក្មេងប្រុស និងក្មេងស្រីត្រូវបានរកឃើញថាមានអាយុស្មើរតែដូចគ្នា ដែល ក្មេងប្រុសមានអាយុជាមធ្យម ១២.៩ឆ្នាំ ហើយក្មេងស្រីអាយុជាមធ្យម ១២.៣ឆ្នាំ។ បន្ថែមពីលើនេះទៀត ទាំងក្មេង ប្រុស និងក្មេងស្រីអាយុក្មេងជាងគេបំផុតគឺ ៨ឆ្នាំ ហើយច្រើនជាងគេបំផុតគឺ ១៨ឆ្នាំ។

ឪពុកម្តាយ និងអ្នកមើលថែ

កុមារច្រើនជាង ១/៣ (៣៥%) លើកឡើងថា យ៉ាងហោចណាស់ ឪពុក ឬម្តាយរបស់ពួកគេបានស្លា ប់ ហើយក្នុងចំណោមនោះមាន ២៩% បានលើកឡើងថា បានបាត់បង់ឪពុក។ ចំនួនភាគច្រើនដែលមាន ៥៣នាក់ ឬ ៧៣% លើកឡើងអំពីការរស់នៅជាមួយឪពុក/ម្តាយបង្កើត យ៉ាងហោចណាស់ម្នាក់។ យើងឃើញថា ជាទូទៅកើតឡើងចំពោះក្មេងស្រី (៨៤%) ច្រើនជាង បើប្រៀបធៀបជាមួយក្មេងប្រុស (៦៧%)។

តាមការស្រាវជ្រាវបានរកឃើញថា ការរស់នៅជាមួយមនុស្សជាក់លាក់ណាម្នាក់ មិនមែនបានន័យថា បុគ្គលនោះមើលថែពួកគេដែរនោះទេ។ ដូច្នេះ កុមារត្រូវបានសួរអំពីបុគ្គលសំខាន់ម្នាក់ដែលមើលថែពួកគេ។ នេះគឺជាសំណួរបើកមួយ ហើយកុមារអាចឆ្លើយអំពីមនុស្សណាម្នាក់ ឬមនុស្សច្រើននាក់ តាមការចាំបាច់ បន្ទាប់មក ចម្លើយត្រូវបានបែងចែកជាផ្នែក និងត្រូវបានវិភាគ។ ចំនួនកុមារច្រើនជាង ១/៣ បន្តិច និយាយថា ឪពុកម្តាយរបស់ពួកគេជាអ្នកមើលថែពួ កគេ

(២៦នាក់ ឬ ៣៦%)។ កុមារចំនួ នតិចជាង ១/៣ លើកឡើងថា ពួកគេទទួលការមើលថែពីម្ដាយរបស់ពួកគេ តែម្នា ក់ គត់ (២៣នាក់ ឬ ៣០%)។ កុមារចំនួនតិចជាងបានលើកឡើងថា ជីដូន/ជីតារបស់ពួកគេគឺជាអ្នកមើលថែ (១២នាក់ ឬ ១៦%) ឬ ទទួលការមើលថែពីឪពុក (៥នាក់ ឬ ៦%)។ ចម្លើយរបស់ពួកគេក៏រួមបញ្ចូលកុមារ ៣នាក់ ដែលលើកឡើង ថា ពួកគេ ទទួលការមើលថែដោយមិត្តភ័ក្ត ក្រុមបងធំ ហើយកុមារពីរនាក់មានសាច់ញាតិជាអ្នកមើលថែ ម្នាក់មានបង ប្អូនបង្កើតជាអ្នកមើលថែ ហើយម្នាក់ទៀតលើកឡើងថា គ្មានអ្នកណាមើលថែគាត់ទេ។

ក្មេងស្រីលើកឡើងថា ពួកគេជួបជាមួយអ្នកមើលថែរបស់ពួកគេញឹកញាប់ជាង បើប្រៀបធៀបជាមួយក្មេងប្រុស ដែល ១០០% នៃក្មេងស្រីលើកឡើងថា ពួកគេជួបជាមួយអ្នកមើលថែរបស់ពួកគេជារៀងរាល់ថ្ងៃ។ ផ្ទុយទៅវិញ ក្មេង ប្រុសចំនួនតែ ៧៥% ប៉ុណ្ណោះដែលលើកឡើងថា ពួកគេជួបជាមួយអ្នកមើលថែរាល់ថ្ងៃ។ ក្នុងចំណោមអ្នកដែលមិនបានជួបជាមួយអ្នកមើលថែរាល់ថ្ងៃ ក្មេងប្រុស ៣នាក់ (៦%) និយាយថា ពួកគេជួបជាមួយអ្នកមើលថែពីរបីថ្ងៃម្ដង ហើយក្មេងប្រុស ៣នាក់ទៀត (៦%) និយាយថា ពួកគេជួបជាមួយអ្នកមើលថែមួយសប្ដាហ៍ម្ដង ហើយក្មេងប្រុស ៤នាក់ (៨%) និយាយថា ពួកគេជួបជាមួយអ្នកមើលថែរបស់ពួកគេពីរបីសប្ដាហ៍ម្ដង។

ការអប់រំ

កុមារទាំងនេះត្រូវបានសួរអំពីពេលដែលចូលរៀនចុងក្រោយ។ ៧៥% បានលើកឡើងថា ពួកគេមិនទាន់បានចូលរៀនទេ ក្នុងអំឡុងឆ្នាំសិក្សាថ្មីនេះ ហើយ ៩% លើកឡើងថា ពួកគេបានចូលរៀនកាលពីឆ្នាំមុន។ ៣២% និយាយថា ពួកគេបានចូលរៀនកាលពីជាងមួយឆ្នាំមុន ហើយ ២៥% និយាយថា ពួកគេមិនដែលបានចូលរៀនទេ។ ការចុះឈ្មោះចូល រៀនរវាងក្មេងប្រុស និងក្មេងស្រី មានភាពស្រដៀងគ្នា ក៏ប៉ុន្តែ ក្នុងចំណោមកុមារដែលមិនបានចូលរៀននៅពេល បច្ចុប្បន្ន គឺក្មេងស្រីមានទំនោរចូលរៀនតិចជាងក្មេងប្រុស (៣៦% នៃក្មេងស្រីបើប្រៀបធៀបនឹង ២០% នៃក្មេងប្រុស)។ បន្ថែមពីលើនេះទៀត ស្ទើរតែគ្រប់កុមារទាំងអស់ (៩៦%) លើកឡើងថា ថ្នាក់រៀនចុងក្រោយដែលពួកគេបានបញ្ចប់គឺថ្នាក់បឋមសិក្សា។ មានតែកុមារពីរនាក់ប៉ុណ្ណោះដែលបង្ហាញថា ពួកគេបានចុះឈ្មោះចូលរៀនថ្នាក់អនុវិទ្យា ល័យ។

ការពាក់ព័ន្ធនៅតាមផ្លូវ

លំនៅដ្ឋាន

ដោយសារភាពចម្រុះគ្នានៃក្រុមកុមារដែលពាក់ព័ន្ធនៅតាមផ្លូវ និងលំនៅដ្ឋានរបស់ពួកគេដែលមិនមានភាពជាប់លាប់ ដូច្នេះការដែលគ្រាន់តែសួរអំពីទីកន្លែងដែលពួកគេគេងនៅពេលយប់ មិនអាចស្វែងយល់ឲ្យបានគ្រប់គ្រាន់អំពីភាព ងាយរងគ្រោះរបស់ពួកគេទេ។ ដើម្បីសម្របទៅនឹងភាពចម្រុះនៃក្រុមកុមារ អ្នកស្រាវជ្រាវបានសួរសំ ណួរទៅកាន់ពួក គេ នូវសំណួរបែបគុណវិស័យអំពីទីកន្លែងដែលពួកគេគេង ហើយគេងនៅទីនោះញឹកញាប់ប៉ុណ្ណា និងមូលហេតុអ្វីបានជាពួកគេគេងនៅទីនោះ និងក៏សួរអំពីអារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេផងដែរ នៅពេលពួកគេគេងនៅទីកន្លែងផ្សេងៗគ្នា។

មុនដំបូង កុមារភាគច្រើន ៥៩នាក់ ឬ ៧២% លើកឡើងថា ពួកគេរស់នៅក្នុងផ្ទះជាមួយសមាជិកគ្រួសារ ឬអ្នកមើល ថែ។ លើសពីនេះ ១២% បានលើកឡើងថា ពួកគេរស់នៅក្នុងផ្ទះជាមួយមនុស្សដែលមិនមែនជាគ្រួសាររបស់ពួកគេទេ។ នៅក្នុងសំណួរដំបូង មានតែ ១៦% ប៉ុណ្ណោះដែលបានលើកឡើងថា ពួកគេគេងនៅតាមផ្លូវ។ ក៏ប៉ុន្តែ ក្នុងចំណោមកុមារដែលលើកឡើងថា ពួកគេគេងនៅតាមផ្ទះ មានតែ ៨០% ប៉ុណ្ណោះដែលនិយាយថា ពួកគេគេងនៅ ផ្ទះជាប្រចាំ។ ១១% និយាយថា ពួកគេគេងនៅទីនោះ ៤-៦យប់ក្នុងមួយសប្តាហ៍ ហើយ ៩% និយាយថា ពួកគេគេង នៅទីនោះតែ ១-៣យប់ប៉ុណ្ណោះក្នុងមួយសប្តាហ៍។ នៅពេលត្រូវបានសួរថាតើពួកគេគេងនៅទីណា ជាទូទៅ ១១នាក់ និយាយថា ពួកគេគេងនៅតាមផ្លូវ ៣នាក់គេងនៅក្នុងមណ្ឌលសំចត និង ២នាក់និយាយថា គេងជាមួយសមាជិក គ្រួសារ។

នៅពេលគិតអំពីភាពមិនជាប់លាប់នេះ ៣៣% នៃកុមារទាំងនេះគេងនៅតាមផ្លូវម្តងម្កាល ស្ទើរតែច្រើនជាងទ្វេដងនៃចំនួនកុមារដែលលើកឡើងដំបូងថា ពួកគេគេងនៅតាមផ្លូវ។ ការគេងនៅតាមផ្លូវស្ទើរតែកើតឡើងទ្វេដងចំពោះក្មេងប្រុស ដែល ៥០% នៃក្មេងប្រុស (១៩នាក់) គេងនៅតាមផ្លូវម្ត ងម្កា ល បើប្រៀបធៀបជាមួយ ២០% នៃក្មេងស្រី (៥នាក់)។ ក្នុងចំណោមកុមារដែលគេងនៅតាមផ្លូវម្តងម្កាល មាន ៤នាក់បានលើកឡើងថា ពួកគេគេងនៅតាមផ្លូវ ដោយសារការងារ ដោយពន្យល់ថា ពេលខ្លះពួកគេមកផ្ទះយឺតនៅពេលបញ្ចប់ការងាររួច។ បីនាក់និយាយថា ពួកគេគេង នៅតាមផ្លូវ ដើម្បីចៀសវាងអំពើហិង្សដែលមាននៅផ្ទះ ចំណែកឯ ៣នាក់ទៀតនិយាយថា ពួកគេគ្មានកន្លែងគេង។ កុមារ

ពីរនាក់និយាយថា ការប្រើគ្រឿងញៀនរារាំងពួកគេមិនឲ្យត្រឡប់ទៅផ្ទះវិញ ហើយម្នាក់ទៀតនិយាយថា ការគ្មានលំនៅដ្ឋានមិនសមរម្យ (ផ្ទះខូចខាត ឬសើមប៉ិចប៉ាច់) ធ្វើឲ្យពួកគេគេងនៅតាមផ្លូវ ដែលនេះគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើនផ្សេងទៀត។

ការរកប្រាក់ចំណូល

កុមារត្រូវបានរកឃើញថា ពួកគេធ្វើការងារជាច្រើនផ្សេងៗគ្នា នៅតាមផ្លូវ។ ការសុំទានគឺជាប្រភេទការងារដែលត្រូវបានលើកច្រើនជាងគេ ដែលមានកុមារលើសពាក់កណ្តាល (៥៣%) និយាយថា ពួកគេធ្វើការងារប្រភេទនេះ។ បន្ទាប់ពីការងារសុំទាន គឺការងាររើសអេតចាយនៅក្នុងសំរាម ដែលត្រូវបានលើកឡើងដោយ ១ ក្នុងចំណោម ៥នាក់ (២១%)។ ការអូសរទេះឆ្លងដែនក៏ត្រូវបានលើកឡើងដោយកុមារចំនួន ៦នាក់ (៨%) និងការលក់តវ៉ាន់នៅតាមផ្លូវក៏ត្រូវបានលើកឡើងដោយកុមារចំនួន ៦នាក់ផ្សេងទៀតដែរ។ "ការងារសំណង់" ក៏ត្រូវបានលើកឡើងតិចតួច ដោយកុមារចំនួន ២នាក់ ហើយពីរនាក់លើកឡើងអំពី "ការងារចម្ការ"។ កុមារពីរនាក់លើកឡើងអំពីការបេះកណ្តូប ម្នាក់និយាយ "សែងជ្រូក" និងម្នាក់ទៀតនិយាយថា "មើលថៃក្មេង"។ ទោះបីជាការងារសុំទាន និងរើសអេតចាយគឺជាការងារទូទៅសម្រាប់ភេទប្រុស និងភេទស្រីក៏ដោយ ប៉ុន្តែមានការងារប្រភេទផ្សេងទៀតដែលហាក់បីដូចជា ត្រូវនឹងភេទជាក់លាក់ជាង ដូចជា ការអូសរទេះសម្រាប់ភេទប្រុស និងការលក់ដូរនៅតាមផ្លូវ (ជាញឹកញាប់ លក់ដូរជាមួយឪពុកម្តាយ ឬអ្នកមើលថែ) សម្រាប់ភេទស្រី។

ជាទូទៅ កុមារលើកឡើងអំពីការធ្វើការរយៈពេល ៦.៨ម៉ោងជាមធ្យមក្នុងមួយថ្ងៃ ជាអប្បបរិមា ១.៥ម៉ោង និងជាអតិបរិមា ១៦ម៉ោង។ ទោះបីជាម៉ោងធ្វើការជាមធ្យមរបស់ក្មេងប្រុស និងក្មេងស្រីប្រហាក់ប្រហែលគ្នាក៏ដោយ ប៉ុន្តែក្មេងប្រុសមួយចំនួនបានលើកឡើងពីការធ្វើការច្រើនម៉ោងជាង ដោយមានក្មេងប្រុសម្នាក់ធ្វើការរហូតទៅដល់ ១៦ម៉ោងក្នុងថ្ងៃ។

អ្នកសម្ភាសបានសុំឲ្យកុមាររៀបរាប់អំពីចំណុចល្អ និងចំណុចមិនល្អ ដែលពួកគេមើលឃើញក្នុងការរស់នៅ/ធ្វើការនៅតាមផ្លូវ។ ការសួរសំណួរទាំងនេះគឺដើម្បីពិចារណាទៅលើកត្តារុញច្រាន ដែលនាំឲ្យកុមារចូលមកពាក់ព័ន្ធនឹងដងផ្លូវ និងកត្តាអូសទាញដែលធ្វើឲ្យពួកគេចង់នៅតាមផ្លូវ។ គិតអំពីចំណុចវិជ្ជមានអំពីការពាក់ព័ន្ធនៅតាមផ្លូវ កុមារមើលឃើញអំពី

សមត្ថភាពក្នុងការរកលុយ ដែលជាមូលហេតុចម្បងក្នុងការបន្តរស់នៅ/ធ្វើការតាមផ្លូវ ក្នុងចំណោមកុមារជាងពាក់កណ្តាល (៥៣%)។ ការឆ្លើយតបនេះច្រើនតែលើកឡើងក្នុងចំណោមក្មេងស្រី (៦៥%) បើប្រៀបធៀបជាមួយក្មេងប្រុស (៤៨%)។ ទីពីរ កុមារចំនួន ១៨នាក់ (២៧%) លើកឡើងថា ការរស់នៅ/ធ្វើការនៅតាមផ្លូវ "គ្មានអ្វី" ល្អទេ។ កុមារមួយចំំនួនតូចក៏លើកឡើងអំពីទំនាក់ទំនងសង្គម និងសេរីភាពដែលជាកត្តាវិជ្ជមាននៃការរស់នៅ/ធ្វើការនៅតាមផ្លូវ។

តាមរយៈការពិចារណាអំពីចំណុចអវិជ្ជមាននៃការរស់នៅ/ធ្វើការនៅតាមផ្លូវ កុមារផ្តល់ចម្លើយខុសៗគ្នា។ អំពើហិង្សា លើរាងកាយគឺជាចំណុចអវិជ្ជមានមួយនៃការរស់នៅ/ធ្វើការនៅតាមផ្លូវ ដែលត្រូវបានលើកឡើងដោយកុមារចំនួន ១៥នាក់ (៣០%)។ ចំណុចអវិជ្ជមាននេ ះភាគច្រើនត្រូវបានលើកឡើងដោយក្មេងប្រុសច្រើនជាង ដែលមានក្មេងប្រុស ១២នាក់ (៣៤%) លើកឡើងអំពីអំពើហិង្សាផ្នែករាងកាយ និងក្មេងស្រី (២០%) លើកឡើងដូចគ្នា។ ក្រៅពី អំពើហិង្សាលើរាងកាយ កុមារចំនួន ៧នាក់ (១៤%) លើកឡើងអំពី "ការត្រូវបានគេចាប់ខ្លួ ន" ថាជាចំណុ ចអវិជ្ជមាននៃការ ធ្វើការ/រស់នៅតាមផ្លូវ។ ការត្រូវគេចាប់ខ្លួនត្រូវបានលើកឡើងញឹកញាប់ដោយក្មេងស្រីច្រើនជាង (២៧% បើប្រៀបធៀបទៅនឹងក្មេងប្រុស ៩%)។ ក្រៅពីនេះ កុមារ ៦នាក់ (១២%) លើកឡើងថា ការគ្មានការអប់រំគឺជាចំណុចអវិជ្ជ មាន។ ចំណុចអវិជ្ជមាននេះភាគច្រើនត្រូវបានលើកឡើងដោយក្មេងស្រី (២៧%) បើប្រៀបធៀបនឹងក្មេងប្រុស (៦%)។ "ការត្រូវចោរឆក់" ក៏ត្រូវបានលើកឡើងបន្តិចដែរ ដោយក្មេងប្រុសទាំងអស់ (៩%) និង "អាកាសធាតុក្តៅ" ក៏ត្រូវបានលើកឡើងដោយក្មេងប្រុសទាំងអស់ (៩%) ការគ្មានលុយចាយ ៩% នៃក្មេងប្រុសទាំងអស់ និង "អំពើហិង្សាផ្នែកពាក្យសម្តី" ត្រូវបានលើកឡើងដោយក្មេងប្រុសទាំំងអស់ (៩%)។ ចំណុចអវិជ្ជមានផ្សេងទៀតក៏ត្រូវបានលេ ីកឡើងដែរ រួមមាន "ការរើសអើង" "ការប្រើប្រាស់គ្រឿងញៀន" "ភាពអាម៉ាស់" "ការធ្វើការលំបាកលំបិន" "ភាពអត់ឃ្លាន" និង "ការគេងមិនគ្រប់គ្រាន់"។

ការធ្វើចំណាកស្រុក

ការធ្វើចំណាកស្រុកទៅប៉ោយប៉ែត



កុមារភាគច្រើន (៦៣%) កើតនៅក្រៅក្រុងប៉ោយប៉ែត និងធ្វើចំណាកស្រុកមកតំបន់នេះ។ ការធ្វើចំណាកស្រុកមក តំបន់ប៉ោយប៉ែតពីតំបន់ផ្សេងទៀតធ្វើឡើងភាគច្រើនដោយក្មេងស្រី (៧៨%) បើប្រៀបធៀបនឹងក្មេងប្រុស (៥៥%)។ ភាគច្រើន កុមារទាំងនេះកើតនៅខេត្តផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា រួមទាំងរាជធានីភ្នំពេញ (៦នាក់) ខេត្តសៀមរាប (៦នាក់) ខេត្តព្រៃវែង (៥នាក់) ខេត្តពោធិ៍សាត់ (៥នាក់) ខេត្តបន្ទាយមានជ័យ (៤នាក់) ខេត្តបាត់ដំបង (៤នាក់) និងខេត្តកំពង់ចាម (៣នាក់) និងខេត្តផ្សេងៗទៀត (៦នាក់)។ កុមារ ៤នាក់កើតនៅក្រៅប្រទេសកម្ពុជា រួម មាន ៣នាក់នៅក្នុងប្រទេសថៃ និងម្នាក់នៅក្នុងប្រទេសវៀតណាម។

ជាមធ្យម កុមារដែលបានរស់នៅក្នុងតំបន់ប៉ោយប៉ែតរយៈពេល ៦.៩ឆ្នាំ ដែលរយៈពេលខ្លីបំផុតបន្ទាប់ពីធ្វើចំណាក គឺរយៈពេល ១ខែ និងរយៈពេលយូរបំផុត ១៨ឆ្នាំ។ ក្មេងប្រុសជាមធ្យមបានលើកឡើងថា បានធ្វើចំណាកស្រុកមកប៉ោយប៉ែតថ្មីៗជាងក្មេងស្រី (ជាមធ្យមរយៈពេល ៤.៦ឆ្នាំ បើប្រៀបធៀបនឹងក្មេងស្រីដែលមានរយៈពេល ៧.៥ឆ្នាំ)។ ជាទូទៅ កុមារលើកឡើងថា ពួកគេបានធ្វើចំណាកស្រុកមកប៉ោយប៉ែត ដើម្បីសុំទាន (២០នាក់ ឬ ៤៨%) ឬមកស្វែង រកការងារធ្វើ (១២នាក់ ឬ ២៩%) ដោយចង្អុលបង្ហាញថា ភាពក្រីក្រ អាចជាការជំរុញឲ្យមានចំណាកស្រុក។ ហេតុផល ផ្សេងទៀតនៃការធ្វើចំណាកស្រុក រួមមាន បំណុល (៣នាក់) និងភាពក្រីក្រ (៣នាក់) នៅក្នុងចំណោមហេតុផលផ្សេង ទៀត។ កុមារភាគច្រើន (៧៧%) លើកឡើងថា ពួកគេបានធ្វើចំណាកស្រុកជាមួយគ្រួសាររបស់ពួកគេ។ កុមារដទៃទេ ៀតដែលធ្វើចំណាកស្រុកជាមួយគ្រួសារមាន ១៣% ជាមួយបងប្អូនបង្កើតមាន ៥% ធ្វើដំណើរម្នាក់ឯងមាន ៥% ឬ ជាមួយមិត្តភ័ក្ត (២%)។

ការឆ្លងដែន

ការផ្តោតសំខាន់នៃការសម្ភាសទាក់ទងនឹងការបង្កើតការយល់ដឹងអំពីភាពងាយរងគ្រោះ ទាក់ទងនឹងការឆ្លងដែនទៅធ្វើការនៅក្នុងប្រទេសថៃ។ សំណួរសំខាន់ដែលត្រូវបានសួរនៅក្នុងផ្នែកនេះ ពាក់ព័ន្ធនឹងមូលហេតុដែលពួកគេឆ្លងព្រំដែន នរណាដែលពួកគេឆ្លងទៅជាមួយ ពួកគេស្នាក់នៅរយៈពេលប៉ុន្មាន ពួកគេឆ្លងនៅពេលណា និងពួកគេឆ្លងដោយរបៀបណា ខុសច្បាប់ ឬស្របច្បាប់។

កុមារស្ទើរតែ ១/៣ លើកឡើងថា ពួកគេមិនដែលឆ្លងដែនទៅប្រទេសថៃទេ ប៉ុន្តែធ្វើការងារនៅតាមផ្លូវនៅក្នុងទឹកដីកម្ពុជា។ សម្រាប់កុមារភាគច្រើនផ្សេងទៀត មាន ២៣នាក់ (៣១% នៃកុមារចូលរួម) ឆ្លងដែនជាមួយសមាជិកគ្រួសារ។ កុមារ ២១នាក់ (២៨% នៃកុមារចូលរួមទាំងអស់) ឆ្លងព្រំដែនជាមួយមិត្តភ័ក្តម្នាក់។ កុមារ ៥នាក់ឆ្លងព្រំដែន ម្នាក់ឯង ហើយ ៥នាក់ទៀតឆ្លងជាមួយ "មនុស្សម្នាក់ទៀត"។

ក្នុងចំណោមកុមារដែលឆ្លងព្រំដែន កុមារភាគច្រើន ឬ ២៩នាក់ (៣៩%) លើកឡើងអំពីការឆ្លងព្រំដែន "យូរៗម្តង" ដែលមានភាពស្រដៀងគ្នារវាងក្មេងប្រុស និងក្មេងស្រី (៣៩% និង ៣៨%)។ កុមារ ៨នាក់ (១១%) លើកឡើងថា ពួកគេឆ្លងព្រំដែន "រាល់ថ្ងៃ" ហើយទាំង ៨នាក់គឺជាក្មេងប្រុស។ កុមារ ១០នាក់ (១៣%) លើកឡើងថា ពួកគេឆ្លង ព្រំដែន "ពីរបីដងក្នុងមួយសប្តាហ៍" ដែលមានភាពប្រហាក់ប្រ ហែលគ្នារវាងក្មេងប្រុស និងក្មេងស្រី (១២% និង ១៧%)។ កុមារតែ ៦នាក់ប៉ុណ្ណោះ (៨%) ក្មេងប្រុស ៣នាក់ និងក្មេងស្រី ៣នាក់ ដែលឆ្លងព្រំដែនលើកឡើងថា ពួកគេឆ្លងពីរបីដងក្នុងមួយខែ។



គោលបំណងដែលបញ្ជាក់ក្នុងការឆ្លងព្រំដែនទៅក្នុងប្រទេសថៃ ហាក់បីដូចជាមានភាពជាឯកច្ឆន្ទ ដែលមានកុមារស្ទើរតែទាំងអស់ (៥៥ នាក់ ឬ ៩៤%) ឆ្លងព្រំដែនដើម្បីទៅរកប្រាក់ចំណូល។ ក្នុងចំណោមកុមារដែលឆ្លងដែន ដើម្បីទៅធ្វើការ ក្មេងស្រីហាក់បីដូចជាធ្វើចំណាកស្រុកទៅធ្វើការងារជាក់លាក់ ដែលមាន ៨0% លើកឡើងអំពីប្រភេទការងារ ឬកិច្ចការផ្សេងៗគ្នា ដែលពួកគេនឹងធ្វើនៅពេលឆ្លងព្រំដែន ដើម្បីស្វែងរកលុយ។ ចំពោះក្មេងប្រុសវិញ ពួកគេហាក់បីដូចជាមានភាពស្រពិចស្រពិលក្នុងចម្លើយរបស់ពួកគេ ដោយ ៤៨% លើកឡើងថា ពួកគេបានឆ្លងព្រំដែន "ដើម្បីរកលុយ"។



នៅក្នុងចំណោមកុមារដែលឆ្លងព្រំដែន មានតែ ២១នាក់ (៤៥%) បានរាយការណ៍អំពីការឆ្លងព្រំដែន តាមច្រក "ស្របច្បាប់" ទៅក្នុងប្រទេសថៃ។ ទោះបីជាការចូលទៅប្រទេសថៃឆ្លងកាត់ច្រក "ស្របច្បាប់" ក៏ដោយ ប៉ុន្តែមិនមានព័ត៌មានច្បាស់ថា តើកុមារទាំងនេះពិតជាឆ្លងដែនស្របច្បាប់នោះទេ។ កុមារម្នាក់នៅក្នុងក្រុមដែលប្រើច្រកឆ្លងដែនស្របច្បាប់ លើកឡើងថា គាត់ឆ្លងច្រកព្រំដែនស្របច្បាប់ ដោយប្រើបណ្ណឆ្លងដែនក្លែងក្លាយ។ ព័ត៌មានដែលទទួល បានពីបុគ្គលិកធ្វើការផ្ទាល់បង្ហាញថា ការប្រើបណ្ណឆ្លងដែលក្លែងក្លាយអាចនឹងកើតឡើងច្រើនជាងការបង្ហាញនៅក្នុង ទិន្នន័យនេះ។ ការឆ្លងដែនស្របច្បាប់ទាមទារឲ្យមានបណ្ណឆ្លងដែនរយៈពេលមួយថ្ងៃ (ប្រហែលជា ១០០០រៀល) ដែលអាចប្រើបានតែមួយថ្ងៃប៉ុណ្ណោះ ឬត្រូវមានឯកសារផ្លូវការផ្សេងទៀត ដែលអនុញ្ញាតឲ្យអ្នកចូលទៅក្នុងប្រទេស ថៃ រយៈពេលយូរជាង។

ចំណាកស្រុករបស់ឪពុកម្តាយ

កុមារភាគច្រើន ឬ ៦០% (៤៣នាក់) លើកឡើងថា ឪពុកម្តាយរបស់ពួកគេ ធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីរកការងារធ្វើ។ ក្នុងគ្រប់ករណីទាំងអស់ លើកលែងតែ ៣ ករណីប៉ុណ្ណោះ ដែលបញ្ជាក់ថា ឪពុកម្តាយធ្វើចំណាកស្រុក និងទុកឲ្យកូនចោលក្នុងប្រទេសខ្មែរ។ ក្នុងចំណោមកុមារដែលមានឪពុកម្តាយធ្វើចំណាកស្រុកទៅធ្វើការ មានការរៀបរាប់អំពីសកម្មភាពរកប្រាក់ចំណូលផ្សេងៗគ្នា។ ក្នុងចំណោមការងារដែលបានរៀបរាប់ច្រើនជាងគេគឺ ការងារសំណង់ ដែលមនុស្ស ៨នាក់ បានលើកឡើង។ កុមារ ៥នាក់ (១៤%) លើកឡើងថា ឪពុកម្តាយរបស់ពួកគេធ្វើការងារសុំទាន ឬរើសអេតចាយនៅក្នុងប្រទេសថៃ និង ៥នាក់ទៀត (១៤%) និយាយថា ឪពុកម្តាយរបស់ពួកគេអូសរទេះ ដែលជា ការងារដែលត្រូវបានលើកឡើងច្រើនសម្រាប់កុមារផងដែរ។ បន្ថែមពីលើនេះទៀត កុមារ ៥នាក់ (១៤%) លើកឡើងថា ឪពុកម្តាយរបស់ពួកគេបេះផ្លែឈើ និងបន្លែនៅក្នុងប្រទេ សថៃ និង ៤នាក់ (១១%) លើកឡើងថា ឪពុកម្តាយរបស់ពួកគេធ្វើត្រី។

មានមួយចំនួនតូច ដែលមានកុមារ ៣នាក់ (៨%) លើកឡើងថា ឪពុកម្តាយរបស់ពួកគេរៀប ចំលក់សត្វល្អិត ៣នាក់ (៨%) ផ្សេងទៀតលក់សម្ភារៈផ្សេងៗ ២នាក់ (៦%) មើលខុសត្រូវក្មេងសុំទាន និងម្នាក់ (៣%) ធ្វើការជាអ្នកលក់សាច់។

នៅពេលធ្វើចំណាកស្រុកទៅប្រទេសថៃដើម្បីធ្វើការ កុមារនិយាយថា ឪពុកម្តាយរបស់ពួកគេទៅរយៈពេលខុសៗគ្នា។ ចំពោះកុមារភាគច្រើន ចំនួន ១១នាក់ (៣០%) ឪពុកម្តាយរបស់ពួកគេទៅតែពេលថ្ងៃទេ ហើយត្រឡប់វិញនៅពេលល្ងាច។ ប៉ុន្តែសម្រាប់កុមារមួយចំនួនធំទៀត ចំនួន ១០នាក់ (២៧%) និយាយថា ឪពុកម្តាយរបស់ពួកគេហាក់បីដូចជា ក្នុងពេលវេលាមិនច្បាស់លាស់ ដោយកុមារទាំងនេះនិយាយថា ឪពុកម្តាយរបស់ពួកគេធ្វើដំណើរទៅរយៈពេលយូរមក ហើយមិនបានប្រាប់ពេលវេលាជាក់លាក់ថានឹងត្រឡប់មកវិញនៅពេលណាទេ។ ស្រដៀងគ្នានឹងក្រុមនេះដែរ កុមារ ៤នាក់ (១១%) និយាយថា ឪពុកម្តាយរបស់ ពួកគេចាកចេញទៅកាលពី ១ឆ្នាំមុន និងមិនបានប្រាប់អំពីពេ លវេលាត្រឡប់មកវិញជាក់លាក់នោះទេ។ ចំពោះឪពុកម្តាយរបស់កុមារផ្សេងទៀត កុមារ ៦នាក់ (១៦%) លើកឡើងថា ឪពុកម្តាយរបស់ពួកគេមកលេងពីប្រទេសថៃប្រចាំឆ្នាំ កុមារ ៤នាក់ (១១%) និយាយថា ឪពុកម្តាយរបស់ពួកគេទៅ ម្តងៗរយៈពេល ១-៦ខែ ចំណែកឯកុមារ ២នាក់ទៀត (៥%) និយាយថា ឪពុកម្តាយរបស់ពួកគេទៅរយៈពេលពីរបីថ្ងៃ ម្តង។

ដោយសារពេលខ្លះ ឪពុកម្តាយរបស់កុមារអវត្តមានរយៈពេលយូរ វាជាការសំខាន់ដែលត្រូវដឹងថា នរណាជាអ្នកមើលថែកុមារ នៅពេលឪពុកម្តាយរបស់ពួកគេនៅឆ្ងាយ។ ចំពោះកុមារ ១៥នាក់ (៤១%) មានឪពុក/ម្តាយម្នា ក់ទៀតដែលជាអ្នកមើលថែកុមារ។ កុមារ ១២នាក់ (៣២%) និយាយថា ពួកគេត្រូវបានមើលថែដោយជីដូ ន/ជីតា ឬបងប្អូនបង្កើត ហើយកុមារ ៨នាក់ (២២%) និយាយថា ពួកគេត្រូវបានទុកឲ្យនៅម្នាក់ឯង នៅពេលឪពុកម្តាយរបស់ ពួកគេនៅ ឆ្ងាយ។ អ្នកសម្ភាសបានសួរកុមារថាតើពួកគេគិតថា ឪពុកម្តាយរបស់ពួកគេត្រូវការអ្វីខ្លាំងជាងគេ។ ទោះបីជាចម្លើយទូទៅមានភាពចម្រុះគ្នា ប៉ុន្តែចម្លើយភាគច្រើនទាក់ទងនឹងការបំពេញតម្រូវការបឋមក្នុងជីវិតគ្រួសារ ដែលមានកុមារ ២០នាក់ (៦១%) និយាយថា ឪពុកម្តាយរបស់ពួកគេត្រូវការលុយ ហើយ ៤នាក់ (១២%) និយាយថា ត្រូវការម្ហូបអាហារ ហើយកុមារដទៃទៀតលើកឡើងអំពីតម្រូវការ ដូចជា ការដោះបំណុល (ម្នាក់) ទឹកដោះគោសម្រាប់ទារក (ម្នាក់) ម៉ាស៊ីនកិនទឹកអំពៅ (ម្នាក់) ជំនួយឧបត្ថម្ភដើម្បីបើកអាជីវកម្ម (ម្នាក់) និងជួយស្វែងរកការងារធ្វើ (ម្នាក់)។

អំពើហិង្សាលើរាងកាយ

ការមើលឃើញអំពើហិង្សាលើរាងកាយនៅតាមផ្លូវ

មុនពេលពិភាក្សាអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់កុមារ អំពីអំពើហិង្សាលើរាងកាយ មុនដំបូង ក្រុមស្រាវជ្រាវចង់ស្វែងយល់អំពីកម្រិតនៃអំពើហិង្សាដែលកុមារមើលឃើញនៅតាមផ្លូវ។ កុមារភាគច្រើនចំនួន ៥២នាក់ (៧០%) និយាយថា ពួកគេបានមើលឃើញកុមារម្នាក់ទៀតត្រូវគេវាយ ទះតប់ ធ្វើឲ្យឈ្លក់ទឹក ឬរលាកភ្លើងនៅតាមផ្លូវ។ អំពើហិង្សានេះត្រូវបានកើតឡើងទៅលើក្មេងប្រុស ច្រើនជាងក្មេងស្រី (ក្មេងប្រុស ៧៥% និងក្មេងស្រី ៦៣%)។ ក្នុងចំណោមកុមារដែលនិយាយអំពីការមើលឃើញអំពើហិង្សាទាំងនេះនៅលើផ្លូវ មានកុមារ ១១នាក់ (២១%) និយាយថា ពួកគេមើលឃើញអំពើហិង្សានេះស្ទើរតែរាល់ថ្ងៃ។ ចំណែកឯកុមារភាគច្រើន ឬ ៣០នាក់ (៥៨%) និយាយថា ពួកគេមើលឃើញ អំពើហិង្សានេះកើតឡើង "ម្តងម្កាល" តែប៉ុណ្ណោះ។

បទពិសោធន៍នៃអំពើហិង្សាលើរាងកាយនៅតាមផ្លូវ

ទាក់ទងនឹងបទពិសោធន៍ផ្ទាល់ខ្លួនរបស់កុមារទាក់ទងនឹងអំពើហិង្សា កុមារ ៥០នាក់ ឬ ៦៦% និយាយថា ពួកគេជួបអំពើហិង្សាលើរាងកាយនៅតាមផ្លូវ តាមទម្រង់ផ្សេងៗ។ នៅក្នុងចំណោមក្រុមដែលជួបអំពើហិង្សានេះ មាន ៣៥នាក់ជាភេទប្រុស (៦៩%) និង ១៥នាក់គឺជាភេទស្រី (៦០%)។ បន្ថែមពីលើនេះទៀត ស្ទើរតែ ១/៣ (២០នាក់ ឬ ៣១%) លើកឡើងអំពីពេលដែលពួកគេទទួលនូវការធ្វើបាប ឬគំរាមកំហែងដោយអាវុធ។ នៅក្នុងក្រុមនេះ មាន ១៤នាក់ជាភេទប្រុស (៣៦%) និង ៦នាក់ជាភេទស្រី (២៤%)។

កុមារក៏ត្រូវបានសួរអំពីប្រភេទមនុស្សផ្សេងៗនៅក្នុងសហគមន៍របស់ពួកគេ ថាតើពួកគេអាចនឹងមានអំពើហិង្សាពី មនុស្សណាខ្លះ៖ ឪពុកម្តាយ ឬអាណាព្យាបាល "បងធំ" (យុវជនដែលមានអាយុច្រើន ដើងកាង ឬជនគំរាមកំហែង) មនុស្សធំម្នាក់ទៀត ប៉ូលីស និង/ឬ កុមារវ័យស្រករគ្នា។ អំពើហិង្សាលើរាងកាយពីឪពុ កម្តាយត្រូវបានរាយការណ៍ ច្រើនជាងគេដែលមានកុមារ ២០នាក់ (២៦%) និយាយថា ពួកគេបានជួបអំ ពើហិង្សា បែបនេះ។ អំពើហិង្សាពីឪពុក ម្តាយកើតឡើងច្រើនទៅលើក្មេងស្រី បើប្រៀបធៀបជាមួយក្មេងប្រុស ដែលមាន ៥៨% ហើយក្មេងប្រុសមាន ១៥%)។ អំពើហិង្សាលើ

រាងកាយពី "បងធំ" ឬយុវជនដែលអាយុច្រើនជាង/ជើងកាង កើតឡើងច្រើនទីពីរ ដែលមាន ១៩នាក់ (២៤%) និយាយថា ពួកគេធ្លាប់មានបទពិសោធន៍នូវអំពើហិង្សាបែបនេះ ដែលកើតឡើងចំពោះក្មេងប្រុស ច្រើនជាង បើប្រៀបធៀបជាមួយក្មេងស្រី មានក្មេងប្រុស ៣១% (១៨នាក់) លើកឡើងអំពីអំពើហិង្សា ចំណែកឯ ក្មេងស្រីមានតែ ៥% (១នាក់) ប៉ុណ្ណោះ។ មានចំនួនតិចជាង ដែលកុមារ ១៣នាក់ (១៧%) លើកឡើងអំពីអំពើហិង្សា លើរាងកាយដែលប្រព្រឹត្តដោយមនុស្សធំម្នាក់ទៀត ដែលមានក្មេងប្រុសច្រើនជាង ដែលលើកឡើងអំពីអំពើហិង្សា បើប្រៀបធៀបជាមួយក្មេងស្រី (ក្មេងប្រុស ១៩% និងក្មេងស្រី ១១%)។ ចំណែកឯកុមារ ១៣ម្នាក់ទៀត (១៧%) សុទ្ធតែជាក្មេងប្រុស លើកឡើងអំពីការទទួលរងអំពើហិង្សាពីប៉ូលីស ដែលតំណាងឲ្យ ២២% នៃក្មេងប្រុសដែលនៅ ក្នុងការសិក្សានេះ។

ភាពភ័យខ្លាចអំពើហិង្សានៅតាមផ្លូវ

សំណួរត្រូវបានសួរអំពីភាពភ័យខ្លាចអំពើហិង្សារបស់កុមារ នៅតាមផ្លូវ។ កុមារភាគច្រើន ៥២នាក់ (៧០%) និយាយ ថា ពួកគេខ្លាចមនុស្សមកសម្លាប់ ឬធ្វើបាបពួកគេនៅតាមផ្លូវ។ ភាពភ័យខ្លាចនេះត្រូវបានលើកឡើងដោយក្មេងប្រុស ៧៤% (៣៧នាក់) និង ៦៣% នៃក្មេងស្រី (១៥នាក់)។ នៅពេលកុមារទាំងនេះត្រូវបានសួរអំពី ថាតើពួកគេ ខ្លាច នរណាខ្លាំងជាងគេ យើងទទួលបានចម្លើយផ្សេងៗគ្នា។ "មនុស្សធំ" និង/ឬ "អ្នកប្រើគ្រឿងញៀន" ត្រូវបានលើកឡើងច្រើនជាងគេ ដែលកុមារ ១៤នាក់ (២៩%) លើកឡើងថា ពួកគេខ្លាចមនុស្សធំ និង ១៤នាក់ទៀត (២៩%) និយាយថា ពួកគេខ្លាចអ្នកញៀនថ្នាំ។ ក្រៅពីខ្លាចមនុស្សធំ និងអ្នកប្រើថ្នាំញៀន ពួកគេក៏លើកឡើងអំពីការខ្លាចមនុស្សវ័យជំទង់ (បងធំ) ដែលមានកុមារ ៧នាក់ (១៤%) បានលើកឡើង។ ភាពភ័យខ្លាចបងធំត្រូវបានលើកឡើងច្រើនក្នុង ចំណោមក្មេងប្រុស (៦នាក់ ឬ ១៧% គឺជាក្មេងប្រុស បើប្រៀបធៀបនឹង ១នាក់ (៧%) ដែលជាក្មេងស្រី)។ នៅក្នុងនោះផងដែរ ក៏មានលើកឡើងអំពីការទទួលរងអំពើហិង្សាពីកុមារវ័យស្រករគ្នា (៤នាក់បានលើកឡើង) អ្នកជិតខាង (៣នាក់បានលើកឡើង) ឪពុកម្តាយ (៣នាក់បានលើកឡើង) ប៉ូលីស (២នាក់បានលើកឡើង) មេខ្យល់ (ម្នាក់បានលើកឡើង) និងសាច់ញាតិ (ម្នាក់បានលើកឡើង)។

អ្វីដែលលើកឡើងញឹកញាប់បំផុតគឺ ភាពភ័យខ្លាចត្រូវគេវ៉ៃ (២៣នាក់ ឬ ៤២%)។ ភាពភ័យខ្លាចនេះត្រូវបាន លើកឡើងដោយក្មេងប្រុសញឹកញាប់ជាងក្មេងស្រី (៥៣% ជាក្មេងប្រុស និង ២១% ជាក្មេងស្រី)។ ការត្រូវគេលួចប្លន់គឺភាពភ័យខ្លាចភាគច្រើនទីពីរ ដែលកុមារលើកឡើង (១៤នាក់ ឬ ២៥%)។ ការត្រូវគេធ្វើបាបក៏ត្រូវលើកឡើង ដោយចំនួនកុមារប្រហាក់ប្រហែលគ្នាដែរ (១៣នាក់ ឬ ២៤%)។ មានចំនួនតិចតួចផងដែរ ភាពភ័យខ្លាចមិនមានការ ងារធ្វើ ការត្រូវគេសម្លាប់ ការត្រូវគេចាប់រំលោភ ការត្រូវគេលក់ និង "ការត្រូវមូសខាំ" ត្រូវបានកុមារម្នាក់ៗលើកឡើងផងដែរ។





គំនិតយល់ឃើញអំពីភាពងាយរងគ្រោះដោយអំពើហិង្សា

ក្មេងប្រុស និងក្មេងស្រីត្រូវបានសួរអំពីការយល់ឃើញរបស់ពួកគេ អំពីអ្វីដែលពួកគេគិតថាជាកត្តាគ្រោះថ្នាក់សម្រាប់ក្មេងស្រីនៅតាមផ្លូវ និងអំពីអ្វីដែលពួកគេគិតថាគឺជាគ្រោះថ្នាក់សម្រាប់ក្មេងប្រុស។ នេះគឺជាសំណួរបើកដែលអនុញ្ញាត ឲ្យកុមារឆ្លើយតប តាមអ្វីដែលពួកគេ ចង់ឆ្លើយ។ សម្រាប់វិធីសាស្ត្រស្រាវជ្រាវ សំណួរនេះហាក់បីដូចជាច្របូកច្របល់បន្តិចចំពោះកុមារ ព្រោះគំនិតយល់ឃើញ និងតថភាពជាក់ស្តែងពិបាកបែងចែកឲ្យច្បាស់លាស់ នៅក្នុងបរិបទវប្បធម៌សង្គម។ ជាលទ្ធផល មាន "តម្លៃ n" ទាបជាងសម្រាប់អថេរទាំងពីរនេះ សម្រាប់កុមារ ២៥នាក់ ដោយលើកនិយាយអំពីគំ និតយល់ឃើញរបស់ពួកគេថាគ្រោះថ្នាក់សម្រាប់ក្មេងស្រី និង ២៣នាក់និយាយថា គ្រោះថ្នាក់សម្រាប់ក្មេងប្រុស។



ទាក់ទងនឹងគំនិតយល់ឃើញរបស់កុមារអំពីគ្រោះថ្នាក់សម្រាប់ក្មេងស្រី ចម្លើយដូចគ្នាច្រើនបំផុតគឺថា ក្មេងស្រីងាយរងគ្រោះត្រូវគេរំលោភ ដែលកុមារ ៩នាក់បានលើកឡើង។ ជាពិសេស កុមារលើកឡើងបញ្ជាក់អំពីការរំលោភពីអ្នកប្រើថ្នាំញៀននៅតាមផ្លូវ។ ទីពីរ កុមារយល់ថា ក្មេងស្រីងាយរងគ្រោះត្រូវឡានបុក ដែលត្រូវបានលើកឡើងដោយ កុមារ ៥នាក់។ កុមារ ៥នាក់ផ្សេងទៀតលើកឡើងថា ក្មេងស្រីជួបនូ វគ្រោះថ្នាក់នៅតាមផ្លូវ ស្រដៀងនឹងក្មេងប្រុស។ ហើយជាចុងក្រោយ កុមារ ៣នាក់និយាយថា ក្មេងស្រីប្រឈមនឹងគ្រោះថ្នាក់ត្រូវគេជួញដូរ ហើយ ២នាក់និយាយថា ពួកគេប្រឈមនឹងគ្រោះថ្នាក់ត្រូវគេចាប់ខ្លួន។ ទាក់ទងនឹងគ្រោះថ្នាក់ចំពោះក្មេងប្រុស ចម្លើយភាគច្រើននិយាយអំពី គ្រោះថ្នាក់ត្រូវគេវាយដំ ដែលត្រូវបានលើកឡើងដោយកុមារ ៦នាក់ ហើយការត្រូវឡានបុកក៏ត្រូវបានលើកឡើង ដោយកុមារ ៦នាក់ដែរ។ បន្ថែមពីលើនេះ កុមារ ៥នាក់និយាយថា ក្មេងប្រុសជួបគ្រោះថ្នាក់ស្រដៀងនឹងក្មេងស្រីដែរ។ ជាចុងក្រោយ កុមារពីរនាក់និយាយថា ក្មេងប្រុសប្រឈមគ្រោះថ្នាក់ត្រូវគេចាប់ខ្លួន ហើយ ២នាក់ទៀតជឿថា ពួកគេប្រឈមនឹងគ្រោះថ្នាក់ត្រូវចោរប្លន់។

អំពើហិង្សាផ្លូវភេទ

ការសន្ទនាអំពីបញ្ហាផ្លូវភេទ ជាពិសេសអំពើហិង្សាផ្លូវភេទ ពិបាកលើកមកនិយាយជាមួយកុមារវ័ យក្មេង។ ដោយសារយល់បែបនេះ អ្នកសម្ភាសយកចិត្តទុកដាក់ពិសេសក្នុងការធ្វើការសម្ភាសក្នុងផ្នែកនេះ។ បន្ថែមពីលើនេះទៀត លំហូរ នៃការសន្ទនាក្នុងពេលសម្ភាសត្រូវបានរៀបចំឡើងបែបនេះ ដើម្បីឲ្យការសន្ទនាអំពីប្រធានបទទាក់ទងនឹងផ្លូវភេទ និង ការរំលោភបំពានផ្លូវភេទ ត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន បន្ទាប់ពីពិភាក្សាអំពីផ្នែកផ្សេងៗនៅក្នុងជីវិតរបស់ កុមារ និងបន្ទាប់ពីមានការកសាងទំនាក់ទំនងរួចហើយ។ អ្នកសម្ភាសចាប់ផ្តើមការពិភាក្សាដោយសួរកុមារថា តើពួកគេដឹងថា មនុស្សធំនៅក្នុងសហគមន៍របស់ពួកគេ ធ្លាប់បានសុំឲ្យពួកគេធ្វើអ្វីមួយដែលពួកគេមានអារម្មណ៍មិនស្រួលដែរឬទេ។ ការសួរសំណួរបន្ថែមទៀតដើម្បីស៊ើបអង្កេតអំពីកុមារអាយុស្រករគ្នា ដែលអាចនឹងត្រូវបានមនុស្សធំប៉ះពាល់ផ្នែកផ្លូវភេទ ហើយគេលើកយកបញ្ហារំលោភបំពានផ្លូវភេទរបស់ពួកគេមកពិភាក្សា។

កុមារត្រូវបានសួរថាតើមានមនុស្សធំនៅតាមផ្លូវធ្វើអ្វីមួយ ដែលធ្វើឲ្យពួកគេមានអារម្មណ៍មិនស្រួល ឬមិនចូលចិត្តដែរឬទេ។ កុមារចំនួនច្រើនជាង ១/៥ លើកឡើងអំពីស្ថានភាពបែបនេះ។ ទោះបីជាសំណួរនេះមិនបានសួរចំៗអំពីបញ្ហា ផ្លូវភេទរបស់កុមារក៏ដោយ ក៏ប៉ុន្តែ ចម្លើយជាច្រើនរបស់កុមារបានរៀបរាប់ ឬផ្តល់គម្រុយអំពីទម្រង់ផ្សេងៗនៃអំពើ ហិង្សាផ្លូវភេទ។ ក្មេងប្រុស ៥នាក់លើកនិយាយអំពីមនុស្សធំបានចាប់ ឬអង្អែលលេងកន្លែងប្រដាប់ភេទរបស់ពួកគេ ហើយម្នាក់ទៀតនិយាយថា "មនុស្សស៊កប្រដាប់ភេទចូលរន្ធគូទរបស់គាត់"។ ក្មេងប្រុសម្នាក់ទៀតនិយាយថា គាត់ត្រូវ បានហៅឲ្យ "ដើរចូលព្រៃ ឬដើរចុះឡើងនៅពេលយប់" ប៉ុន្តែមិនបាននិយាយលម្អិតអំពីហេតុការណ៍នោះទេ។ ទោះបី ជាក្មេងស្រីមិនសូវរៀបរាប់ដាក់លាក់អំពីអំពើហិង្សាផ្លូវភេទក៏ដោយ ក៏ប៉ុន្តែមានក្មេងស្រី ២នាក់បានផ្តល់គម្រុយអំពី ការរំលោភបំពានផ្លូវភេទដែលអាចកើតឡើង។ ក្មេងស្រីម្នាក់បាននិយាយថា មនុស្សធំម្នាក់សុំគេងជាមួយនាង និង អោបនាង ចំណែកឯកុមារម្នាក់ទៀតនិយាយថា មនុស្សធំម្នាក់ "បានបិទទ្វារ ហើយនៅតែពីរនាក់នៅក្នុងបន្ទប់"។



នៅពេលយើងសួរកុមារត្រង់ៗអំពីការប៉ះពាល់ផ្នែកផ្លូវភេទ ស្ទើរតែ ១/៤ ឬ ១៦នាក់ (២៣%) លើកឡើងអំពីមនុស្ស ធំដែលប៉ះពាល់ពួកគេមិនសមរម្យ នៅកន្លែងប្រដាប់ភេទ។ ការប៉ះពាល់ប្រដាប់ភេទនេះកើតឡើងភាគច្រើនទៅលើក្មេងប្រុស ដែលមានក្មេងប្រុស ១៤នាក់ (៣១%) និយាយអំពីការប៉ះពាល់ផ្លូវភេទ ហើយក្មេងស្រី ២នាក់ (៨%) លើកឡើងដូចគ្នា។ ក្នុងចំណោម ១៦នាក់ដែលលើកឡើងអំពីការប៉ះពាល់ផ្លូវភេទដោយមនុស្សធំ ១១នាក់និយាយថា ការប៉ះពាល់នេះកើតឡើងរវាង ១-៥ដង (ក្មេងប្រុស ១០នាក់ និងក្មេងស្រីម្នាក់)។ បន្ថែមពីលើនេះទៀត ក្មេងប្រុសម្នាក់ថា ការប៉ះពាល់ប្រភេទនេះបានកើតឡើងទៅលើគាត់ "គ្រប់ពេល" ឬ "ជាប្រចាំ"។

កុមារ ៧នាក់ ឬ ១១% និយាយថា បទពិសោធន៍នៃអំពើហិ ង្សាផ្លូវភេទនេះកើតឡើងលើសពីការប៉ះពាល់ទៅទៀត។ នៅក្នុងចំណោមក្រុមកុមារដែលនិយាយបែបនេះ មានក្មេងប្រុស ៦នាក់ (១៤% នៃក្មេងប្រុស) និងក្មេងស្រីម្នាក់ (៤% នៃក្មេងស្រី)។ គ្រប់កុមារទាំងអស់លើកឡើងអំពីស្ថានភាព ដែលពួកគេត្រូវបានបង្ខំផ្នែករាងកាយឲ្យធ្វើរឿងផ្នែកផ្លូវភេទ។ នៅក្នុងចំណោមកុមារទាំងនេះ មាន ៣នាក់ដែលនិយាយថា រឿងនេះកើតឡើង ១-៥ដង ហើយម្នាក់និយាយ ថា រឿងនេះកើតឡើង "គ្រប់ពេល" ឬ "ជាប្រចាំ"។

អំពើកេងប្រវ័ញ្ចធ្វើអាជីវកម្មផ្លូវភេទ

ការសិក្សានេះក៏ព្យាយាមស្វែងយល់ អំពីការកើតឡើងនៃអំពើកេងប្រវ័ញ្ចធ្វើអាជីវកម្មផ្លូវភេទលើកុមារ 'CSEC' ក្នុងចំណោមកុមារដែលនៅតាមផ្លូវ។ កុមារ ៧នាក់ ឬ ១០% និយាយអំពីស្ថានភាពដែលពួកគេ គ្រួសាររបស់ពួកគេ ឬមនុស្សម្នាក់ទៀតដែលបានទទួលលុយ ម្ហូបអាហារ ឬអំណោយ ដើម្បីឲ្យកុមារដោះដូរសេវាផ្លូវភេទជាមួយមនុ ស្សធំ។ ក្នុងចំណោមកុមារ ៧នាក់ មានក្មេងប្រុស ៦នាក់ (១៣% នៃក្មេងប្រុស) និងក្មេងស្រីម្នាក់ (៤% នៃក្មេងស្រី)។ ក្នុងចំណោមសម្ភារៈដែលត្រូវបានដោះដូរជាមួយសេវាផ្លូវភេទ កុមារបានរៀបរាប់អំពីការទទួលនូវសម្ភារៈមួយចំនួន ដូចជាអាហារ ជម្រក និងលុយ។ កុមារម្នា ក់និ យាយថា គាត់បានទទួលមីឆាមួយចាន និងលុយ ៨បាត ចំណែកឯម្នាក់ ទៀតនិយាយថា គាត់ត្រូវបានគេហៅឲ្យគេងក្នុងផ្ទះសំណាក់មួយយប់។

រឿងអាសអាភាស

រឿងអាសអាភាសអាចត្រូវបានប្រើជាមធ្យោបាយមួយដើម្បី "ធ្វើឲ្យមានអារម្មណ៍ផ្នែកផ្លូវភេទ" ឬល្បួងកុមារ ដើម្បីប្រព្រឹត្តអំពើផ្នែកផ្លូវភេទ។ ដោយសារយល់បែបនេះ កុមារត្រូវបានសួរអំពីហេតុការណ៍ដែលមនុស្សធំនៅតាមផ្លូវ បង្ហាញរូបភាព ឬវីដេអូអាសអាភាសឲ្យពួកគេមើល។

កុមារស្ទើរតែ ១/៣ ឬ ២២នាក់ (៣១%) និយាយថា មនុស្សធំបង្ហាញរូបភាព ឬវីដេអូអាសអាភាសឲ្យមើល។ នៅក្នុងចំណោមកុមារទាំងនេះមានក្មេងប្រុស ១៧នាក់ (៣៦%) និងក្មេងស្រី ៥នាក់ (២១%)។ នៅក្នុងចំណោមកុមារ ២២ នាក់ មានកុមារ ១០នាក់ ឬ ៤៥% និយាយថា រូបភាព ឬវីដេអូទាំងនេះត្រូវបានមនុស្សដែលពួកគេមិនដែលស្គាល់ បង្ហាញឲ្យពួកគេមើល ហើយ ៥នាក់ ឬ ២៣% និយាយថា អ្នកធ្វើការជាមួយគ្នានៅតាមផ្លូវបង្ហាញរូបភាព ឬរឿង អាសអាភាសឲ្យពួកគេមើល។ មានមួយចំនួនតូចបានលើកឡើងថា មនុស្សវ័យជំទង់បង្ហាញរូបភាព ឬវីដេអូអាសអាភាសឲ្យពួកគេមើល (៣នាក់) មនុស្សនៅហាងអ៊ីនធើណិត (២នាក់) និង "មិត្តភ័ក្ត" (២នាក់)។

អំពើហិង្សាផ្លូវអារម្មណ៍

អំពើហិង្សាផ្លូវអារម្មណ៍ត្រូវបានយល់ថា ជាទម្រង់មួយនៃអំពើរំលោភបំពានផ្នែកផ្លូវចិត្ត ដែលមានទំនោរខ្ពស់ក្នុងការបំផ្លាញសុខភាពផ្លូវចិត្តរបស់កុមារ និង/ឬ សុខមាលភាព ក៏ដូចជា ការលូតលាស់ផ្នែកសីលធម៌ ផ្នែកព្រលឹងវិញ្ញាណ ឬការលូតលាស់ផ្នែកសង្គម (UNICEF, 2013)។ ការវាយតម្លៃទៅលើអំពើហិង្សាផ្លូវអារម្ម ណ៍នៅក្នុងការស្រាវជ្រាវនេះផ្តោតទៅលើចំណុចទូទៅចំនួន ៣ រួមមានៈ ការគំរាមកំហែង និងការបៀតបៀន ការរំលោភបំពានផ្នែកពាក្យសម្តី (នៅតាមផ្លូវ និងនៅផ្ទះ) និងការវាយតម្លៃផ្ទាល់ខ្លួនអំពីអារម្មណ៍ និងការឆ្លើយតបរបស់ពួកគេចំពោះអារម្មណ៍អវិជ្ជមាន។

ការបៀតបៀន និងអំពើហិង្សាផ្នែកពាក្យសម្តីនៅតាមផ្លូវ

កុមារស្ទើរតែពាក់កណ្តាល (២៩នាក់ ឬ ៤៣%) និយាយអំពីមនុស្សមួយចំនួននៅតាមផ្លូវដែលយកលុយ ឬវត្ថុផ្សេងៗ ពីពួកគេដោយគំរាមកំហែង ឬបំភ័យពួកគេ។ លើសពីនេះ កុមារភាគច្រើន ៥៩នាក់ ឬ ៨៣% លើកឡើងអំពីស្ថាន ភាពផ្សេងៗដែលមនុស្សនៅតាមផ្លូវស្រែកដាក់ពួកគេ ឬស្រែកជេរពួកគេ។ ទោះបីជា ទាំងក្មេងប្រុស និងក្មេងស្រីលើកឡើងអំពីបទពិសោធន៍នេះក៏ដោយ ក៏ប៉ុន្តែក្មេងប្រុសបានលើកឡើងច្រើនជាង (៨៧% នៃក្មេងប្រុស និង ៧៥% នៃក្មេងស្រី)។ កុមារភាគច្រើនលើកឡើងថា ពួកគេជួបនូវការរំលោភបំពានផ្នែកពាក្យសម្តីភាគច្រើនពីកុមារអាយុស្រករគ្នា (១២នាក់ ឬ ៤០%) និងពីប៉ូលីស (១០នាក់ ឬ ៣៣%)។

មានការសម្គាល់ឃើញថា ការរំលោភបំពានផ្នែកពាក្យសម្តី មានភាពខុសគ្នារវាងក្មេងប្រុស និងក្មេងស្រី។ ចំពោះក្មេងប្រុស ការរំលោ ភបំពានផ្នែកពាក្យសម្តីភាគច្រើននៅតាមផ្លូវកើតឡើងដោយសារប៉ូលីស ដែលមានក្មេងប្រុស ៩នាក់ (៤១%) លើកឡើងអំពីទម្រង់នៃអំពើហិង្សានេះ។ ក្រៅពីនេះ ក្មេងប្រុស ៧នាក់ (៣២%) លើកឡើង អំពីអំពើហិង្សាផ្នែកពាក្យសម្តីពីកុមារអាយុស្រករគ្នា។ មានក្មេងប្រុសមួយចំនួនតូចនិយាយថា ពួកគេទទួលអំពើហិង្សាពី "មនុស្សដែលធ្វើការ

នៅតាមផ្លូវដទៃទៀត" (៤នាក់ ឬ ១៨%) និងពីសន្តិសុខ (២នាក់ ឬ ៩%)។ សម្រាប់ក្មេងស្រី អំពើហិង្សាផ្នែកពាក្យ សម្តីនៅតាមផ្លូវកើតឡើងពីកុមារអាយុស្រករគ្នា ដែលត្រូវបានលើកឡើងដោយកុមារចំនួន ៥នាក់ (៦៣%)។ បន្ទាប់ពីនេះ ក្មេងស្រីម្នាក់និយាយថា នាងទទួលអំពើហិង្សាពីប៉ូលីស ម្នាក់ទៀតនិយាយថាទទួល អំពើហិង្សាពី "អ្នកធ្វើការនៅតាមផ្លូវផ្សេងទៀត" និងម្នាក់ទៀតលើកឡើងពីអំពើហិង្សាពីបុគ្គលិកសន្តិសុខ។ ភាគច្រើន កុមារហាក់បីដូចជាបង្ហាញថា បទពិសោធន៍នៃអំពើហិង្សាដោយពាក្យសម្តីនៅតាមផ្លូវ ដោយសារតែពួកគេ ធ្វើការ/រស់នៅតាមផ្លូវ។ ក្រៅពីនេះ កុមារលើកឡើងថាពួកគេទទួលអំពើហិង្សា ដោយសារពួកគេមិនធ្វើការ ឬមិនសូវខំប្រឹងធ្វើការនៅតាមផ្លូវ។ ជាចុងក្រោយ កុមារលើកឡើងអំពីការឈ្លោះគ្នាដោយពាក្យសម្តីជាមួយកុមារផ្សេងទៀត ឬមនុស្សវ័យជំទង់នៅតាមផ្លូវ ដោយសារការប្រើប្រាស់គ្រឿងញៀន មិនចែកចាយគ្រឿងញៀន និងការបែង ចែកប្រាក់ដែលរកបានមិនស្មើរគ្នា និងមានហេតុផលផ្សេងទៀត។

អំពើហិង្សាដោយពាក្យសម្តីនៅផ្ទះ

នៅក្នុងផ្ទះ កុមារ ៥១នាក់ (៨០%) លើកឡើងនូវស្ថានភាពដែលមនុស្ស ស្រែក ឬជេរពួកគេ ដែលភាគច្រើនគឺ ជាឪពុកម្តាយបង្កើត ឬ ឪពុកម្តាយចុង (៧០%) ឬ យាយតា (១៨%)។ នៅពេលយើងសួរថាហេតុអ្វីបានជាមនុស្សទាំងនេះ ស្រែកដាក់ពួកគេ កុមារភាគច្រើន (១៦នាក់ ឬ ៦៤% នៃកុមារដែលឆ្លើយ) និយាយថា ឪពុកម្តាយ ឬអាណាព្យាបាល មានអំពើហិង្សា ព្រោះពួកគេមានអារម្មណ៍ថា កុមារនេះមិនខំប្រឹងធ្វើការ មិនរកលុយបានគ្រប់គ្រាន់ ខ្ជិលច្រអូស ឬ មិនធ្វើកិច្ចការផ្ទះ។ កុមារមួយចំនួនតូចចំនួន ៥នាក់ (២០%) និយាយថា គេស្រែកឲ្យគាត់ដោយសារ គាត់មិនមកផ្ទះ ៣នាក់ទៀតនិយាយថា គេស្រែកដាក់ដោយសារពួកគាត់មិនស្តាប់ការណែនាំ ហើយម្នាក់និយាយថា ឪពុកម្តាយ ឬ អ្នកមើលថែស្រែកឲ្យគាត់នៅពេលពួកគេស្រវឹង។

សុខភាព

សុខភាពផ្លូវអារម្មណ៍

ទាក់ទងនឹងសុខភាពផ្លូវអារម្មណ៍ កុមារទាំងនេះត្រូវបានសុំឲ្យឆ្លុះបញ្ចាំងអំពីបទពិសោធន៍ផ្សេងៗនៅតាមផ្លូវ ហើយត្រូវបានសួរថាតើ បទពិសោធន៍ទាំងនេះប៉ះពាល់អារម្មណ៍ ឬអាកប្បកិរិយារបស់ពួកគេដោយរបៀបណា។ នេះគឺជា សំណួរបើក ហើយកុ មារអាចឆ្លើយតបតាមរបៀបណាដែលពួកគេចង់ឆ្លើយ ទោះបីជាចម្លើយវិជ្ជមាន អវិជ្ជមាន ឬ អព្យាក្រិត។ កុមារភាគច្រើនដែលឆ្លើយ មាន ១៩នាក់ (៦៦%) លើកឡើងអំពីឥទ្ធិពលវិជ្ជមាន រួមមាន សមត្ថភាពក្នុង ការបង្កើតទំនាក់ទំនង ឬបង្កើតមិត្តភ័ក្តថ្មីៗនៅតាមផ្លូវ។ កុមារដទៃទៀតលើកឡើងអំពី សមត្ថភាពក្នុងការរកលុយ ឬមានសេរីភាពច្រើន ដោយសារតែការរស់នៅតាមផ្លូវ។ ស្ទើរតែ ១/៤ ឬ កុមារ ៧នាក់ (២៤%) លើកឡើងអំពីផលប៉ះពាល់អវិជ្ជមានទាក់ទងនឹងការរស់នៅ/ធ្វើការតាមផ្លូវ រួមមាន ការប្រើគ្រឿងញៀន ការគ្មានការអប់រំ និងការគ្មានលុយ។ ជាចុងក្រោយ កុមារ ៣នាក់ (១០%) លើកឡើងថា បទពិសោធន៍របស់ពួកគេនៅតាមផ្លូវមិនប៉ះពាល់ដល់អារម្មណ៍ ឬអាកប្បកិរិយារបស់ពួកគេទេ។

បន្ថែមពីលើនេះទៀត កុមារត្រូវបានសួរអំពីជំនួយផ្លូវអារម្មណ៍ដែ លពួកគេមាន នៅពេលពួកគេមានអារម្មណ៍ខឹង ឬកើតទុក្ខ។ ទោះបីជាកុមារចំនួន ៥២នាក់ (៧៥%) និយាយថា ពួកគេអាចលើកអំពីមនុស្សម្នាក់ដែលពួកគេអាចទៅរក បាន ក៏ប៉ុន្តែ ១៧នាក់ (២៥%) និយាយថា ពួកគេមិនមាននរណាដែលពួកគេទៅរកបានទេ។ ក្នុងចំណោមកុមារដែ ល និយាយថា ពួកគេមានអ្នកដែលអាចជួយពួកគេបាន នៅពេលពួកគេមានអារម្មណ៍ខឹង ឬកើតទុក ភាគច្រើន ២៨នាក់ (៦១%) និយាយថា ពួកគេមានសមាជិកគ្រួសារ ឬអ្នកថែទាំ រួមមាន ឪពុកម្តាយ បងប្អូនបង្កើត ឬមីង ឬពូ ដែលអាច ទទួលជំនួយបាន។ កុមារផ្សេងទៀត ចំនួន ១៨នាក់ (៣៩%) និយាយថា ពួកគេទៅរកក្រុមមិត្តភ័ក្តរបស់ពួកគេ នៅពេលពួកគេកើតទុក្ខ ឬមានអារម្មណ៍ខឹង។

សុខភាពទូទៅ

កុមារនៅតាមផ្លូវភាគច្រើន ចំនួន ៦៣នាក់ (៨៣%) លើកឡើងអំពីជំងឺមួយចំនួន ដូចជា ជំងឺក្តៅខ្លួន ផ្តាសាយ ឈឺក្បាល ឈឺពោះ និងករណីរលាកទងសួត។ ជំងឺដែលត្រូវបានលើកឡើងច្រើនជាងគេ គឺជំងឺក្តៅខ្លួន ដែលកុមារកុមារ ៣៨នាក់ (៥៣%) បានរៀបរាប់អំពីលក្ខណៈនៃជំងឺ។ ក្នុងចំណោម ៣៨ករណី មានករណីជំងឺគ្រុនឈាមធ្ងន់ធ្ងរចំនួន ៥ ករណី និងករណីគ្រុណពោះវៀន ៤ករណី។ ចុងក្រោយ កុមារ ២៤នាក់ (៣៣%) បានរាយការណ៍ច្រើនអំពីជំងឺផ្តាសាយ។



បន្ថែមពីលើនេះទៀត កុមារត្រូវបានសួរថាតើពួកគេស្វែងរកការព្យាបាលនៅកន្លែងណា នៅពេលពួកគេឈឺ។ កុមារភាគច្រើន ៣៦នាក់ (៦០%) និយាយថា ពួកគេទិញថ្នាំពីឱសថដ្ឋាន ១៨នាក់ (៣០%) និយាយថា ទៅជួបពេទ្យ ហើយ ២នាក់ (៣%) និយាយថា ពួកគេសុំថ្នាំពីអង្គការ ហើយ ៤នាក់ (៧%) និយាយថា ពួកគេមិនបានទទួលការ ព្យាបាលទេ។ ក្នុងចំណោមកុមារដែលលើកឡើងអំពីជំងឺគ្រុនឈាម ជំងឺគ្រុនពោះវៀន ឬជំងឺរលាកទងសួតក្នុងរយៈពេល ៣ខែ កុមារចំនួន ៧នាក់ (៧៧%) និយាយថា ពួកគេបានទៅជួបគ្រូពេទ្យ ចំណែកឯ ២នាក់ (២២%) និយាយថា ពួកគេគ្រាន់តែទិញថ្នាំពីឱសថដ្ឋានប៉ុណ្ណោះ។

សុខភាពផ្លូវភេទ

ក្នុងចំណោមកុមារដែលមានអាយុ ១៣ឆ្នាំ ដល់ ១៨ឆ្នាំ មានកុមារតែចំនួនតូចប៉ុណ្ណោះ ចំនួន ៧នាក់ (២០%) ដែល បានទទួលការអប់រំសុខភាពផ្លូវភេទ។ បើគិតអំពីគ្រប់អាយុទាំងអស់ មានកុមារតែ ១១% ប៉ុណ្ណោះដែលបានទទួលការ អប់រំអំពីសុខភាពផ្លូវភេទ។ កុមារត្រូវបានសួរអំពីចំណេះដឹងទូទៅរបស់ពួកគេអំពីមេរោគអេដស៍ ដែលជាកត្តាប្រឈម នៃសុខភាពផ្លូវភេទ។ កុមារភាគច្រើន ៣៩នាក់ (៥៦%) លើកឡើងថា ពួកគេមិនដែលបានលឺអំពីជំងឺនេះទេ ដូច្នេះពួកគេមិនបានដឹងអំពីកត្តាគ្រោះថ្នាក់ទាំងនេះទេ។ ក្នុងចំណោមកុមារដែលនិយាយថាពួកគេធ្លាប់បានលឺអំពី មេរោគអេដស៍ កុមារច្រើនជាងពាក់កណ្តាល ១៨នាក់ (៥៨%) និយាយថា មេរោគអេដស៍ឆ្លងតាមការរួមភេទ ហើយ ៧នាក់ (២៣%) និយាយថា មេរោគ

អេដស៍ឆ្លងតាមឈាម។ កុមារមួយចំនួនតូចចំ នួន ៣នាក់និយាយថា ពួកគេអត់ដឹង អំពីការឆ្លងនៃមេរោគអេដស៍នោះទេ។ កុមារម្នាក់លើកឡើងថា មេរោគអេដស៍ឆ្លងតាមការធ្វើក្រចក ហើយម្នាក់ទៀតនិយាយថា វាឆ្លងតាមការញ៉ាំអាហាររួមគ្នា។

ការប្រើប្រាស់សារធាតុញៀន

នៅក្នុងផ្នែកផ្សេងនៃការសន្ទនា កុមារបានលើកឡើងរួមគ្នាអំពីការប្រើប្រាស់គ្រឿងញៀន និងអ្នកប្រើគ្រឿងញៀនជាប្រភពនៃអំពើហិង្សា និងឧបសគ្គដល់ការលូតលាស់ផ្នែករាងកាយ។ អ្វីដែលគួរឲ្យកត់សម្គាល់គឺថា ការប្រើប្រាស់សារធាតុញៀន (គ្រឿងស្រវឹង ការ និងម៉ាទឹកកក) ហាក់បីដូចជាទាក់ទងនឹងយេនឌ័រជាក់លាក់ច្រើនជាង ហើយក្មេងស្រី ៥នាក់ប៉ុណ្ណោះដែលនិយាយថា បានប្រើសារធាតុញៀនទាំងនេះ។

គ្រឿងស្រវឹងគឺជាសារធាតុដែលត្រូវបានប្រើច្រើនបំផុត ចំពោះយុវជនដែលនៅតាមផ្លូវ ដែលមានកុមារ ២៩នាក់ (៣៨%) និយាយថា បានប្រើសារធាតុ ញៀនខ្លះ។ ការត្រូវបានប្រើដោយកុមារច្រើនជាង ១/៤ ឬ ១៩នាក់ (២៧%) ហើយក្នុងចំណោមចំនួនកុមារទាំងនេះ មានក្មេងប្រុសតែម្នាក់គត់។ ដោយគិតដល់ក្មេងប្រុសទាំងអស់ មានក្មេងប្រុស ១៨នាក់ ឬ ៤០% នៃក្មេងប្រុសប្រើការ ហើយ ៨នាក់ (១៨%) និយាយថា ពួកគេប្រើ "ញឹកញាប់" ៤នាក់ (៩%) និយាយថា ពួកគេប្រើ "ញឹកញាប់ណាស់" ហើយក្មេងប្រុស ២នាក់ (៥%) និយាយថា ពួកគេ "តែងតែ" ប្រើ។ អាយុ ជាមធ្យមដែលកុមារចាប់ផ្តើមប្រើការគឺអាយុ ១០.៨ឆ្នាំ ដែលកុមារអាយុតិចជាងគេគឺអាយុ ៦ឆ្នាំ នៅពេលកុមារនេះ ចាប់ផ្តើមប្រើការ ហើយកុមារអាយុច្រើនជាងគេគឺអាយុ ១៤ឆ្នាំ។

ការប្រើ "ម៉ាទឹកកក" ឬមេតាហ្វីតាមីនគ្រីស្តាល់ត្រូវបានលើកឡើងដោយកុមារចំនួន ១២នាក់ (១៨%) ហើយនៅក្នុងចំណោមក្រុមនេះ អ្នកដែលប្រើទាំងអស់គឺជាក្មេងប្រុស។ ទាក់ទងនឹងក្មេងប្រុស ក្មេងប្រុស ១២នាក់តំណាងឲ្យ ២៩% នៃក្មេងប្រុសទាំងអស់។ អាយុជាមធ្យមដែលក្មេងប្រុសចាប់ផ្តើមប្រើមេតាហ្វីតាមីនគឺអាយុ ១២.៦ឆ្នាំ ដែលកុមារអាយុតិចជាងគេគឺអាយុ ៨ឆ្នាំ នៅពេលកុមារនេះចាប់ផ្តើមប្រើថ្នាំ ហើយកុមារដែលអាយុច្រើនជាងគេគឺអាយុ ១៦ឆ្នាំ។

បន្ថែមពីលើនេះ កុមារត្រូវបានសុំឲ្យពិភាក្សាអំពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ទាំំងផលប៉ះពាល់វិ ជ្ជមាន និងអវិជ្ជមាន។ ជាទូទៅ កុមារហាក់បីដូចជាយល់ដឹងទូលំទូលាយអំពីផលប៉ះពាល់អវិជ្ជមាន នៃការប្រើប្រាស់សារធាតុញៀនទៅលើសុខភាព និងទំនាក់ទំនងរបស់ពួកគេ និងសង្គមទាំងមូល។ ក្នុងចំណោមផលប៉ះពាល់អវិជ្ជមានដែលបាន

លើកឡើង "ការមានសុខភាពមិនល្អ" ឬ "ការប៉ះពាល់ ខួរក្បាល" ត្រូវបានលើកឡើងច្រើនបំផុតដោយកុ មារចំនួន ១៣នាក់ (៥២%) ដែលនិយាយថា មានផលប៉ះពាល់អវិជ្ជមាន។ ក្រៅពីនេះ "ការញៀនថ្នាំ" ត្រូវបានលើកឡើងដោយកុមារ ៤នាក់ (១៦%) "ការបាត់បង់ការគ្រប់គ្រង" លើកឡើងដោយកុមារ ២នាក់ (៨%) និង "ការត្រូវមនុស្សស្អប់" ត្រូវបានលើកឡើងដោយកុមារ ២នាក់ (៨%) ក្នុងចំណោមការលើកឡើងផ្សេងទៀត។

បន្ថែមពីលើការយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមាននៃសារធាតុញៀន ចំនួនក្មេងប្រុសជិតពាក់កណ្តាល (១៧នាក់ ឬ ៤៩%) និយាយថា ពួកគេបានព្យាយាមឈប់ប្រើគ្រឿងញៀនពីមុនមក ហើយក្មេងប្រុសជាងពាក់កណ្តាល (១៩នាក់ ឬ ៥៩%) និយាយថា ពួកគេកំពុងព្យាយាមឈប់ប្រើគ្រឿងញៀន។ ក្នុងចំណោមកុមារដែ លបានព្យាយាមឈប់ប្រើគ្រឿងញៀន កុមារ ៦នាក់និ យាយថា ពួកគេបានព្យាយាមឈប់ប្រើការ ហើយ ៥នាក់និយាយថា ពួកគេបានព្យាយាម ឈប់ប្រើមេតាហ្វីតាមីន។ ទាក់ទងនឹងក្មេងស្រី មិនមានទិន្នន័យគ្រប់គ្រាន់អំពីក្មេងស្រីដែលនិយាយថា ពួកគេប្រើគ្រឿងញៀនទេ លើកលែងតែក្មេងស្រីម្នាក់ដែលនិយាយថាបានប្រើការ។

ក្មេងប្រុសត្រូវបានសួរអំពីអ្វីដែលពួកគេជឿថានឹងជួយឲ្យពួកគេឈប់ប្រើគ្រឿងញៀន។ ក្មេងប្រុសមួយចំនួនធំ ៦នាក់ (៤៣%) ជឿថា ការនៅផ្ទះ ឬការមានទំនាក់ ទំនងរឹងមាំជាមួយគ្រួសាររបស់ពួកគេ នឹងជួយឲ្យពួកគេឈប់ប្រើគ្រឿងញៀន។ ក្មេងប្រុសដទៃទៀត (២នាក់) និយាយថា ការអប់រំមានភាពចាំបាច់ ការទទួលជំនួយពីអង្គការ (កុមារ ២នាក់) និង ការគ្មានលុយចាយ (២នាក់) ត្រូវបានលើកឡើងថាអាចនឹងជួយឲ្យពួកគេអាចឈប់ប្រើគ្រឿងញៀនបាន។ បន្ថែម ពីលើនេះទៀត ជាង ១/៣ មានកុមារ ៥នាក់ (៣៦%) លើកឡើងថា ពួកគេមិនដឹងថានឹងមានអ្វីអាចជួយឲ្យពួកគេ ឈប់ប្រើគ្រឿងញៀននោះទេ។

ការពិភាក្សា

ការធ្វើចំណាកស្រុក

ប៉ោយប៉ែតបានក្លាយជាតំបន់គោលដៅដ៏សំខាន់មួយសម្រាប់កម្មករចំណាកស្រុក ដែលស្វែងរកអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច មួយផ្នែកដោយសារឱកាសនៃការវិនិយោគបរទេសខ្នាតធំ និងអាជីវកម្មឆ្លងដែននៅក្នុងដំបន់សេដ្ឋកិច្ចពិសេស (Special Economic Zone (SEZ))។ តថភាពនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងទិន្នន័យ ដែលកុមារស្ទើរតែ ២/៣ (៦៣%) លើកឡើងអំពីការធ្វើចំណាកស្រុកទៅប៉ោយប៉ែតពីខេត្តក្រុងផ្សេងៗក្នុងប្រទេសកម្ពុជា ដែលស្ទើរតែកុមារទាំងអស់ (៩៨%) ធ្វើចំណាកស្រុកដើម្បីរកការងារធ្វើ ឬដើម្បីមូលហេតុផ្នែកហិរញ្ញវត្ថុផ្សេងទៀត។ ក្រៅពីការធ្វើចំណាកស្រុកទៅប៉ោយប៉ែត កុមារមួយចំនួនក៏លើកឡើងអំពីការធ្វើចំណាកស្រុករហូតទៅដល់ប្រទេសថៃ។ អស់រយៈពេលជាង ១ទសវត្សរ៍កន្លងមកនេះ គោលនយោបាយរបស់រដ្ឋាភិបាលថៃ មានការលំបាកកាន់តែខ្លាំងឡើង សម្រាប់អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួនក្នុងទីក្រុង។ នៅក្នុងករណីជាច្រើន ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន មិនត្រូវបានចែកឲ្យដាច់ពីជនចំណាកស្រុកខុសច្បាប់ទេ ដែលធ្វើឲ្យ ពួកគេងាយប្រឈមត្រូវប៉ូលីសចាប់ខ្លួន និងឃុំខ្លួន (UNHCR, 2008)។

ការធ្វើចំណាកស្រុកទៅប៉ោយប៉ែត

ការធ្វើចំណាកស្រុកធ្វើឲ្យកុមារប្រឈមនឹងភាពងាយរងគ្រោះជាច្រើន ទាំងនៅពេលទៅដល់ទីដៅ និងនៅតាមផ្លូវធ្វើចំណាកស្រុក ជាពិសេសនៅពេលពួកគេធ្វើចំណាកស្រុកម្នាក់ឯង។ របាយការណ៍នៃអំពើជួញដូរមនុស្សរបស់សហរដ្ឋអាមេរិចឆ្នាំ ២០១៦ បានគូសបង្ហាញថា កុមារត្រូវបានជួញដូរទៅតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ព្រំដែន ដូចជា តំបន់ព្រំដែនប៉ោយប៉ែត (ក្រសួងការបរទេសសហរដ្ឋអាមេរិច 2016)។ ទាក់ទងនឹងអំពើកេងប្រវ័ញ្ចធ្វើអាជីវកម្មផ្លូវភេទ និងអំពើរំលោភបំពានលើកុមារ (CSEA) អំពើជួញដូរត្រូវបានរាយការណ៍ថាមានកំណើនកើនឡើង ដើម្បីបំពេញតម្រូវការនៃ

ភ្ញៀវទេសចរណ៍ ជនចំណាកស្រុក និងពលករបរទេស ដែលចង់បានសេវាផ្លូវភេទពីកុមារ (2016) ដែលភាពងាយរងគ្រោះកើតឡើងនៅតំបន់សេដ្ឋកិច្ចពិសេស ដូចជា តំបន់ប៉ោយប៉ែត (ECPAT, 2016)។

ក្នុងចំណោមអ្នកដែលធ្វើចំណាកស្រុកក្នុងតំបន់ប៉ោយប៉ែត ភាគច្រើន (៥៨%) បង្ហាញថា ធ្វើចំណាកស្រុកចន្លោះអាយុ ៤ និង ៩ឆ្នាំ។ មានតែកុមារចំនួន ៣នាក់ប៉ុណ្ណោះដែលបង្ហាញថា ពួកគេធ្វើចំណាកស្រុកតែម្នាក់ឯង ឬជាមួយមិត្តភ័ក្ត ហើយកុមារទាំង ៣នាក់នេះសុទ្ធតែមានអាយុច្រើន ចន្លោះ ១៣ឆ្នាំ និង ១៨ឆ្នាំ។ បន្ថែមពីលើនេះទៀត កុមារដែល មានអាយុ ១០ឆ្នាំ ឬច្រើនជាង នៅក្នុងពេលធ្វើចំណាកស្រុក មាន ៥៥% ប្រឈមនឹងការរស់នៅតាមផ្លូវ និង ២៨% អាចនឹងមានការរាយការណ៍អំពីបទពិសោធន៍នៃអំពើហិង្សាផ្លូវភេទ បើប្រៀបធៀបជាមួយកុមារដែលធ្វើចំណាកស្រុក មុនអាយុ ១០ឆ្នាំ។ ចំណុចនេះបង្ហាញអំពីទំនាក់ទំនងគួរឲ្យកត់សម្គាល់ រវាងអាយុដែលកុមារធ្វើចំណាកស្រុក និងភាព ងាយរងគ្រោះរបស់ពួកគេនៅក្នុងលំនៅដ្ឋាន និងភាពងាយរងគ្រោះចំពោះអំ ពើហិង្សាផ្លូវភេទ។ និយាយម្យ៉ាងទៀតថា កុមារដែលធ្វើចំណាកស្រុកមានវ័យកាន់តែច្រើន ពួកគេក៏កាន់តែងាយគេងនៅតាមផ្លូវ និងជួបនូវបទពិសោធន៍នៃអំពើហិង្សាផ្លូវភេទ។ ចំណុចនេះហាក់បីដូចជាផ្ទុយនឹងគំនិតយល់ឃើញថា កុមារដែលមានអាយុច្រើនមិនសូវប្រឈម នឹងគ្រោះថ្នាក់នៅពេលធ្វើចំណាកស្រុកដូចជាកុមារតូចៗនោះទេ។ ទោះបីជាចំណុចនេះអាចពិតមែនក៏ដោយ ក៏យើងគួរគិតផងដែរថា កុមារធំៗអាចនឹងមិនសូវបានទទួលការថែទាំ និងការឃ្លាំមើលទេ ដោយសារការយល់ឃើញថា ពួកគេមានសមត្ថភាពអាចមើលថែខ្លួន ដូច្នេះធ្វើឲ្យពួកគេងាយប្រឈមនឹងអំពើហិង្សាផ្នែកផ្លូវភេទ និងលំនៅដ្ឋានអសន្តិសុខ។ ត្រង់ចំណុចនេះ ត្រូវការធ្វើការស្រាវជ្រាវបន្ថែមទៀត។

ការឆ្លងដែនដើម្បីស្វែងរកការងារធ្វើ

កុមារភាគច្រើនដែលចូលរួមឆ្លើយ (៧១%) ឆ្លងដែនទៅប្រទេសថៃ ដើម្បីស្វែងរកឱកាសការងារផ្សេងៗ។ កុមារដែលពាក់ព័ ន្ធនៅតាមផ្លូវភាគច្រើននៅក្នុងគំរូសំណាកនេះ ហាក់បីដូចជាស្ថិតនៅក្នុងតំបន់ព្រំដែន និងមិនបានធ្វើចំណាកស្រុកទៅប្រទេសថៃទេ។ នៅពេលកុមារឆ្លងព្រំដែនជាញឹកញាប់ ពួកគេឆ្លងនៅពេលថ្ងៃ ហើយពេ លខ្លះស្នាក់នៅមួយយប់ ដើម្បីធ្វើការងារផ្សេងៗនៅតាមផ្លូវនៅម្ខាងទៀតនៃព្រំដែន។ អ្វីដែលគួរឲ្យកត់សម្គាល់ក្នុងចំណោមកុមារទាំងនេះ គឺភាពងាយរងគ្រោះនៃអំពើហិង្សាជាពិសេស អំពើហិង្សាលើរាងកាយ និងផ្លូវភេទ។

បន្ថែមពីលើកុមារចំនួន ១៤នាក់ (២៦%) ដែលលើកឡើងអំពីអំពើហិង្សាលើរាងកាយពីសំណាក់ប៉ូលីស ទិន្នន័យបែបគុណវិស័យក៏ឆ្លុះបញ្ចាំងនូវបទពិសោធន៍ និងការខ្វល់ខ្វាយអំពីអំពើហិង្សាពីប៉ូលីស និងបុគ្គលិកសន្តិសុខថៃដែរ នៅពេលពួកគេធ្វើការនៅក្នុងប្រទេសថៃ។ លើសពីនេះទៀត ទិន្នន័យបង្ហាញថា កុមារដែលឆ្លងដែនទៅធ្វើការនៅប្រ ទេសថៃមានចំនួន ២.១ដង ងាយនឹងរាយការណ៍អំ ពីអំពើហិង្សាផ្នែករាងកាយ (៧៨.១% បើប្រៀបធៀបនឹង ៣៦.៩%) និងមានចំនួន ៩.១ដង ងាយនឹងរាយការណ៍អំពីការត្រូវគេធ្វើបាប ឬគំរាមកំហែងដោ យអាវុធ (៣៧.៧% បើប្រៀបធៀបនឹង ៩.១%) បើប្រៀបធៀបជាមួយកុមារដែលធ្វើការតែនៅក្នុងព្រំដែនខ្មែរ។ តថភាពនេ ះក៏ត្រូវបាន ឆ្លុះបញ្ចាំងនៅក្នុងការពិភាក្សាក្រុមមុនពេលប្រមូលទិន្នន័យ ដែលកុមារបង្ហាញអំពីស្ថានភាពដែលពួកគេ ឬបងប្អូនត្រូវបានគំរាមកំហែងដោយកាំភ្លើង ដោយសារពួកគេបានឆ្លងព្រំដែនខុសច្បាប់ និងធ្វើការនៅតាមផ្លូវ។

ការចាប់ខ្លួន ការឃុំខ្លួន និងការធ្វើមាតុភូមិនិវត្តន៍

នៅតាមព្រំដែនខ្មែរ-ថៃ គ្មាន "មណ្ឌលនិរទេស" ជាផ្លូវការនៅក្រោមរដ្ឋាភិបាលថៃទេ។ ដូច្នេះ កុមារដែលត្រូវបានឃុំ ខ្លួននៅពេលធ្វើការនៅតាមព្រំដែន ឬនៅក្បែរព្រំដែន ជាញឹកញាប់ ត្រូវបាននាំទៅការិយាល័យអន្តោប្រវេសន៍នៅ ស្រុកអារញ្ញ និងត្រូវបានឃុំខ្លួន រហូតទាល់តែពួកគេអាចធ្វើមាតុភូមិនិវត្តន៍បាន។ នៅក្នុងចំណោមកុមារដែលនៅតាមផ្លូវ ក្នុងតំបន់ប៉ោយប៉ែត ការនិរទេសនេះត្រូវបាន "បញ្ជូនតាមឡានទ្រុង" ដែលសំដៅទៅលើរថយន្តដែលបិទជិត ដែលដាក់កុមារនៅខាងក្នុង នៅពេលពួកគេត្រូវបាននាំយកទៅការិយាល័យអន្តោប្រវេសន៍ក្នុងស្រុកអារញ្ញ។ ការិយាល័យអន្តោប្រវេសន៍ទទួលខុសត្រូវក្នុងការទទួលប្រជាពលរដ្ឋខ្មែរ ដែលគ្មានឯកសារមកពីគ្រប់តំបន់ក្នុងប្រទេសថៃ ជារៀងរាល់ថ្ងៃ។ កុមារដែលត្រូវបានឃុំខ្លួននៅទីនេះ ហាក់បីដូចជាលាយឡំជាមួយពលករដែលគ្មានឯកសារ ដែលរង់ចាំធ្វើមាតុភូមិនិវត្តន៍។ នៅពេលគ្មានមណ្ឌលបញ្ជូននៅក្នុងស្រុកអារញ្ញ ដូច្នេះនៅក្នុងឆ្នាំ ២០១៦ អង្គការតំណក់ទឹកបានបើក មណ្ឌលមួយដែលអាចទទួលកុមារ និងធ្វើការសម្ភា ស ការតាមដានគ្រួសារ ការវាយតម្លៃ និងការបញ្ជូនបន្តករណីណាដែលចាំបាច់ ដើម្បីកាត់បន្ថយពេលវេលាដែលកុមារត្រូវចំណាយពេលនៅការិយាល័យអន្តោប្រវេសន៍។
កុមារដែលគ្មានឯកសារ និងគ្មានអាណាព្យាបាលដែលធ្វើការចូលទៅជ្រៅក្នុងប្រទេសថៃ ច្រើនតែត្រូវបញ្ជូនមកមណ្ឌលឃុំខ្លួន និងរក្សាទុកនៅទីនោះ រហូតទាល់តែមានជនជាតិខ្មែរដែលគ្មានឯកសារច្រើននាក់ពេញឡាន ទើបបញ្ជូនមក (ជាទូ ទៅ ចំនួន ៦០-៨០នាក់)។ បន្ទាប់មក មនុស្សទាំងនេះត្រូវបញ្ជូនមកការិយាល័យអន្តោប្រវេសន៍ក្នុងប៉ោយប៉ែត ដើម្បីធ្វើមាតុភូមិនិវត្តន៍**។

កុមារចំនួន ២៥នាក់ ឬស្ទើរតែពាក់កណ្តាលនៃចំនួនសំណាក (៤៥%) និយាយថា ពួកគេត្រូវបានចាប់ខ្លួនក្នុងប្រទេសថៃ។ ច្រើនជាងពាក់កណ្តាលនៃក្រុមនេះនិយាយអំពី "ការដឹកជញ្ជូនតាមឡានទ្រុង" ឬឃុំខ្លួននៅព្រំដែនក្នុងប្រទេសថៃ។ កុមារ ៩នាក់និយាយថា ពួកគេត្រូវប៉ូលីសវាយដំ នៅពេលពួកគេត្រូវបានចាប់ខ្លួន។ នៅក្នុងចំណោមក្រុមនេះ សុទ្ធតែជាក្មេងប្រុស។ បន្ថែមពីលើនេ ះ ការពិភាក្សាក្រុមគោលដៅមុនពេ លប្រមូលទិន្នន័យបង្ហាញថា ក្មេងប្រុសត្រូវបានប៉ូលីសគំរាមកំហែងដោយប្រើអាវុធ ហើយក្មេងប្រុសម្នាក់និយាយថា ត្រូវបានគេគ្រវែងពីលើដំបូល។ ម្យ៉ាងទៀត ទោះបីជាក្មេងស្រីមិនសូវបង្ហាញអំពីអំពើហិង្សាផ្នែករាងកាយពីប៉ូលីសក៏ពិតមែន ប៉ុន្តែពួកគេងាយនឹងត្រូវឃុំខ្លួន ("បញ្ជូនតាមឡាន

ទ្រុង") បើប្រៀបធៀបជាមួយក្មេងប្រុស (៣១% នៃក្មេងស្រី និង ១៩% នៃក្មេងប្រុស)។ នៅពេលក្មេងប្រុសត្រូវបានចាប់ខ្លួន ពួកគេងាយនឹងជួបអំពើហិង្សាផ្នែករាងកាយ ឬត្រូវគេដេញមកព្រំដែនខ្មែរវិញ។

បន្ថែមពីលើនេះទៀត កុមារដែលត្រូវបញ្ជូនទៅមណ្ឌលនិរទេស ត្រូវបានរកឃើញថា ងាយនឹងប្រើការ និង/ឬថ្នាំមេតាហ្វីតាមីន ដល់ទៅ ២ដង។ យ៉ាងណាក៏ដោយ យើងនៅតែត្រូវការទិន្នន័យលម្អិតដើម្បីពិភាក្សាអំពីរបស់នេះ ហើយវាសំខាន់ដែលត្រូវសម្គាល់អំពីផលប៉ះពាល់ផ្លូវចិត្តដែលអាចកើតមានឡើង នៅពេលដែលកុមារត្រូវបានចាប់ខ្លួន ឬបញ្ជូនមកវិញ។ ការមានបទពិសោធន៍នូវគេចាប់ខ្លួន ឬនិរទេស ទោះបីជាមិនទទួលនូវអំពើហិង្សាផ្នែករាងកាយ ឬផ្នែកផ្លូវចិត្តក៏ដោយ ក៏អាចនឹងបណ្តាលឲ្យមានការប៉ះទង្គិចខ្លាំងដល់កុមារផងដែរ ឬយ៉ាងហោចណាស់ ក្លាយជាប្រភពនៃភាពតានតឹងផ្លូវអារម្មណ៍ដល់កុមារ។ ចំណុចនេះអាចមានផលប៉ះពាល់អវិជ្ជមានទៅលើសុខភាព និងសុខមាលភាពផ្លូវចិត្តរបស់កុមារ។ នៅក្នុងបរិបទនេះ ការជ្រើសរើសប្រើសារធាតុញៀនគឺជាវិធីសាស្ត្រដោះស្រាយទម្រង់ផ្សេងៗនៃភាពតានតឹងផ្លូវអារម្មណ៍ (UNICEF, 2012)។ មិនមានព័ត៌មានច្បាស់លាស់ទេថាតើកុមារកំពុងប្រើ គ្រឿងញៀន នៅពេលបញ្ជូនទៅមណ្ឌលនិរទេស ឬមិនដឹងថាតើពួកគេជ្រើសរើសប្រើគ្រឿងញៀន នៅដំណាក់កាលពេលក្រោយ ឬយ៉ាងណាទេ។ ការស្រាវជ្រាវបន្ថែមត្រូវធ្វើឡើងនៅក្នុងផ្នែកនេះ ដើម្បីពិនិត្យមើលទំនាក់ទំនងរវាងការចាប់ខ្លួន ការប៉ះទង្គិចផ្លូវចិត្ត និងការប្រើគ្រឿងញៀន។

ចំណាកស្រុកទៅប្រទេសថៃ

ទោះបីជាមានកុមារតិចតួចដែលរស់នៅ/ធ្វើការនៅតាមផ្លូវនិយាយថា ពួកគេធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃក៏ដោយ ក៏ប៉ុន្តែឪពុកម្តាយមួយចំនួនធំរបស់កុមារធ្វើចំណាកស្រុក ជាញឹកញាប់ ធ្វើដំណើរទៅរយៈពេលយូរ និងទុក កូនឲ្យនៅម្នាក់ឯង ឬមិនសូវមានការមើលថែ។ កុមារជាងពាក់កណ្តាល (៥១%) បង្ហាញថា ឪពុកម្តាយរបស់ពួកគេធ្វើចំណាកស្រុកទៅប្រទេសថៃដើម្បីរកការងារធ្វើ។ ផ្ទុយពីអ្វីដែលបានរំពឹងទុក កុមារដែលមានឪពុកម្តាយធ្វើចំណាកស្រុកទៅប្រទេសថៃដើម្បីរកការងារធ្វើ មានភាគរយចុះឈ្មោះចូលរៀន ១.៤ដង បើប្រៀបធៀបជាមួយកុមារដែល ឪពុកម្តាយមិនធ្វើចំណាកស្រុក (៣៩% បើប្រៀបធៀបជាមួយ ២៧%)។ ចំណុចនេះអាចបណ្តាលមកពីឪពុកម្តាយដែលធ្វើចំណាកស្រុកទៅធ្វើការ ងាយនឹងប្រើកូនរបស់ពួកគេឲ្យធ្វើការនៅតាមផ្លូវ ដូច្នេះរារាំងមិនឲ្យកូនរបស់ពួកទៅសាលារៀនជាប្រចាំ។ ស្រដៀងគ្នាដែរ ចំពោះកុមារដែលមានឪពុកម្តាយធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ មានសមត្ថភាពផ្គត់ផ្គង់ថវិកាឲ្យកូនទៅសាលារៀន។ យ៉ាងណាមិញ ត្រូវមានការសិក្សាស្រាវជ្រាវបន្ថែមទៀតដើម្បី ស្វែងយល់អំពីរបស់នេះ។

ទោះបីជាកុមារដែលមានភាគរយច្រើនទៅសាលារៀនក៏ដោយ ក៏ប៉ុន្តែកុមារទាំងនេះនៅតែមានភាពងាយរងគ្រោះ ដោយសារឪពុកម្តាយធ្វើចំណាកស្រុក។ ក្នុងចំណោមកុមារដែលឪពុកម្តាយធ្វើចំណាកស្រុក ២៤% ត្រូវបានទុកចោលឲ្យនៅម្នាក់ឯង ហើយ ១៨% ត្រូវបានទុកឲ្យនៅជាមួយបងប្អូនបង្កើតណាម្នាក់ នៅពេលឪពុកម្តាយរបស់ពួកគេចេញ ទៅធ្វើការនៅក្រៅប្រទេស ដែលធ្វើឲ្យកូនៗរបស់ពួកគេ ប្រឈមនឹងគ្រោះថ្នាក់នៅតាមផ្លូវ។ ក្នុងចំណោមកុមារដែល ត្រូវបានទុកឲ្យនៅម្នាក់ឯង ឬនៅជាមួយបងប្អូនបង្កើត កុមារទាំងអស់ (៩២%) លើកលែងតែម្នាក់ និយាយថា ពួកគេ ជួបអំពើហិង្សាផ្នែករាងកាយ ភាគច្រើនពីមនុស្សវ័យជំទង់ ប៉ូលីស និងមនុស្សពេញវ័យផ្សេងទៀតនៅតាមផ្លូវ។ កុមារជាងពាក់កណ្តាល (៥៣%) បង្ហាញថា ឪពុកម្តាយរបស់ពួកគេទៅធ្វើការនៅក្រៅប្រទេស យ៉ាងហោចណាស់រយៈ ពេលមួយខែម្តង ហើយកុមារជាង ១/៣ បង្ហាញថា ពួកគេមិនដឹងច្បាស់ថា ពេលណាឪពុកម្តាយរបស់ពួកគេនឹងត្រឡប់មកវិញទេ។

កុមារដែលមានឪពុកម្តាយ និង/ឬអ្នកមើលថែធ្វើចំណាកស្រុក ប្រហែលជាមិនអាចបង្កើតទំនាក់ទំនងរឹងមាំជាប់លាប់ជាមួយគ្នាទេ ប៉ុន្តែគ្រួសារដែលនឹងធឹងគឺជាទម្រង់មួយនៃការការពារសម្រាប់កុមារ។ តាមរយៈគ្រួសារដែលរឹងមាំនេះហើយ ដែលទំនាក់ទំនងរវាងកូន និងឪពុកម្តាយ អាចនឹងត្រូវបានបង្កើតឡើង (UNICEF, 2012)។ ចំពោះកុមារ ជាច្រើននៅក្នុងប៉ោយប៉ែត ពួកគេមិនអាចបង្កើតទំនាក់ទំនងទាំងនេះបានទេ ដោយសារដែលឪពុកម្តាយរបស់ពួកគេ ធ្វើចំណាកស្រុក។ ហេតុនេះហើយ កុមារអាចនឹងមានអារម្មណ៍នៅដាច់ឆ្ងាយ ឬដាច់ទំនាកទំនងពីគ្រួសារ ឬអ្នកមើលថែរបស់ពួកគេ និងជ្រើសរើក្រុមមិត្តភ័ក្តដែលរស់នៅតាមផ្លូវ និង/ឬ ជ្រើសរើសប្រើសារធាតុញៀន ជាមធ្យោបាយក្នុង បង្កើតចំណង "គ្រួសារ" សាជាថ្មី នៅក្នុងក្រុមមិត្តភ័ក្ត របស់ពួកគេ។ នេះគឺជាការពិចារណាមួយដ៏សំខាន់ព្រោះការបង្កើតទំនាក់ទំនងរឹងមាំជាមួយគ្រួសារ អាចជាកត្តាការពារមួយ ដើម្បីយកឈ្នះលើភាពតានតឹងផ្លូវអារម្មណ៍ នៅពេល អនាគតនិងការជាសះស្បើយ។

ទីក្រុងប៉ោយប៉ែត (ឬទីក្រុងជាប់ប្រទេសថៃ ស្រុកអារញ្ញ) ត្រូវបានស្គាល់ថា ជាច្រកចូលទៅក្នុងប្រទេសថៃសម្រាប់ជនជាតិខ្មែរជាច្រើនដែលធ្វើចំណាកស្រុក នៅក្នុងឧស្សាហកម្មសំណង់ដែលកំពុងតែលូតលាស់ និងនៅក្នុងឧស្សាហកម្មកសិកម្ម និងនេសាទ (Capaldi, 2014)។ ការសិក្សាមួយរបស់ Terre Des Hommes (2014) បានរកឃើញថា កុមារអាចនឹងឆ្លងព្រំដែនចូលជ្រៅទៅក្នុងប្រទេសថៃ ជាមួយសមាជិកគ្រួសារ ប៉ុន្តែនៅពេលពួកគេមានអារម្មណ៍ថាមានទំនុក

ចិត្តក្នុងការធ្វើដំណើរ នោះពួកគេនឹងត្រឡប់មកវិញ ជាកុមារដែលធ្វើចំណាកស្រុកដែលមានភាពឯករាជ្យ (Capaldi, 2014)។ បន្ថែមពីលើនេះទៀត ការសិក្សានេះរកឃើញថា កុមារជាច្រើនមកពីតំបន់ជនបទក្នុងប្រទេសកម្ពុជាតែងតែរកបានការងារធ្វើ ដូចជា ធ្វើការក្នុងហាង អ្នកដើរលក់តាមផ្លូវ អ្នកធ្វើការតាមផ្ទះ កម្មករសំណង់ និង កម្មករនៅក្នុងវិស័យវាយនភណ្ឌ និងផលិតកម្ម។ មូលហេតុដោយសារការយល់ឃើញថា ការធ្វើការនៅប្រទេសថៃអាច រកប្រាក់ចំណូលបានច្រើន ដូច្នេះការងារទាំងនេះទាក់ទាញយុវជនមកពីតំបន់ជនបទក្នុងប្រទេសកម្ពុជា ដូចជា តំបន់ ប៉ោយប៉ែត (Capaldi, 2014)។ ចំណុចនេះមានអំណះអំណាងបញ្ជាក់បន្ថែមដោយលទ្ធផលស្រាវជ្រាវពីរបាយការណ៍ ឆ្នាំ ២០១៦ (មិនទាន់បោះពុម្ពផ្សព្វផ្សាយនៅឡើយ ខណៈពេលកំពុងធ្វើរបាយការណ៍នេះ) អំពីរបត់នៃចំណាកស្រុក ក្នុងចំណោមជនជាតិខ្មែរដែលនៅជនបទ (Sampson & Sokleap, 2016) ដែលរកឃើញថា ជនជាតិខ្មែរធ្វើចំ ណាកស្រុក ដោយសារពួ កគេយល់ឃើញថា ឱកាសការងារ និងការរកប្រាក់ចំណូលក្នុងប្រទេសកម្ពុជាមិនគ្រប់គ្រាន់។ ការសិក្សានេ ះក៏រកឃើញថា កុមារភាគច្រើនបានបោះបង់ចោលការសិក្សា ដើម្បីធ្វើចំណាកស្រុកទៅធ្វើការនៅប្រ ទេសថៃ ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ (Sampson & Sokleap, 2016)។

ការប្រើប្រាស់សារធាតុញៀន

ការប្រើគ្រឿងញៀនត្រូវបានរកឃើញថា ជាបញ្ហាមួយដ៏សំខាន់ក្នុងចំណោមក្មេងប្រុសដែលរស់នៅ/ធ្វើការតាមផ្លូវក្នុងតំបន់ប៉ោយប៉ែត ដែលក្មេងប្រុស ៥០% និយាយថា ពួកគេប្រើការហិត ហើយក្មេងប្រុស ២៩% បង្ហាញថា ពួកគេប្រើ ថ្នាំមេតាហ្វីតាមីន។ ទិន្នន័យអន្តរជាតិស្តីអំពីការប្រើប្រាស់សារធាតុញៀនរបស់យុវជន បង្ហាញថា ក្មេងប្រុសប្រឈមខ្លាំងនឹងការប្រើសារធាតុញៀន រួមជាមួយការមានអាយុច្រើន ការខ្វះទំនាក់ទំនងជាមួយគ្រួសារ ភាពធ្លាក់ទឹកចិត្ត និង ការជួបនូវអំពើរំលោភបំពាន (Moan, et al., 2013)។ កម្រិតនៃការប្រើគ្រឿងញៀនក្នុងទីក្រុងប៉ោយប៉ែតត្រូវបានរក ឃើញថា មានទំនាក់ទំនងច្រើនទៅនឹងផលប៉ះពាល់អវិជ្ជមានទៅលើសុខភាព អំពើហិង្សាផ្នែករាងកាយ អំពើហិង្សាផ្នែកផ្លូវភេទ និងការអស់វាំ។ ការប្រើសារធាតុញៀននៅវ័យក្មេង អាចនឹងប៉ះពាល់ខ្លាំងដល់ការលូតលាស់។ ទិន្នន័យអន្ត រជាតិក៏បង្ហាញផងដែរថា កុមារដែលប្រើគ្រឿងញៀននៅវ័យក្មេង មានការប្រឈមខ្លាំងក្នុងការបោះបង់ចោលការ សិក្សា (NIDA, 2003) និងអាចមានភាគរយច្រើនក្នុងការស្ថិតក្នុងភាពក្រីក្រ នៅក្នុងជីវិតពេញវ័យរបស់ពួកគេ។ បន្ថែមពីលើនេះទៀត ការប្រើ

គ្រឿងញៀនអាចនឹងប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពផ្លូវកាយ សុខភាពផ្លូវអារម្មណ៍ និង សុខភាពផ្លូវចិត្តរបស់កុមារ។ នៅក្នុងដំណាក់កាលនេះហើយ ដែលការលូតលាស់មានសារៈសំខាន់បំផុត។ ការលូតលាស់នេះពិតមានផលប៉ះពាល់សំខាន់ទៅលើជីវិតពេញវ័យរបស់ពួកគេ សុខមាលភាពនៅពេលអនាគត និងសក្តានុពលក្នុងការធ្វើជាពលរដ្ឋសកម្មក្នុងសង្គម។ បន្ថែមពីលើនេះទៀត ការប្រើប្រាស់គ្រឿងញៀនក៏ប៉ះពាល់ខ្លាំងដល់សុខភាព សេវាសង្គម និងប្រព័ន្ធតុលាការរបស់ប្រទេសផងដែរ។

ការប្រើប្រាស់គ្រឿងញៀន និងបទពិសោធន៍នៃអំពើហិង្សា

ការប្រើប្រាស់គ្រឿងញៀន ក៏ពាក់ព័ន្ធនឹងបទពិសោធន៍នៃអំពើហិង្សាខ្ពស់ផ្នែករាងកាយផងដែរ។ ក្នុងចំណោមអ្នកប្រើ ថ្នាំមេតាហ្វេតាមីន និង/ឬការ កុមារស្ទើរតែទាំងអស់ (៩៥%) ក៏លើកឡើងអំពីហេតុការណ៍នៃអំពើហិង្សាផ្នែករាងកាយ (បើប្រៀបធៀបជាមួយ ៥៤% នៃកុមារដែលមិនបានលើកឡើងថា ប្រើមេតាហ្វេតាមី ន និង/ឬការ)។ អំពើហិង្សាផ្នែករាងកាយភាគច្រើនដែលកុមារប្រើគ្រឿងញៀនជួប គឺមកពីយុវជនដែលមានអាយុច្រើន ឬក្រុមបងធំ (៦៨%) មកពីប៉ូលីស (៥០%) និង "មនុស្សធំផ្សេងទៀត" (៤១%)។ គួរកត់សម្គា ល់ ផងដែ រថា ក្នុងចំណោមកុមារប្រើ គ្រឿងញៀនចំនួនពាក់កណ្តាលនិយាយថា ពួកគេទទួលអំពើហិង្សាពីប៉ូលីស។

មានការផ្សារភ្ជាប់សំខាន់មួយផងដែរ រវាងការប្រើប្រាស់គ្រឿងញៀន និងអំពើហិង្សាផ្លូវភេទ ក្នុងចំណោមកុមារដែលរស់នៅ/ធ្វើការនៅតាមផ្លូវ ដែលកុមារប្រើគ្រឿងញៀនជាង ២/៣ (៦៨%) និយាយថា ពួកគេជួបអំពើហិង្សាផ្នែកផ្លូវភេទ បើប្រៀបធៀបជាមួយ ១០% នៃកុមារដែលមិនប្រើគ្រឿងញៀន។ បន្ថែមពីលើ នេះទៀត កុមារស្ទើរតែ ៣/៤ (៧៣%) ដែលប្រើគ្រឿងញៀនលើកឡើងថា មនុស្សធំបានបង្ហាញរូបភាពអាសអាភាសឲ្យពួកគេមើល បើប្រៀបធៀបជាមួយកុមារ ១៨% ដែលមិនប្រើគ្រឿងញៀន។ ចំណុចនេះសំខាន់ ព្រោះរូបភាព/វីដេអូអាសអាភាសត្រូវបាន ជនល្មើស CSEA ភាគច្រើនប្រើ ដើម្បីល្បួងកុមារសម្រាប់អំពើកេងប្រវ័ញ្ចផ្លូវភេទ (Fordham, 2005)។ ចំណុចនេះត្រូវបានអះអាងបញ្ជាក់ដោយកុមារប្រើគ្រឿងញៀនស្ទើរតែ ១/៣ (៣០%) ដែលនិយាយថា ពួកគេត្រូវបានផ្តល់ម្ហូប អាហារ លុយ ឬកាដូ ជាការដោះដូ រជាមួយសេវាផ្លូវភេទជាមួយមនុស្សធំ បើប្រៀបធៀបទៅនឹង ៤% នៃកុមារដែលមិនប្រើគ្រឿងញៀន។ ចំណុចទំនាក់ទំនងរវាងអំពើហិ ង្សាផ្លូវភេទ និងការប្រើសារធាតុញៀនក៏ត្រូវបានបង្ហាញច្បាស់នៅក្នុងការសិក្សាលើកមុន ដែលបានធ្វើក្នុងទី ក្រុងឈៀងម៉ៃ (Davis, Fiss & Miles, 2015) ដែលមានអត្រាអំពើរំលោភបំពានផ្លូវភេទខ្ពស់ទៅលើកុមារដែលប្រើគ្រឿង ញៀន បើប្រៀបធៀបជាមួយកុមារដែលមិនប្រើសារធាតុញៀនណាមួយ។

ការប្រើប្រាស់គ្រឿងញៀន និងទំនាក់ទំនងសង្គម

នៅក្នុងចំណោមកុមារដែលប្រើគ្រឿងញៀនក្នុងទីក្រុងប៉ោយប៉ែត មានការសម្គាល់ឃើញអត្រានៃអំពើហិង្សាខ្ពស់ និងទំនាក់ទំនងជាមួយគ្រួសារ/សង្គមមានកម្រិតទាប។ វាពិតជាមានតម្លៃនៅក្នុងបរិបទនេះ ដែលធ្វើការពិចារណាថា ការ ខ្វះការផ្សារភ្ជាប់ទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ក៏ដូចជា បរិយាកាសនៅក្នុងផ្ទះមានភាពរញ៉េរញ៉ៃ ក៏ត្រូវបានចាត់ទុកថា

ជាកត្តាប្រឈមឲ្យកុមារប្រើគ្រឿងញៀនដែរ (NIDA, 2003)។ បន្ថែមពីលើនេះទៀត ការមានការចូលរួម ជាវិជ្ជមានពីឪពុកម្តាយនៅក្នុងជីវិតរបស់កុមារ និងការបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុ ផ្លូវអារម្មណ៍ ផ្នែកបញ្ញា និងផ្នែក ទំនាក់ទំនងសង្គម គឺជាកត្តាដែលអាចជួបទប់ស្កាត់បញ្ហានៃការប្រើប្រាស់សារធាតុញៀននៅក្នុងកុមារ (2003)។

ទិន្នន័យក៏បានបង្ហាញថែមទៀតអំពីការផ្សារភ្ជាប់ដ៏សំខាន់នៃទំនាក់ទំនងក្នុងគ្រួសារ (ឬ ការខ្វះទំនាក់ទំនង) និងការប្រើប្រាស់គ្រឿងញៀន។ កុមារចំនួនជាង ១/៣ (៣៦%) និយាយថា ការនៅផ្ទះ ឬការមានទំនាក់ទំនងល្អជាមួយគ្រួសារនឹងជួយឲ្យពួកគេឈប់ប្រើគ្រឿងញៀន។ បន្ថែមពីលើនេះ កុមារភាគច្រើនដែលប្រើគ្រឿងញៀន (៧៨%) និយាយថាពួកគេស្វែងរកមិត្តភ័ក្ត ឬកុមារអាយុស្រករគ្នា នៅពេលពួកគេមានអារម្មណ៍ខឹង ឬមិនសប្បាយចិត្ត ហើយ ១៦% នៃក្រុមដដែលនេះ (កុមារ ៣នាក់) និយាយថា ពួកគេគ្មាននរណាដែ លអាចជួយពួកគេបានទេ។ ចំណុចនេះស្របនឹងការស្រាវជ្រាវដែលបានធ្វើរួចហើយ ដែលរកឃើញទំនាក់ទំនងដ៏គួរឲ្យកត់សម្គាល់រវាងការដាច់ទំនាក់ទំនងជាមួយសង្គ ម និងការញៀនគ្រឿងញៀន។ ការសិក្សាទាំងនេះបង្ហាញថា ការប្រើគ្រឿងញៀនសម្រាប់សប្បាយ និងការញៀនគ្រឿងញៀនគឺជាចំណុចពីរផ្សេងគ្នា។ ការញៀនគឺជារោគសញ្ញាមួយនៃបញ្ហាផ្នែកសង្គម និងផ្នែកអារម្មណ៍ និងការខ្វះទំនាក់ទំនងរឹងមាំរវាងចំណុចទាំងពីរ។ តាមរយៈការយល់ឃើញបែបនេះ ការញៀនគ្រឿងញៀនឆ្លុះបញ្ចាំងនូវ "ការដាច់ចេញ" (Polyani, 1944) "ការនៅឆ្ងាយពី គ្នា" ឬ "ការដាច់ទំនាក់ទំនង" (Alexander, 2010) របស់កុមារពីសហគមន៍ និងទំនៀមទម្លាប់របស់សហគមន៍។ នៅក្នុងទស្សនៈនេះ ការញៀនគ្រឿងញៀនគឺជារោគសញ្ញានៃការខ្វះគោលបំណង ឬភាពកក់ក្តៅ ឆ្លុះបញ្ចាំងអំពីការដាច់ចេញពី គ្រួសារ សហគមន៍ ឬសង្គមទាំងមូល។ ដូច្នេះ ការជាសះស្បើយពីការញៀនក៏ដូចជាការទប់ស្កាត់នូវការញៀនថ្មីៗ ជាញឹកញាប់ទាក់ទងនឹងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃ និងកាត់ផ្តាច់ការនៅដាច់ឆ្ងាយពីអ្នកដទៃ។ ចំណុចនេះទាក់ទងជាពិសេសទៅលើឪពុកម្តាយភាគច្រើនដែលធ្វើដំណើរទៅប្រទេសថៃ ការដាច់ទំនាក់ទំនងជាមួយកូន និងផលប៉ះពាល់នៃការប្រើប្រា ស់សារធាតុញៀន។ សម្រាប់ផ្នែកនេះត្រូវធ្វើការស្រាវជ្រាវបន្ថែមទៀត។

អំពើហិង្សា

បទពិសោធន៍នៃអំពើហិង្សាកើតឡើងច្រើន ក្នុងចំណោមកុមារដែលរស់នៅ/ធ្វើការតាមផ្លូវក្នុងតំបន់ប៉ោយប៉ែត ហើយត្រូវបានលើកឡើងថា អំពើហិង្សាកើតឡើងនៅក្នុងបរិបទផ្សេងៗ រួមមាន នៅក្នុងគេហដ្ឋាន និងនៅតាមផ្លូវ។ ទម្រង់ផ្សេងៗនៃអំពើហិង្សា (ផ្នែករាងកាយ ផ្នែកផ្លូវភេទ និងផ្នែកអារម្មណ៍) ជាញឹកញាប់តែងតែកើតឡើងជាន់គ្នា និងធ្វើ ឡើងដោយបុគ្គលមួយចំនួន ដូចជា ប៉ូលីស កុមារអាយុស្រករគ្នា មនុស្សធំ មនុស្សដែលមិនស្គាល់មុខ និងសមាជិកក្រុមបងធំបងតូច។ កុមារនៅតាមផ្លូវលើកឡើងអំពីភាពភ័យខ្លាច និងបទពិសោធន៍នៃអំពើហិង្សាថាជាបញ្ហាមួយដែលគួរឲ្យកត់សម្គាល់ជាពិសេស អំពើហិង្សាពីមនុស្ស ធំ និងអ្នកប្រើគ្រឿងញៀន។ បន្ថែមពីលើនេះ អំពើហិង្សាដែល ប្រព្រឹត្តដោយអាជ្ញាធរជាពិសេស មន្ត្រីអនុវត្តច្បាប់របស់ប្រទេសថៃ ត្រូវបានលើកឡើងយ៉ាងច្បាស់ៗ ដោយកុមារ ជាង ១/៤។ នៅក្នុងបរិបទនេះហើយ ដែលជាញឹកញាប់ ការប្រើប្រាស់គ្រឿងញៀនកើតឡើងជាយន្តការនៃការឆ្លើយ តបចំពោះបញ្ហា ឬដើម្បីពង្រឹងទំនាក់ទំនងរួម។ អំពើកេងប្រវ័ញ្ច អំពើជួញដូរមនុស្ស និងអំពើហិង្សាផ្នែកផ្លូវភេទគឺជា បញ្ហាប្រឈមដែលត្រូវបានបន្ថែម។ កុមារដែលរស់នៅ/ធ្វើការនៅតាមផ្លូវមួយចំនួន ទាំងក្មេងស្រី និងក្មេងប្រុស ត្រូវបានរកឃើញថា ធ្លាប់ប្រឡូកក្នុងសកម្មភាពផ្លូវភេទដើម្បីដោះដូរជាមួយលុយ ដែលជាញឹកញាប់ គឺជាមធ្យោបាយ នៃការរស់រានមានជីវិត។

យេនឌ័រ និងអំពើហិង្សាផ្នែកផ្លូវភេទ

ទោះបីជាអំពើហិង្សាផ្នែកផ្លូវភេទស្ទើរតែមានភាគរយកើតឡើងស្ទើរតែ ៤ដង ក្នុងចំណោមក្មេងប្រុសក៏ដោយ បើប្រៀបធៀបជាមួយក្មេងស្រី (៣១% បើប្រៀបធៀបនឹង ៨%) ក៏ប៉ុន្តែ ទាំងក្មេងប្រុស និងក្មេងស្រី គ្មាននរណាហាក់បីដូចជាចាត់ទុកអំពើហិង្សាផ្លូវភេទ ជាកត្តាគ្រោះថ្នាក់ដល់ក្មេងប្រុសទេ។ ក្នុងចំណោមទាំងពីរភេទ បញ្ហាគ្រោះថ្នាក់ចម្បងចំពោះក្មេងប្រុស ត្រូវបានសន្មតថាជាទម្រង់ អំពើហិង្សាលើរាងកាយ ដូចជា ការត្រូវឡានបុក និងកត្តាគ្រោះថ្នាក់ចម្បងចំពោះក្មេងស្រីត្រូវបានសន្មតថា ការត្រូវគេចាប់រំលោភ ជាពិសេសត្រូវពួកអ្នកញៀនថ្នាំចាប់ រំលោភ។ ផ្ទុយពីការយល់ឃើញទាំងនេះ មានកុមារស្ទើរតែ ១/៣ និងក្មេងស្រីតិជាង ១ ក្នុង ១០ លើកឡើងអំពីអំពើ ហិង្សាផ្នែកផ្លូវភេទ។ ហេតុការណ៍នេះកើតឡើងជាពិសេសក្នុងករណីក្មេងប្រុសម្នាក់ ដែលរៀបរាប់អំពីបទពិសោធន៍នៃការរំលោភបំពានផ្លូវភេទ រួមមាន ការចាប់រំលោភដោយប្រើកម្លាំងកាយ។ ទោះបីជាមានអំពើហិង្សានេះក៏ដោយ នៅពេលកុមារទាំងនេះ

ត្រូវបានសួរអំពីគ្រោះថ្នាក់ផ្សេងៗដែលក្មេងប្រុស និងក្មេងស្រីជួបនៅតាមផ្លូវ ក្មេងប្រុសទទួល ទទួលស្គាល់ថា អំពើហិង្សាផ្លូវភេទកើតឡើងតែទៅលើក្មេងស្រីតែប៉ុណ្ណោះ ហើយនិយាយថា ប្រុសៗជួបគ្រោះថ្នាក់ អំពើហិង្សាផ្នែករាងកាយតែប៉ុណ្ណោះ។ នេះអាចកើតឡើងដោយសារផ្នត់គំនិតសង្គមភាគច្រើនអំពីភាពជាបុរស និង ភាពជាស្ត្រី ដែលមានទំនោរចាត់ទុកភេទស្រីជាភេទទន់ខ្សោយ និងមិនអាចការពារខ្លួនឯងបាន ចំណែកឯបុរស ត្រូវ បានចាត់ទុកថាមានកម្លាំងខ្លាំង មាំមួន និងអាចជួ យខ្លួនឯងបាន។ តាមរយៈទស្សនៈបែបនេះ ភាពជាជនរងគ្រោះនៃ ភេទប្រុស ហាក់បីដូចជាផ្ទុយពីផ្នត់គំនិតទូទៅរបស់សង្គមអំពីភេទប្រុស (Weiss, 2010)។

ទោះបីជាក្មេងស្រីមិនត្រូវលើកឡើងអំពីអំពើហិង្សាផ្លូវភេទក្តី វាមិនមែនបង្ហាញថា ក្មេងស្រីមិនសូវងាយរងគ្រោះនោះ ទេ ប៉ុន្តែវាលើកឡើងនូវការពិចារណាសំខាន់ៗ សម្រាប់ធ្វើការស្រាវជ្រាវនៅថ្ងៃអនាគត ដោយសិក្សាទៅលើយេនឌ័រ និងអំពើហិង្សា។ ភាពមិនស្របគ្នារវាងការយល់ឃើញអំពីភាពងាយទទួលរងអំពើហិង្សា និងតថភាពជាក់ស្តែងនៃការទទួលរងអំពើហិង្សា ហាក់បីដូចជាមានទំហំធំ។ ដោយសារការយល់ឃើញទូ ទៅផ្នែកវប្បធម៌អំពីយេនឌ័រ ជាញឹកញាប់ភេទប្រុសត្រូវបានចាត់ទុកថាមិនសូវទទួលរងនូវអំពើហិង្សា និងត្រូវបានសន្មតថា អាចការពារខ្លួនឯងបាន (Frederick, 2010: 6-7)។ ទោះបីជានៅក្នុងការពិភាក្សាក្រុមគោលដៅដំបូង មុនពេលប្រមូលទិន្នន័យ កុមារដែលរស់នៅ/ធ្វើការនៅតាមផ្លូវ ដែលជាភេទប្រុស និងភេទស្រី បានលើកឡើងនូវការសន្ម តស្រ ដៀងគ្នាថា ក្មេងប្រុសមិនសូវ រងគ្រោះនៅតាមផ្លូវទេ ព្រោះពួកគេ "ឆ្លាតជាង" ក្មេងស្រី និងចេះរត់ចេញពីស្ថានភាពគ្រោះថ្នាក់ដែលអាចកើតឡើង។ វាក៏មានតម្លៃផងដែរដែលត្រូវពិចារណាអំពីផលប៉ះពាល់នៃការសន្មតនេះ នៅពេលឪពុកម្តាយ អ្នកមើលថែ និង/ឬគ្រួសាររបស់កុមារត្រូវមើលការខុសត្រូវ និងផ្តល់ការការពារដល់ពួ កគេ។ ប្រហែលជាក្មេងប្រុសអាចនឹងសូវទទួលបានការមើលថែ និងការការពារបានគ្រប់គ្រាន់ ដូច្នេះធ្វើឲ្យពួកគេងាយប្រឈមនឹងទម្រង់ផ្សេងៗនៃ អំពើហិង្សា។ នៅក្នុងការស្រាវជ្រាវនៅថ្ងៃអនាគត វាជាការល្អដែលយើងអាចសិក្សាអំពីការសន្មតទៅលើឥទ្ធិពលនៃភាពជាបុរស និងភាពងាយរងគ្រោះរបស់បុរសទៅនឹងអំពើហិង្សាផ្នែកផ្លូវភេទ ជាពិសេស ក្នុងចំណោមកុមារដែលរស់នៅ/ធ្វើការតាមផ្លូវ។

បន្ថែមពីលើនេះ បុគ្គលិកដែលធ្វើការផ្ទាល់ជាមួយកុមារក្នុងក្រុងប៉ោយប៉ែតផ្អែកលើភស្តុតាងពីគ្រួសារ លើកឡើងថា ក្មេងស្រីវ័យក្មេងមួយចំនួន (អាយុតិចជាងក្មេងស្រីដែលបានរួ មបញ្ចូលក្នុងគំរូសំណាកក្នុងការសិក្សានេះ) ត្រូវបានភ្ញៀវ ទេសចរណ៍ល្បួងយកមករួមភេទនៅកាស៊ីណូ ក្នុងតំបន់សេដ្ឋកិច្ចពិសេស និងពាណិជ្ជកម្មសេរី ក្បែរប៉ោយប៉ែត។ ទោះបីជាព័ត៌មាននេះមិនមានភស្តុតាងបញ្ជាក់ក៏ពិតមែន វាអាចជាការល្អសម្រាប់ការស្រាវជ្រាវនៅពេលអនាគត ក្នុង ការសិក្សាអំពីភាពងាយរងគ្រោះ ក្នុងចំណោមកុមារវ័យក្មេងក្នុងតំបន់ប៉ោយប៉ែត។

ក្រុមក្មេងទំនើង និងអំពើហិង្សា

កុមារដែលនៅក្នុងការសិក្សាស្រាវជ្រាវនេះលើកឡើងអំពីអំពើហិង្សាពីក្រុមក្មេងទំនើង ដែលជាញឹកញាប់ ត្រូវបាន ហៅថា ក្រុមបងធំ ។ ក្នុងចំណោមកុមារ ២១នាក់ដែលបានលើកឡើងអំពីអំពើហិង្សាពីក្រុមបងធំ ទាំងអស់គឺជាភេទ ប្រុស (៩៥%) លើកលែងតែម្នាក់។ ទោះបីជាមានការលើកឡើងជាញឹកញាប់អំពីអំពើហិង្សាពីក្រុមបងធំក៏ដោយ ក៏ប៉ុន្តែមាន យុវជនតែមួយចំនួនតូចប៉ុណ្ណោះ ក្មេងប្រុស ៣នាក់ អាយុ ១៣-១៨ឆ្នាំ និយាយថា ពួកគេរស់នៅជាមួយ ក្រុមបងធំ។ ក្នុងចំណោមកុមារទាំង ៣នាក់នេះ ទាំងអស់និយាយថា ពួកគេរស់នៅតាមផ្លូវ ២នាក់មិនដែលបានចូល រៀន ហើយម្នាក់ និយាយថា មិនបានចូលរៀនជិត ១០ឆ្នាំហើយ។ កុមារទាំងបីនាក់លើកឡើងអំពីការប្រើគ្រឿងញៀន រួមមាន ការសម្រាប់ហិត និងមេតាហ្វីតាមីន។

ក្រុមបងធំក្នុងប៉ោយប៉ែតត្រូវបានមើលឃើញថាជាប្រភពអសន្តិសុខ អំពើហិង្សា និងការគំរាមកំហែលដល់កុមារដែល រស់នៅ/ធ្វើការនៅតាមផ្លូវ។ ការចូលរួមនៅក្នុងក្រុមបងធំ អាចកើតឡើងមកពីតម្រូវការចង់បានអត្តសញ្ញាណខ្លួនឯង សន្តិសុខផ្នែករាងកាយ និងជំនួយផ្នែកផ្លូវអារម្មណ៍ ជាតម្រូវការមួយសំខាន់ដល់យុវវ័យដែលមកពីគ្រួសារដែល បែកបាក់ ឬមានភាពរញ៉េរញ៉ៃ។ ការបង្កើតអត្តសញ្ញាណថ្មីនៅតាមផ្លូវ អាចជួយឲ្យកុមារងើបផុតពីការមើលងាយថាជា "ក្មេងតាម ចិញ្ចើមថ្នល់" និងផ្តល់អត្ថន័យវិជ្ជមានទៅដល់បទពិសោធន៍ឈឺចាប់របស់ពួកគេ ដែលជួយឲ្យពួកគេ មានអារម្មណ៍ថា ពួកគេស្ថិតនៅក្នុងគ្រួសារមួយ (Beazley, 2003)។ ការទទួលរាប់រកអាចធ្វើឡើងដោយចូលរួមក្នុង ក្រុមបងធំ ការរស់នៅក្នុងក្រុម ឬបង្កើតមិត្តភាពតាមរយៈបណ្តាញកុមារនៅតាមផ្លូវ។ ការស្ថិតនៅក្នុងក្រុមមួយ មិនគ្រាន់តែជួយឲ្យ កុមារនៅតាមផ្លូវទទួលបានមុខមាត់ និងការរាប់រកប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយឲ្យពួកគេទទួលបាន សន្តិសុខ ការការពារផ្នែក រាងកាយ និងជំនួយផ្លូវអារម្មណ៍ផងដែរ (UMP, 2000)**។

បន្ថែមពីលើនេះទៀត មានទំនាក់ទំនងស្ថិតិសំខាន់មួយក្នុងភាពជាបុរស ការប្រើគ្រឿងញៀន និងការទទួលរងអំពើ ហិង្សានៅតាមផ្លូវ តាមទម្រង់ផ្សេងៗ។ ទោះបីជាយើងមិនអាចសន្និដ្ឋានជាក់លាក់ ថា កត្តាមួយបណ្តាលឲ្យមានកត្តា មួយទៀតក៏ដោយ វាជាការសំខាន់ដែ លយើងត្រូវពិចារណាអំពីការទាក់ទងគ្នានៃកត្តានីមួយៗ (យេនឌ័រ ការប្រើ គ្រឿងញៀន និងអំពើហិង្សា) នៅក្នុងតំបន់ប៉ោយប៉ែត និងអំពីផលប៉ះពាល់ទៅលើសុ វត្ថិភាពកុមារនៅតាមផ្លូវ។ ភេទ ប្រុសត្រូវបានគិតថាមានកម្លាំងជាង និងអាចការពារខ្លួនឯងនៅក្នុងគ្រួសារ នៅក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ និងមិនសូវទទួលបាននូវការការពារ និងជំនួយពីគ្រួសារនោះទេ (Frederick, 2010)។ បន្ថែមពីលើនេះ ការស្រាវជ្រាវ

បានបង្ហាញអំពីអត្រាខ្ពស់នៃភាពតានតឹងផ្លូវចិត្ត ក្នុងចំណោមភេទប្រុស ដែលមិនមានសន្តិសុខផ្នែកអាហារ ភាពតានតឹងខ្ពស់នៃការងារ ឬភាពគ្មានការងារធ្វើ បើប្រៀបធៀបជាមួយនឹងភេទស្រី (WHO, 2007) ទាំងអស់នេះសុទ្ធតែទាក់ទងនឹងការប្រឈមខ្ពស់ទៅនឹងការប្រើគ្រឿងញៀន (NIDA, 2003)។ ការស្រាវជ្រាវបន្ថែម ទៀតត្រូវធ្វើឡើង ដើម្បីសិក្សាអំពីទំនាក់ទំនងរវាងភេទប្រុស ភាពជាបុរស អំពើហិង្សា និងការប្រើគ្រឿងញៀន ជាពិសេសនៅក្នុងសហគមន៍ដែលរស់នៅ/ធ្វើការនៅតាមផ្លូវ។

អំពើហិង្សាក្នុងគ្រួសារ

ទោះបីជាកុមារភាគច្រើន (៨៤%) និយាយថា ពួកគេមានផ្ទះ ឬជម្រកណាមួយដែលពួកគេគេងនៅខាងក្នុង ប៉ុន្តែ កុមារ ១ ក្នុង ៥នាក់ ត្រូវបានបង្ខំឲ្យគេងនៅកន្លែងផ្សេងជាប្រចាំ ដែលភាគច្រើនគេងនៅតាមផ្លូវ។ ក្នុងចំណោមកុមារ ដែលមានផ្ទះ ប៉ុន្តែមិនអាចគេងនៅផ្ទះបានជាប្រចាំ កុមារ ១/៣ លើកឡើងអំពីអំពើហិង្សានៅផ្ទះ ឬមានអារម្មណ៍ថា ផ្ទះគឺជាទីកន្លែងដែលពួកគេចង់ចៀសវាង។ នៅក្នុងផ្ទះ កុមារជិត ៣៨% លើកឡើងអំពីអំពើហិង្សា ផ្នែករាងកាយពី ឪពុកម្តាយ ហើយនៅក្នុងចំណោមកុមារចំនួន ៥៥នាក់ដែលនិយាយអំពីភាពភ័យខ្លាច ចត្រូវរបួស ឬខ្លាចស្លាប់ដោយសារ អំពើហិង្សា ៥នាក់បានលើកឡើងថា ពួកគេខ្លាចឪពុក/ម្តាយ ឬសាច់ញាតិ។ ជាពិសេស កុមារម្នាក់ (ប្រុស អាយុ ១២ឆ្នាំ) និយាយថា ត្រូវឪពុករបស់គាត់ដែលស្រវឹងដេញចេញពីផ្ទះ។ ការរកឃើញនៅក្នុងការស្រាវជ្រាវនេះហាក់បី ដូចជាបង្ហាញអំពីភាពចាំបាច់ត្រូវផ្តោតទៅលើការធ្វើការទៅលើផ្ទះ និងគ្រួសាររបស់កុមារដែលធ្វើការ/រស់នៅតាមផ្លូវ។

ការអប់រំអំពីផ្លូវភេទ

ការស្រាវជ្រាវនេះបានបង្ហាញអំពីអត្រាដ៏ខ្ពស់ (៨៩%) នៃកុមារដែលមិនបានទទួលការអប់រំអំពីសុខភាពផ្លូវភេទ។ ការ រកឃើញនេះមានកម្រិតខ្ពស់ជាងរបាយការណ៍អង្គការយូនីសេហ្វ (2016) ដែលរកឃើញត្រឹមតែ ក្មេងប្រុស ៤៦% និង ក្មេងស្រី ៣៨% ក្នុងចំណោមយុវជនកម្ពុជាទូទៅ (ចន្លោះឆ្នាំ ២០១០ និង ២០១៤) ដែលយល់ដឹងទូលំទូលាយអំពី មេរោគអេដស៍។ វាជាការសំខាន់ដែលត្រូវផ្តោតទៅលើការអប់រំសុខភាពផ្លូវភេទ សម្រាប់យុវជន ហើយក៏ត្រូវអប់រំ កាន់តែខ្លាំងថែមទៀតដល់កុមារនៅតាមផ្លូវ ដែលពួកគេអាចនឹងងាយប្រឡូកក្នុងសកម្មភាពដែលប្រថុយប្រថាន និងអាចខ្វះការណែនាំ និងទំនាក់ទំនងដែលគួរឲ្យទុកចិត្តជាមួយមនុស្សធំ ទាក់ទងនឹងបញ្ហាទាំងអស់នេះ (SOTWC, 2016)។

អនុសាសន៍

បទពិសោធន៍នៃអំពើហិង្សាផ្នែករាងកាយ ផ្លូវភេទ និងផ្លូវអារម្មណ៍កើតឡើងច្រើន ហើយជាញឹកញាប់ កើតឡើងជាមួយគ្នាក្នុងចំណោមកុមារដែលរស់នៅ/ធ្វើការនៅតាមផ្លូវក្នុងតំបន់ប៉ោយប៉ែត និងត្រូវបានមនុស្សមួយចំនួនធ្វើបាប ដូចជាប៉ូលីស កុមារអាយុស្រករគ្នា មនុស្សធំ មនុស្សដែលមិនស្គាល់មុខ និងក្រុមបងធំ។ បន្ថែមពីលើនេះទៀត ការប្រើគ្រឿងញៀនត្រូវបានរកឃើញថា ជាបញ្ហាមួយធំក្នុងចំណោមក្មេងប្រុសដែលរស់នៅ/ធ្វើការតាមផ្លូវក្នុងប៉ោយ ប៉ែតដែលត្រូវបានរកឃើញថាមានការទាក់ទងទៅនឹងផលប៉ះពាល់អវិជ្ជមានទៅលើសុខភាព អំពើហិង្សាលើរាង កាយ អំពើហិង្សាផ្នែកផ្លូវភេទ និងការអប់រំ។ តាមរយៈលទ្ធផលដែលបានរកឃើញទាំងនេះ កម្មវិធីធំៗខាងក្រោមមួយ ត្រូវបានផ្តល់អនុសាសន៍សម្រាប់អង្គការសិទ្ធិកុមារ ម្ចាស់ជំនួយ រដ្ឋាភិបាល និងការស្រាវជ្រាវបន្ថែមនៅពេលអនាគត៖

សម្រាប់អង្គការសិទ្ធិកុមារ៖

- អន្តរាគមន៍ទៅលើគ្រឿងញៀន ដោយផ្តោតទៅលើការកសាងសហគមន៍ និងការផ្សារភ្ជាប់ទំនាក់ទំនងក្នុងសង្គម៖ វាជាការសំខាន់ដែលអង្គការសិទ្ធិកុមារត្រូវប្រើយុទ្ធសាស្ត្រចម្រុះ ដើម្បីជួយកាត់បន្ថយការប្រើប្រាស់គ្រឿងញៀន និងធ្វើឲ្យជីវិតកុមារនៅតាមផ្លូវក្នុងតំបន់ប៉ោយប៉ែតមានភាពប្រសើរឡើង។ យុទ្ធសាស្ត្រនៃការទប់ស្កាត់អាចរួមមាន កម្មវិធីដែលផ្តោតលើការពង្រឹងទំនាក់ទំនង និងការផ្សារភ្ជាប់ជាមួយគ្រួសារ រួមមាន ឪពុកម្តាយ គ្រូបង្រៀន កុមារអាយុស្រករគ្នា អ្នកដឹកនាំផ្នែកសាសនា និងមនុស្សធំផ្សេងទៀត។ ឧទាហរណ៍ ការបង្កើតទីកន្លែងសម្រាប់ឲ្យកុមារប្រាស្រ័យទាក់ទងគ្នាជាវិជ្ជមាន ជាមួយគ្រួសារ និងអ្នកមើលថែរបស់ពួក គេ អាចជាវិធីសាស្ត្រអន្តរាគមន៍មួយ។ កម្មវិធីដូច្នេះអាចកើតឡើងនៅក្នុងមណ្ឌលសំចតមួយក្នុងសហគមន៍ ដែលមានបុគ្គលិកអង្គការ/បុគ្គលិកសង្គមកិច្ច ដើម្បីលើកទឹកចិត្ត និងជំរុញឲ្យមានការប្រាស្រ័យទាក់ទង និង សកម្មភាពវិជ្ជមានតាមការចាំបាច់។ លោកសង្ឃ អ្នកដឹកនាំក្រុមជំនុំ និងអង្គការគួរតែត្រូវបានលើកទឹកចិត្តឲ្យ បង្កើតកន្លែងសម្រាប់ឲ្យកុមារជួបជុំគ្នាក្នុងក្រុមយុវជន និងក្លឹបកុមារ ដែលមានឥទ្ធិពលវិជ្ជមានទៅលើកុមារដទៃទៀត។
- កសាងភាពជាសះស្បើយ ដើម្បីទប់ស្កាត់អំពើហិង្សា និងការប្រើសារធាតុញៀន៖ កម្មវិធីសង្គមគួរតែផ្តោតទៅលើការកសាងកត្តាការពារដែលនាំមកនូវការជាសះស្បើយ ការកាត់បន្ថយការប្រឈមរបស់កុមារក្នុងការប្រើសារធាតុញៀន។ បន្ថែមពីលើកម្មវិធី ស្តារសម្បទាអ្នកញៀនថ្នាំ កម្មវិធីទប់ស្កាត់គួរតែរួមបញ្ចូលជំនាញបំណិនជីវិត ការបង្ហាត់បង្រៀនកូនតាមរបៀបវិជ្ជមាន ការអប់រំអំពីផ្លូវភេទ និងកម្មវិធីមិត្តអប់រំមិត្ត។ បទ អន្តរាគមន៍ទាំងនេះអាចនឹងចំណាយពេល និងកម្លាំងច្រើន ប៉ុន្តែអាចមានប្រសិទ្ធិភាពច្រើននៅពេលអនាគត និងជួយសម្រេចគោលដៅសម្រាប់កម្មវិធីទប់ស្កាត់ និងស្តារនីតិសម្បទា។

- ជំនួយគាំទ្រដល់សាលារៀន៖ គ្រូបង្រៀនគួរតែទទួលជំនួយ ដើម្បីផ្ដល់ការអប់រំដល់កុ មារដែលងាយរងគ្រោះ រួមមាន កុមារដែល "ស្ថិតនៅក្រោយគេ"។ សាលារៀនគួរតែផ្ដល់ថ្នាក់បំពេញវិជ្ជាសម្រាប់កុមារ ដែលរៀនបាន ពិន្ទុទាបនៅសាលារៀន ដើម្បីពួកគេអាចរៀនតាមគេ ទាន់។ សាលារៀនគួរតែត្រូវបានលើកទឹកចិត្តឲ្យកំណត់ អំពីកុមារដែលងាយរងគ្រោះក្នុងការធ្វើចំណាកស្រុក និងជួយឲ្យកុមារបន្តរៀននៅក្នុងសាលារៀន។

- ពង្រីកសកម្មភាពមើលការខុសត្រូវលើមិត្តភ័ក្ដ៖ ទិន្នន័យបង្ហាញថា កុមារចំនួនជាងពាក់កណ្ដាល (៥១%) និយាយថា ឪពុកម្ដាយរបស់ពួកគេធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ ដែលកុមារ ២៤% ត្រូវទុកនៅម្នាក់ឯង ដោយ គ្មានឪពុក/ម្ដាយ ឬអ្នកមើលថែ។ អំពើហិង្សា និងការប្រើសារធាតុញៀនក្នុងចំណោមកុមារទាំងនេះ ត្រូវបានរក ឃើញថាមានកម្រិតខ្ពស់ បើប្រៀបធៀបជាមួយកុមារដែលបានទាក់ទងជាប្រចាំជាមួយឪពុក/ម្ដាយ ឬអ្នកមើលថែ។ បុគ្គលិកអប់រំមិត្ត/យុទ្ធសាស្ត្រអន្តរាគមន៍ផ្ដោតលើបណ្ដាញ ត្រូវបានរកឃើញថា ផ្ដល់នូវឥទ្ធិពលវិជ្ជមានក្នុងចំណោម យុវជនកម្ពុជាវ័យក្មេង រួមមាន ការកាត់បន្ថយការប្រើប្រា ស់ថ្នាំមេតាំហ្វេតាមីន ការកើនឡើងនៃការប្រើ ស្រោមអនាម័យ និងការថយចុះនៃអត្រាជំងឺកាមរោគ (Sherman, et al., 2008)។ ទោះបីជាកម្មវិ ធីមិត្តអប់រំមិត្ត កំពុងដំណើរការក្នុងតំបន់ប៉ោយប៉ែតហើយក៏ដោយ (អនុវត្តដោយអង្គការតំណក់ទឹក) អាចនឹងមានការពង្រីកកម្មវិធី ទាំងនេះ ដើម្បីរួ មបញ្ចូលការប្រើប្រាស់ជាយុទ្ធសាស្ត្រនូវ "ភាពជាអ្នកដឹកនាំនៃយុវជន" ដើម្បីផ្ដល់ការគាំទ្រ និង ជំរុញយុវជនដែលងាយរងគ្រោះ ដើម្បីស្វែងរកឱកាសចូលរួម ជាមួយសហគមន៍របស់ពួកគេជាលក្ខណៈវិជ្ជមាន (Iwasaki, 2015)។ កម្មវិធីទាំងនេះអាចនឹងផ្ដោតជាក់លាក់ទៅលើតម្រូវការរបស់កុមារ ដែលឪពុកម្ដាយធ្វើ ចំណាកស្រុក និងទុកកូនរបស់ពួកគេចោល ឬឪពុកម្ដាយដែលមិននៅផ្ទះ។ បន្ថែមពីលើនេះទៀត ការអប់រំសុខភាព ផ្លូវភេទ និងសុខភាពបន្តពូជអាចនឹងត្រូវបន្ថែមទៅក្នុងការពង្រីកយុទ្ធសាស្ត្រទាំងនេះ ដើម្បីជួយអប់រំដល់កុមារ (៨៩%) ដែលនិយាយថា ពួកគេមិនបានទទួលការអប់រំផ្នែកសុខភាពផ្លូវភេទ។

- ពង្រីកការបណ្ដុះបណ្ដាលសម្រាប់បុគ្គលិកអង្គការ និងបុគ្គលិកផ្នែកសុខភាព៖ ការបណ្ដុះបណ្ដាលពិសេស គួរតែ ត្រូវបានផ្ដល់សម្រាប់បុគ្គលិកអង្គការ និងបុគ្គលិកផ្នែកសុខភាព អំពីផលប៉ះពាល់នៃគ្រឿងញៀនទៅលើ កុមារ និងយុវជន ការថែទាំសម្រាប់កុមារដែលទទួលរងនូវអំពើហិង្សា និងផលប៉ះពាល់របស់គ្រឿងញៀន ដែល ប៉ះពាល់ដល់ការលូតលាស់ និងសុខភាពផ្លូវភេទ។

- ធ្វើការជាមួយមន្ត្រីអនុវត្តច្បាប់ដើម្បីពង្រឹងសិទ្ធិកុមារ៖ កុមារជាង ១/៤ នៅក្នុងការសិក្សាស្រាវជ្រាវនេះ លើកឡើងអំពីអំពើហិង្សាលើរាងកាយពីប៉ូលីស ជាពិសេសក្នុងចំណោមកុមារដែលប្រើគ្រឿងញៀន និង ក្មេងប្រុសដែលឆ្លងព្រំដែនដើម្បីស្វែងរកការងារធ្វើ។ នៅក្នុងបរិបទនេះ វាជាការល្អសម្រាប់អង្គការនានា និង អង្គ ការសិទ្ធិកុមារ ក្នុងការកសាងទំនាក់ទំនងរឹងមាំជាមួយមន្ត្រីអនុវត្តច្បាប់នៅតាមព្រំដែន ដើម្បីធ្វើការតស៊ូ មតិ និង ដើម្បីបន្តការសន្ទនាក្នុងការលើកកម្ពស់សិទ្ធិកុមារ។ បន្ថែមពីលើនេះទៀត វាអាចជាការល្អក្នុងការផ្ដល់វគ្គ បណ្ដុះបណ្ដាល/ការសន្ទនាជាមួយប៉ូលីស បុគ្គលិកសន្តិសុខព្រំដែន បុគ្គលិកថែទាំសុខភាព បុគ្គលិកសង្គមកិច្ច និង

មន្ត្រីអន្តោប្រវេសន៍អំពីសិទ្ធិកុមារ ជាពិសេសទាក់ទងនឹងការប្រព្រឹត្តចំពោះកុមារដែលធ្វើការ/រស់នៅតាមផ្លូវ ឬកុមារដែលប្រើគ្រឿងញៀន។

- តស៊ូមតិជាមួយរដ្ឋាភិបាលថៃ និងរដ្ឋាភិបាលកម្ពុជា ដើម្បីការពារគោលនយោបាយ និងកម្មវិធី សម្រាប់ កុមារដែលរស់នៅ/ធ្វើការតាមផ្លូវ (សូមមើលខាងក្រោម)។

សម្រាប់ម្ចាស់ជំនួយៈ

- ត្រូវការថវិកាបន្ថែមទៀតសម្រាប់កម្មវិធីគ្រប់ជ្រុងជ្រោង សម្រាប់យុវជនដែលកំពុងនៅរៀន ជាពិសេស កុមារដែលមិនទាន់បានបញ្ចប់ការសិក្សា សម្រាប់កម្មវិធីទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ បញ្ហាសុខភាពជុំវិញគ្រឿងញៀន និងសុខភាពផ្លូវភេទ។ ត្រូវការថវិកាសម្រាប់ការអប់រំបែបវិជ្ជាជីវៈ សម្រាប់បុគ្គលិកផ្នែកសុខភាព បុគ្គលិកសង្គមកិច្ច ប៉ូលីស បុគ្គលិកសន្តិសុខនៅព្រំដែន មន្ត្រីផ្នែកអន្តោប្រវេសន៍។ ត្រូវការថវិកាសម្រាប់ការងារស្រាវជ្រាវ និងការតស៊ូមតិ។

សម្រាប់រដ្ឋាភិបាលៈ

- ការបណ្តុះបណ្តាលពិសេសគួរតែផ្តល់សម្រាប់មន្ត្រីសាធារណៈអំពីសិទ្ធិកុមារ ជាពិសេស មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីបម្រើការនៅព្រំដែន ដើម្បីធានាថា ពួកគេមានទំនួលខុសត្រូវចម្បងក្នុងការការពារសិទ្ធិកុមារ។
- រដ្ឋាភិបាលគួរតែធ្វើការ អនុលោមតាមអនុសាសន៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិ ស្តីអំពីសិទ្ធិកុមារ និងចេញច្បាប់ដើម្បីបញ្ឈប់ការឃុំខ្លួនកុមារអន្តោប្រវេសន៍។ មុនពេលដែលមានការការផ្លាស់ប្តូរនេះ រដ្ឋាភិបាលគួរតែខិតខំធ្វើយ៉ាងណាធានាថា ការឃុំខ្លួនកុមារមិនមែនធ្វើដោ យគ្មានហេតុផល ឬគ្មានរយៈពេល កំណត់ច្បាស់លាស់នោះទេ (HRW)។
- វាជាការសំខាន់ដែលរដ្ឋាភិបាលពិចារណាអំពីជម្រើសផ្សេងៗដែលមានប្រសិទ្ធិភាព ជាជាងការឃុំខ្លួនកុមារ។ ជ្រើសរើសវិធីសាស្ត្រផ្សេងក្រៅពីការឃុំខ្លួន ដើម្បីអនុញ្ញាតឲ្យកុមារបន្តនៅជាមួយគ្រួសារ/អ្នកមើលថែរបស់ពួកគេ នៅពេលកំពុងដោះស្រាយអំពីឋានៈអន្តោប្រវេសន៍របស់ពួកគេ (HRW)****។

សម្រាប់ការស្រាវជ្រាវនៅពេលអនាគតៈ

- ការសិក្សាទៅលើឥទ្ធិពលនៃការសន្មតនៃយេនឌ័រភេទប្រុស អំពីភាពងាយរងគ្រោះរបស់ភេទប្រុសទៅនឹងអំពើហិង្សាផ្អែកផ្លូវភេទ ជាពិសេសក្នុងចំណោមកុមារដែលរស់នៅ/ធ្វើការនៅតាមផ្លូវ។
- ការសិក្សាទូលំទូលាយអំពីផលប៉ះពាល់ទៅលើកុមារ ដែលឪពុកម្តាយធ្វើចំណាកស្រុកទៅប្រទេសថៃ។ ធ្វើការស្រាវជ្រាវជាក់លាក់បន្ថែមទៀតនៅក្នុងមាតិកានេះ ដោយសិក្សាទៅលើបញ្ហានៃការផ្តាច់ទំនាក់ទំនងរវាង

កុមារ និងក្រុមគ្រួសារ និងផលប៉ះពាល់ទៅលើភាពងាយរងគ្រោះរបស់ពួកគេ ដែលធ្លាក់ខ្លួនទៅប្រើសារធាតុញៀន និង/ឬយន្តការដោះស្រាយបញ្ហាបែបអវិជ្ជមានផ្សេងទៀត។

- កិច្ចការស្រាវជ្រាវនៅពេលអនាគតគួរតែសិក្សាឲ្យបានជាក់លាក់ និងទូលំទូលាយ អំពីបទពិសោធន៍របស់កុមារជនជាតិខ្មែរ ដែលត្រូវបានចាប់ខ្លួនក្នុងប្រទេសថៃ រួចហើយត្រូវបានឃុំខ្លួន។ បន្ទាប់មក គួរមានកិច្ចការស្រាវជ្រាវជាក់លាក់បន្ថែមទៀតដែលសិក្សាទៅលើការទាក់ទងរវាងការចាប់ខ្លួន ការប៉ះទង្គិចផ្លូវចិត្តរបស់ កុមារ និងបញ្ហានៃការប្រើសារធាតុញៀន និងយុទ្ធសាស្ត្រដោះស្រាយបញ្ហាបែបអវិជ្ជមានផ្សេងទៀត។

BIBLIOGRAPHY

Akinci, G., Crittle, J. 2008. Special economic zone : performance, lessons learned, and implication for zone development. Foreign Investment Advisory Service (FIAS) occasional paper. Washington, DC: World Bank. http://documents.worldbank.org/curated/en/343901468330977533/Special-economic-zone-performance-lessons-learned-and-implication-for-zone-development

Analysing Development Issues Centre (ADIC). (2003). Labour Migration to Thailand and the Thai-Cambodian Border Recent Trends in Four Villages of Battambang Province. ADIC. P1-40.

Beazley, H. (2003) Subcultures in Indonesia, Children's Geographies, Vol. 1, No. 2, 181–200.

Beazley, H. (2015). Multiple identities, multiple realities: children who migrate independently for work in Southeast Asia, Children's Geographies, 13:3, 296-309.

Butler, U. (2009). Freedom, Revolt and 'Citizenship' Three pillars of identity for youngsters living on the streets of Rio de Janeiro, SAGE Publications. Los Angeles, London, New Delhi, Singapore and Washington DC, Vol 16(1): 11–29.

Capaldi, M. (2014). A Child's Journey in Search of Rights. Terre Des Hommes - Netherlands. The Hague. From http://www.streetchildrenresources.org/wp-content/uploads/2016/06/A-Baseline-Study-on-the-Vulnerabilities-of-Street-Involved-Boys.pdf (Accessed: 01 May 2017).

Davis, J., & Miles, G. (2015). They Didn't Help Me; They Shamed Me: A Baseline Study on the Vulnerabilities of Street-Involved Boys To Sexual Exploitation in Manila, Philippines. Love146. http://www.streetchildrenresources.org/wp-content/uploads/2016/06/A-Baseline-Study-on-the-Vulnerabilities-of-Street-Involved-Boys.pdf (Accessed: 28 November 2016)

Davis, J., & Miles, G. (2014). "I want to be brave": A Baseline Study on the Vulnerabilities of Street-Working Boys to Sexual Exploitation in Sihanoukville, Cambodia. Love146. http://digitalcommons.unl.edu/cgi/viewcontent.cgi?article=1005&context=humtrafcon6 (Accessed: 5 May, 2017).

Davis, J., Fiss, J., & Miles, G. (2016). To Help My Parents: An Exploratory Study on the Hidden Vulnerabilities of Street-Involved Children and Youth in Chiang Mai, Thailand. https://up-international.org/wp-content/uploads/2016/03/ToHelpMyParents-English.pdf (Accessed: 25 May 2016)

Davis, J., et al. (2017). Sexual violence among street-involved children in Southwest Cambodia. Manuscript submitted for publication.

ECPAT International (2016), Regional Report on Sexual Exploitation of Children in Travel and Tourism - Southeast Asia. p.10

ECPAT International (2016), "Bill of rights for child victims of sexual exploitation", accessed 7 February 2017, http://www.ecpat.org/wp-content/uploads/2016/11/ KnowYourRight_ENG_A2size.pdf.

Fiss, J. (2013). Street children's survey report in Poipet, Cambodia. Unpublished report. Damnok Toek. Phnom Penh, Cambodia

Frederick, J. 2010. Sexual abuse and exploitation of boys in South Asia a review of research findings, legislation, policy and programme responses. Florence: UNICEF Innocenti Research Centre.

Holmes, G. 1997. See no evil, hear no evil, speak no evil: Why do relatively few male victims of childhood sexual abuse receive help for abuse-related issues in adulthood? Clinical Psychology Review, 17(1), 69-88. doi:10.1016/s0272-7358(96)00047-5

Human Rights Watch. (2015, July 01). Two Years With No Moon. Retrieved May 01, 2017, from http://www.hrw.org/report/2014/09/01/two-years-no-moon/immigration-detention-children-thailand

International Justice Mission (2013). The Commercial Sexual Exploitation of Children in Cambodia. Phnom Penh, Cambodia.

Iwasaki, Y. (2015). The role of youth engagement in positive youth development and social justice youth development for high-risk, marginalised youth. International Journal of Adolescence and Youth, 21(3), 267-278. doi:10.1080/02673843.2015.1067893

Keane, K. (2006). Street-Based Child Sexual Exploitation in Phnom Penh and Sihanoukville: A Profile of Victims. Phnom Penh: Action Pour Les Enfants.

Lalor, K. & McElvaney, R. (2010). Child Sexual Abuse, Links to Later Sexual Exploitation/High-Risk Sexual Behavior, and Prevention/Treatment, Dublin Institute of Technology.

Möller-Leimkühler, A. European Archives of Psychiatry and Clinical Neurosciences (2003) 253: 1. doi: 10.1007/s00406-003-0397-6

National Institute on Drug Abuse (NIDA). (2003). Preventing Drug-Use Among Children and Adolescents: A Research-Based Guide for Parents, Educators, and Community Leaders. US Department of Health and Human Services.

Panter-Brick, C. (2002). Street Children, Human Rights, and Public Health: A Critique and Future Directions, Annual Review of Anthropology, Vol. 31 pp. 147-171.

Paolucci, E., et al. (2001). A Meta-Analysis of the Published Research on the Effects of Child Sexual Abuse, Journal of Psychology, Vol. 135 Issue 1, p17. 20p.

Pocock NS, et al. (2016) Labour Trafficking among Men and Boys in the Greater Mekong Subregion: Exploitation, Violence, Occupational Health Risks and Injuries. PLoS ONE 11(12): e0168500. doi: 10.1371/journal. pone.0168500

Ray, P. et al. (2011). Still on the street –still short of rights, Analysis of policy and programs related to street involved children, Plan and Consortium for Street Children, UK.

Reale, D. (2008). Away from Home, Protecting and Supporting Children on the Move, Save the Children, London.

Rubenstein, B. L., & Stark, L. 2016. A Forgotten Population: Estimating the Number of Children Outside of Households in Cambodia. Global Social Welfare, 3(2), 119-124. doi:10.1007/s40609-016-0051-7

Sampson, I. & Sokleap TraT.y. (2016). Reasons for and Effects of Migrating to Thailand on Cambodian Young People. Kone Kmeng. Phnom Penh.

Sherman SS, et al. Drug use, street survival, and risk behaviors among street children in Lahore. Pakistan. J Urban Health 2005;82:113–24.

The World Bank. (2008). Special Economic Zones: Performance, Lessons Learned, and Implications for Zone Development. doi:10.1596/26103

Thomas de Benítez, S. (2007). State of the World's Street Children: Violence, Consortium for Street Children, London.

Tyler, KA & Johnson, KA. Trading sex: Voluntary or coerced? The experiences of homeless youth. J Sex Res 2006;43:208–16.

USAID. (2011). School Dropout Prevention Program: Dropout Trend Analysis. From: http://schooldropoutprevention.com/wp- content/files/reports/Trend_Analysis_Cambodia_English.pdf. (Accessed 1 May, 2017).

United Nations Children's Emergency Fund (UNICEF). (2011). The State of the World's Children 2012: Children in an Urban World. Retrieved May 01, 2017, from https://www.unicef.org/sowc2012/

United Nations High Commissioner for Refugees. (2008). UNHCR Global Appeal 2008-2009. Retrieved March 31, 2017, from http://www.unhcr.org/uk/474ac8df0.pdf

United Nations Human Rights Office of the High Commissioner. (2011). OHCHR Report 2011. Retrieved May 01, 2017, from http://www2.ohchr.org/english/ohchrreport2011/web_version/ohchr_report2011_web/allegati/downloads/0_Whole_OHCHR_Report_2011.pdf

United Nations Inter-Agency Project on Human Trafficking (2008). Guide to ethics and human rights in counter-trafficking, Ethical standards for counter-trafficking research and programming, United Nations Inter-Agency Project on Human Trafficking, Bangkok.

United Nations International Children's Emergency Fund (UNICEF). (2004). Cambodia National Youth Risk Behavior Survey. UNICEF, Ministry of Education, Youth and Sports. Phnom Penh.

United Nations International Children's Emergency Fund (UNICEF). (2013). Findings from Cambodia's Violence Against Children Survey 2013. Retrieved May 25, 2016 from http://www.unicef.org/cambodia/UNICEF_VAC_Full_Report_English.pdf

United Nations International Children's Emergency Fund (UNICEF). (2016). National Baseline Study on Violence against Children in the Philippines. UNICEF Philippines. Manila.

United Nations International Children's Emergency Fund (UNICEF). (2016, September 23). The State of the World's Children Report 2016. Retrieved May 01, 2017, from https://www.unicef.org/sowc2016/

Urban Management Programme (2000). Street children and Gangs in African Cities: Guidelines for Local Authorities, UMP, Working Paper Series. 18.

Veeran V. (2004), Working with Street Children: A Child centered Approach, Child Care in Practice, 10:4, pp. 359-366

Walsh, J. (2011). Cambodian Migrants in Thailand: Working Conditions and Issues Available:http://citeseerx.ist.psu.edu/viewdoc/download?doi=10.1.1.848.7730 &rep=rep1&type=pdf. (Accessed: May 1, 2017).

Weiss, K. G. (2010). Male sexual victimization: Examining men's experiences of rape and sexual assault. Men and Masculinities, 12, 275–298. doi:10.1177/1097184X08322632

Williams C. 1993. Who are street children? A hierarchy of street use and appropriate responses. Child Abuse & Neglect 17:831-41

Woan, J. et al. (2013). Journal of Adolescent Health, 53, pp. 314-321.

World Health Organization (2000). Working with Street-Children: A Training Package on Substance Use, Sexual and Reproductive Health including HIV/AIDS and STDs. Department of Mental Health and Substance Dependence: Geneva.

World Health Organization (2007). Engaging Men and Boys in Changing Gender-Based Inequity in Health: Evidence from Programme Interventions. Geneva. From www.who.int/ gender/documents/Engaging_men_boys. pdf.

York, B. (2013). The Risk of Movement: Migration in Cambodia. From: http://www.clec.org.kh/web/images/Resources/Res_The%20Risk%20of%20Moveme nt-CLEC%202013%20Annual%20Migration%20Report.pdf. (Accessed: May 1, 2017).